សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្តី

៤



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាស
[illegible] សម្រាប់ប្រើប្រាស់តាមសាលារៀន។

www.elibraryofcambodia.org

សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្ដី

ថ្នាក់ទី ៤

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

| | | |
|---|---|---|
| **អ្នកនិពន្ធនិងរៀបរៀង** | លោក | ព្រៃ សំបូរ |
| **អ្នកខាយអត្ថបទ** | លោកស្រី | ហាក់ ផាន្នី |
| **អ្នកពិនិត្យអក្ខរាវិរុទ្ធ** | លោកស្រី | ឈឹម សក្តិវិឡែត |
| | លោក | អ៊ុំ បុប្ផា |
| **ចិត្រករ** | លោក | ហ៊ុយ វណ្ណថេន |
| **អ្នករចនាធំព័រ** | លោក | គង់ ចិត្រា |
| **គណៈកម្មការពិនិត្យ** | បណ្ឌិត | នៅ ស៊ុន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៦៦០ អយក.ប្រក. ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

**ហាមថតចម្លងសៀវភៅនេះ**

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-002-169

www.elibraryofcambodia.org

# អារម្ភកថា

សួស្តី ! លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ជាទីមេត្រី ! សៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៨នេះ បានរៀបចំឡើងស្របតាមសៀវភៅសិក្សាថ្មីមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សៀវភៅនេះត្រូវបានរៀបចំឡើង ដើម្បីជាជំនួយដល់ការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកសិក្សាទាំងអស់លើផ្នែកសរសេរតាមអាន និងតែងសេចក្តី ដើម្បីឱ្យទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងសៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៨នេះ មានអត្ថបទខ្លីៗសម្រាប់ការសរសេរតាមអាន អំណាន ពាក្យពិបាក ពន្យល់ពាក្យ បដិសព្ទ សទិសសព្ទ វេវចនសព្ទ សំណួរចម្លើយ គម្រោងតែងសេចក្តី និងមានអធិប្បាយតែងសេចក្តីសំខាន់ៗមួយចំនួនថែមទៀត។ ចំណុចទាំងអស់នេះ ជាការចូលរួមលើកកម្ពស់ឱ្យការរៀន និងបង្រៀនសរសេរតាមអាន និងតែងសេចក្តីទទួលបានលទ្ធផលល្អថែមទៀត។

យើងខ្ញុំសង្ឃឹមថា សៀវភៅសរសេរតាមអាននិងតែងសេចក្តីថ្នាក់ទី៨នេះនឹងក្លាយជាជំនួយដ៏ល្អ សម្រាប់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ពុំខាន។

យើងខ្ញុំរង់ចាំទទួលមតិស្ថាបនាពីប្រិយមិត្តអ្នកអាន អ្នកសិក្សាគ្រប់ពេលវេលា ដើម្បីកែសម្រួលសៀវភៅនេះឱ្យកាន់តែល្អថែមទៀត។

**អ្នកនិពន្ធ**

**ខ្មែរ សំបូរ**

www.elibraryofcambodia.org

# មាតិកា

## វិញ្ញាសា
## សរសេរតាមអាន

ទំព័រ


១. រឿង រៃនិងស្រមោច .................. ០១
២. រឿង កុមារណារិន .................. ០៦
៣. រឿង យ៉ារីមើលថែប្អូន .................. ១១
៤. រឿង គោនិងហ៊ីង .................. ១៦
៥. កីឡានិងល្បែងមាន សុវត្ថិភាព .................. ២១
៦. រឿង ជ័យជម្នះរបស់តុលា .................. ២៦
៧. រឿង ក្មេងសុចរិត .................. ៣០
៨. រឿង ព្រះថោងនាងនាគ .................. ៣៥
៩. រឿង គ្រូពេទ្យភូមិយើង .................. ៤០
១០. ការគោរពឪពុកម្ដាយ .................. ៤៥
១១. រឿង ខ្លានិងកណ្ដុរ .................. ៥១
១២. រឿង បងប្អូនបីនាក់ .................. ៥៦
១៣. រឿង កុមារចេះគួរសម .................. ៦២
១៤. រឿង ម្លូលបារាំង .................. ៦៧
១៥. ការផ្សព្វផ្សាយពីផលអាក្រក់នៃ ថ្នាំជក់ .................. ៧២
១៦. ជំណាំស្រូវ .................. ៧៧
១៧. រឿង ក្ងាន ក្អែក និងចចក .................. ៨២


## វិញ្ញាសា
## តែងសេចក្ដីបែបពិពណ៌នា


១. អំពីមនុស្ស .................. ៨៨
២. អំពីសត្វ .................. ៩៣
៣. អំពីទីកន្លែង .................. ៩៥
៤. អំពីទេសភាព .................. ៩៩
៥. អំពីសកម្មភាព .................. ១០២
៦. អំពីពិធីបុណ្យផ្សេងៗ .................. ១០៥


www.elibraryofcambodia.org

# លំនាំបង្រៀន

## I. សរសេរតាមអានត្រួតពិនិត្យ

ក. ការសរសេរតាមអាន

១. គ្រូឱ្យសិស្សម្នាក់ទៅសរសេរនៅក្ដារខៀន ដោយបិទផ្ទាំងខ្នងជិត។
២. គ្រូអានអត្ថបទមួយចប់ឱ្យសិស្សស្ដាប់។
៣. គ្រូហៅកន្សោមពាក្យ ឬឃ្លាខ្លីចំនួនបីដង ឱ្យសិស្សសរសេរតាមចាប់ពីដើមរហូតដល់ចប់។

> *បញ្ជាក់៖* គ្រូអាចឱ្យសិស្សពីរនាក់ ចាំតាមក្រោយគ្រូដោយសិស្សម្នាក់ចាំតាមមុនពេលសរសេរ ហើយសិស្សម្នាក់ទៀតចាំតាម បន្ទាប់ពីខ្លួនសរសេររួច។

៤. គ្រូអានអត្ថបទឱ្យសិស្សស្ដាប់ឡើងវិញដោយយឺតៗ និងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ឡើងវិញ និងទុកពេលឱ្យសិស្សកែកំហុស។

ខ. លំហាត់

១. គ្រូដឹកនាំសិស្សឱ្យហ្វឹកហាត់អានពាក្យមួយម្ដងៗ ។ បន្ទាប់មក ឱ្យសិស្សហ្វឹកហាត់អានពាក្យទាំងនោះ។ គ្រូហៅសំណួរឱ្យសិស្សសរសេរ ឬគ្រូចម្លងសំណួរ ឬលំហាត់ដាក់លើក្ដារខៀន ឬគ្រូចម្លងសំណួរ ឬលំហាត់ដាក់ក្រដាសផ្ទាំងធំយកមកបិទ។
២. គ្រូដឹកនាំសិស្សពន្យល់ពាក្យដោយប្រើវិធីផ្សេងៗដូចជា ប្រើរូបភាពរកន័យដូច រកន័យផ្ទុយ ឬពន្យល់ន័យតែម្ដង។ល។
៣. គ្រូដឹកនាំសិស្សឱ្យរក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទ។

គ. សំណួរ

១. គ្រូហៅសំណួរឱ្យសិស្សសរសេរ ឬគ្រូចម្លងសំណួរ និងលំហាត់ដាក់លើក្ដារខៀន ឬគ្រូចម្លងសំណួរដាក់ក្រដាសផ្ទាំងធំយកមកបិទ។
២. គ្រូណែនាំសិស្សឱ្យឆ្លើយសំណួរមួយម្ដងៗ រហូតដល់ចប់។

ឃ. ការកែលម្អ

១. គ្រូបើកផ្ទាំងខ្នងធ្វើការកែលម្អលើការសរសេរតាមអានរួមលើក្ដារខៀន។

www.elibraryofcambodia.org

២. គ្រូឱ្យសិស្សប្ដូរកិច្ចការគ្នាកែ ដោយគូសពីក្រោមពាក្យខុស និងគូសចំនួនកំហុស នៅខាងឆ្វេង ដើមបន្ទាត់នៃពាក្យខុសនោះ។
៣. គ្រូធ្វើការកែលម្អសំណួរ ឬលំហាត់រួមលើក្ដារខៀនម្ដងមួយៗរហូតដល់ចប់។
៤. គ្រូឱ្យសិស្សធ្វើការកែលម្អកិច្ចការខ្លួន។

## II. តែងសេចក្ដី

### ក. ការបង្ហាញ

១. រំឭកមេរៀនដោយសួរសំណួរទាក់ទងនឹងតែងសេចក្ដីបែបពណ៌នា
២. អានគម្រោងគំរូតែងសេចក្ដីបែបពណ៌នា
៣. សំណួរទាក់ទងនឹងខ្លឹមសារគម្រោងតែងសេចក្ដីបែបពណ៌នាគំរូ
៤. អានអត្ថបទតែងសេចក្ដីគំរូ ដោយសង្កេតមើលចំណុចសំខាន់នៃតែងសេចក្ដីបែបពណ៌នា
៥. សួរសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទតែងសេចក្ដីគំរូ
៦. សួរសំណួររកឱ្យឃើញទម្រង់ និងគម្រោងរបស់តែងសេចក្ដី។

### ខ. ការអនុវត្ត

១. បំផុសសំណួរ ឱ្យឃើញគម្រោងតែងសេចក្ដីលម្អិតទាក់ទងនឹងប្រធានតែងសេចក្ដី
២. ការប្រមូលគំនិត ៖ ប្រមូលគំនិតលម្អិតទាក់ទងនឹងគម្រោងតែងសេចក្ដី
៣. ការសរសេរព្រាង ៖ យកគំនិតដែលប្រមូលបានមកសរសេរព្រាងជាល្បះពេញលេញឱ្យបានត្រឹមត្រូវតាមគម្រោងតែងសេចក្ដី
៤. ការកែលម្អ ៖ គ្រូឱ្យសិស្សប្ដូរកិច្ចការគ្នាកែ (ក្នុងការកែមិនត្រូវឱ្យសិស្សគូសវាស ឬសរសេរលើកិច្ចការគេទេ បើពិនិត្យឃើញមានកំហុសត្រូវមកពិភាក្សាកែលម្អជាមួយម្ចាស់ដើមវិញ) ពេលកែរួចត្រូវប្រគល់កិច្ចការឱ្យម្ចាស់ដើមវិញ
៥. ការសរសេរសម្រេច ៖ ឱ្យសិស្សយកកិច្ចការរបស់ខ្លួនមកសរសេរសម្រេចឱ្យបានស្អាតត្រឹមត្រូវ។

### គ.ការវាយតម្លៃ

១. សួរសំណួរទាក់ទងនឹងបញ្ញត្តិតែងសេចក្ដីបែបពណ៌នា
២. សួរសំណួរពង្រឹងចំណេះដឹងអំពីគម្រោងតែងសេចក្ដីខាងលើ
៣. ដាក់ប្រធានតែងសេចក្ដីថ្មីឱ្យសិស្សធ្វើនៅផ្ទះដោយផ្អែកលើគម្រោងខាងលើ។

www.elibraryofcambodia.org

វិញ្ញាសាទី ១

# រឿង រៃនិងស្រមោច



រដូវប្រាំង រៃច្រៀងលេងគ្មានគិតខ្វល់ខ្វាយរកស្រូវអង្ករទុកឡើយ ឯស្រមោចជាសត្វឧស្សាហ៍ខំនាំគ្នារកស្បៀងទុក។ រដូវភ្លៀងធ្លាក់មកដល់ រៃអត់អាហារក៏ហើរទៅខ្ចីស្បៀងពីស្រមោច។ ស្រមោចសួរ ៖ " អើរៃ ! កាលពីរដូវប្រាំង តើអ្នករវល់ធ្វើអ្វីបានជាមិនរកស្បៀងទុក? "។ រៃឆ្លើយ ៖ " ខ្ញុំរវល់ស្រែកច្រៀងលេងយ៉ាងសប្បាយ "។ ស្រមោចតប ៖ " រៃអើយ ! បើពីដើមអ្នកធ្លាប់ច្រៀងលេង ឥឡូវច្រៀងទៀតទៅ ព្រោះការច្រៀងនាំឱ្យអ្នកឆ្អែត "។ រៃនៅតែទទូចអង្វរស្រមោច ៖ " ឱមិត្តអើយ ! ខ្ញុំអត់បាយស្ទើរដាច់ពោះស្លាប់ទៅហើយ អាណិតចែកស្បៀងឱ្យខ្ញុំខ្ចីបន្តិចមក "។ ស្រមោចឆ្លើយ ៖ " ស្បៀងយើងមានខ្លះដែរ តែទុកល្មមកូនចៅយើង ពុំមានស្បៀងច្រើនចែករំលែកឱ្យអ្នកទេ "។ រៃអស់សង្ឃឹម ក៏ហើរទៅវិញទាំងទុក្ខសោក។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ប្រាំង ខ្ចី សៀ្បង ខ្វល់ខ្វាយ អង្វរ "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ឧស្សាហ៍ រវល់ ច្រើន មាន "។

៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " ទុក្ខ តី "។

### ខ. សំណួរ

១. នៅរដូវប្រាំង តើសត្វស្រមោចនាំគ្នាធ្វើអ្វី ? សត្វរៃនាំគ្នាធ្វើអ្វីដែរ ?

២. តើស្រមោចនិងសត្វរៃ សត្វណាមួយជាសត្វឧស្សាហ៍ ?

៣. ពេលរដូវភ្លៀងធ្លាក់មកដល់ តើសត្វរៃធ្វើដូចម្ដេច ? ព្រោះអ្វី ?

៤. ពេលសត្វរៃទៅរកសុំជំនួយពីសត្វស្រមោច តើសត្វស្រមោចនិយាយរិះគន់ដូចម្ដេចខ្លះ ?

៥. តើព្រឹត្តិការណ៍ណាមួយ ដែលនាំឱ្យរៃអស់សង្ឃឹម ? ចូរស្រង់សេចក្ដីនោះមកបញ្ជាក់។

៦. តើអ្នកយកតំរូសត្វណាមួយ ក្នុងចំណោមសត្វទាំងពីរខាងលើនេះ ? ព្រោះអ្វី ?

៧. ចូរអ្នកបង្ហាញចរិតលក្ខណៈតួអង្គស្រមោច និងតួអង្គរៃ។


www.elibraryofcambodia.org

# កំណែវិញ្ញាសាទី ១

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- ប្រាំង (ន.ឬគុ.) ៖ ឈ្មោះរដូវក្ដៅរាំងឥតទឹកភ្លៀង ឬទាក់ទងដោយរដូវរាំង ឥតមានទឹកភ្លៀង រដូវប្រាំង ខែប្រាំង។ ស្រែប្រាំង ស្រែសម្រាប់ស្ទូងបានតែក្នុងរដូវប្រាំង។
- ខ្ចី (កិ.) ៖ យកពីគេមកប្រើហើយឱ្យទៅវិញ។ *ឧ.* ខ្ចីប្រាក់, ខ្ចីទូក, ខ្ចីចាន ។
- ខ្ចី (គុ.) ៖ ដែលមិនទាន់ចាស់ មិនទាន់ទុំ។ *ឧ.* ចេកខ្ចី ស្វាយខ្ចី។ ពាក្យផ្ទុយចាស់ , ទុំ។
- ស្បៀង (ន.) ៖ គ្រឿងបរិភោគចិញ្ចឹមជីវិតក្នុងការដើរផ្លូវឆ្ងាយ។ ជួនកាលហៅគ្រឿងចិញ្ចឹមជីវិតជាប្រក្រតីថា ស្បៀង ដែរក៏មាន។
- ខ្វល់ខ្វាយ (កិ.) ៖ ខ្នះខ្នែង ស្រវាស្រទេញ។ *ឧ.* ខ្វល់ខ្វាយរកស៊ី ខ្វល់ខ្វាយក្នុងការងារ។
- អង្វរ (ស.)(កិ.)៖ ពោលពាក្យលំអុតទទូចបន្ទន់ចិត្ត ឱ្យអាណិត ឱ្យចុះសម្រុង, ឱ្យយល់ព្រម តាមបំណងរបស់ខ្លួន។ *ឧ.* អង្វរឱ្យយល់ព្រមតាម អង្វរឱ្យលែងប្រកាន់ទោស ។


www.elibraryofcambodia.org

២.បដិសព្ទ

- នស្សាហ៍ ≠ ខ្ជិល
- រវល់ ≠ ទំនេរ
- ច្រើន ≠ តិច
- មាន ≠ ក្រ

៣.សទិសសព្ទ

- ទុក្ខ (ន.) ៖ សេចក្ដីព្រួយ, សេចក្ដីលំបាក (កាយនិងចិត្ត) ។ ឧ. កើតទុក្ខ,មានទុក្ខ។ ពាក្យផ្ទុយ : សុខ។
- ទុក (កិ.) ៖ ដាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឱ្យគង់នៅ ឬរក្សាអ្វីៗឱ្យគង់។ ឧ. ទុកទ្រព្យ។
- ពី (និ. ; អា.និ.) ៖ អំពី ខាង ឯ។ ឧ. មកពីណា ? បានពីណាមក ? មកពីផ្ទះ រួចពីដៃ សម្ដីចេញពីមាត់ ទៅពីព្រឹក ពីមុខ ពីក្រោយ ពីឆ្វេង ពីស្ដាំ ពីលើ ពីក្រោម ។ល។
- ពីរ (ប.សំ.) ៖ មួយគូបន្ទា ពីមួយនិងមួយ (២) ។

## ខ.ចម្លើយ

១. នៅរដូវប្រាំង សត្វស្រមោចនាំគ្នារកស្បៀងទុក។ សត្វរៃនាំគ្នាច្រៀងលេងគ្មានគិតខ្វល់ខ្វាយ រកស្រូវអង្ករទុកឡើយ។

២. ស្រមោចនិងសត្វរៃ សត្វស្រមោចជាសត្វឧស្សាហ៍ ។

៣. ពេលរដូវភ្លៀងធ្លាក់មកដល់ សត្វរៃក៏ហើរទៅខ្ចីស្បៀងពីស្រមោច ព្រោះសត្វរៃពុំមានស្បៀងត្រៀមទុកសម្រាប់បរិភោគនៅរដូវភ្លៀងធ្លាក់។


www.elibraryofcambodia.org

៤. ពេលសត្វរៃទៅរកសុំជំនួយពីសត្វស្រមោច សត្វស្រមោចនិយាយ រិះគន់ថា ៖ " រៃអើយ ! បើពីដើម អ្នកធ្លាប់ច្រៀងលេង ឥឡូវច្រៀងទៀតទៅ ព្រោះការច្រៀងនាំឱ្យអ្នកឆ្អែត " ។

៥. ព្រឹត្តិការណ៍ដែលនាំឱ្យរៃអស់សង្ឃឹម គឺសត្វស្រមោចមិនផ្តល់ស្បៀងឱ្យទៅសត្វរៃ ។ ស្រមោចនិយាយ ៖ " ស្បៀងយើងមានខ្លះដែរ តែទុកល្មមកូនចៅយើងពុំមានស្បៀងច្រើនចែករំលែកឱ្យអ្នកទេ " ។

៦. ខ្ញុំពេញចិត្តយកតំរូតាមសត្វស្រមោច ព្រោះសត្វស្រមោចជាសត្វឧស្សាហ៍ ចេះគិតត្រៀមបម្រុងស្បៀងអាហារនៅពេលខ្វះខាត។

៧. ចរិតលក្ខណៈតួអង្គ ៖

- ស្រមោច ជាសត្វឧស្សាហ៍ព្យាយាម ចេះបម្រុងស្បៀងទុកការពារនៅពេលខ្វះខាត។ តែស្រមោចក៏ជាសត្វដែលមានចិត្តកំណាញ់មិនចេះចែករំលែកដល់អ្នកស្រេកឃ្លានដែរ។
- រៃ ជាសត្វខ្ជិលច្រអូស គិតតែពីការសប្បាយភ្លេចខ្លួន មិនគិតខ្វល់ខ្វាយពីភាពខ្វះខាត។


www.elibraryofcambodia.org

វិញ្ញាសាទី ២

# រឿង កុមារណារិន



ណារិន រស់នៅតាមមាត់ទន្លេ។ ឪពុកណារិន បានបង្ហាត់ណារិនឱ្យចេះហែលទឹកតាំងពីក្មេង។ ណារិន ព្យាយាមហ្វឹកហាត់ហែលទឹកយ៉ាងស្ទាត់ជំនាញ។ ថ្ងៃមួយ មានក្មេងមួយក្រុមកំពុងហ៊ោកញ្ជ្រៀវលេងទឹកទន្លេក្រោយផ្ទះណារិន។ មួយសន្ទុះក្រោយមក ស្រាប់តែឮសំឡេងក្មេងៗស្រែក ៖ " ជួយផង មានអ្នកលង់ទឹកហើយ ! "។ ឮភ្លាមណារិនឆក់បានក្រមាស្ទុះរឹងទៅមាត់ទន្លេ ឃើញក្មេងម្នាក់កំពុងលិចអណ្ដែតៗ។ ណារិនលោតចុះក្នុងទឹក ហែលទៅជិតកុមារនោះ រួចបោះក្រមាឱ្យតោង។ ណារិនហែលអូសរហូតដល់ច្រាំងទើបស្រង់អ្នកលង់ទឹកឡើងគោក។ អ្នកនៅទីនោះ នាំគ្នាជួយសង្គ្រោះអ្នកលង់ទឹក។ អ្នកភូមិសរសើរណារិនគ្រប់ៗគ្នា។



www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ស្ទាត់ ហ្វឹក ហ៊ោ លង់ ច្រាំង សង្គ្រោះ ស្មុះ "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " រស់ អណ្តែត ឮ សរសើរ "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ព្យាយាម "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " កំពុង " ។

### ខ. សំណួរ

១. តើណារិនរស់នៅឯណា? ហើយណារិនមានជំនាញអ្វី ?

២. តើអ្នកណាជាអ្នកបង្ហាត់បង្រៀនជំនាញនេះដល់ណារិន ?

៣. ចូរអ្នករៀបរាប់ពីព្រឹត្តិការណ៍ ដែលណារិនបានជួយសង្គ្រោះក្មេងលង់ទឹក។

៤. តើក្នុងរឿងនេះ ព្រឹត្តិការណ៍ណាដែលសំខាន់ជាងគេ ? ព្រោះអ្វី ?

៥. តើណារិន មានចរិតលក្ខណៈដូចម្តេចខ្លះ ?

៦. ហេតុអ្វីបានជាណារិនបោះក្រមាឱ្យអ្នកលង់ទឹកតោង ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ២

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ស្ទាត់ (កិ.វិ. ឬ គុ.) ៖ ថ្នឹក ជំនាញ ប្រាកដ។ **ឧ.** ចេះស្ទាត់ ចាំស្ទាត់ គំនិតស្ទាត់ ។ ស្ទាត់ស្ទាញ ស្ទាត់ជំនាញ ស្ទាត់ណាស់ ស្ទាត់ជំនាញជាង ។
- ហ្វឹក (ស.) (កិ.) ៖ ហាត់ ហាត់ឱ្យថ្នឹក បង្ហឹក។ **ឧ.** ហ្វឹកខ្លួន ហ្វឹកហាត់ ។
- ហោ (កិ.) ៖ ស្រែកបន្លឺសូរសព្ទ ឮខ្ពស់គ្រលួចស្រួចឡើង ឬស្រែកបន្លឺសូរសព្ទគឹកកងខ្ពស់គ្រលួចស្រួចឡើងព្រមគ្នាយកជ័យ ឬដោយសេចក្ដីរីករាយក្នុងការលេងកំសាន្តសប្បាយជាដើម។ **ឧ.** ហោយកជ័យ ហោសប្បាយ ហោគ្រេវៗ។ ហោកញ្ជ្រៀវ ហោខ្សៀវខ្វារ ។
- លង់ (កិ.) ៖ ជ្រុល ស៊ុន ហួស។ **ឧ.** លង់គំនិត លង់ដៃ លង់សម្ដី ។ លង់ទឹកលិចក្នុងទឹកគ្រដរហែលឡើងពុំរួច។
- ច្រាំង (ន.) ៖ រីមស្ទឹង ទន្លេ សមុទ្រ ...(គួរកុំច្រឡំពាក្យច្រាំងនេះនឹងពាក្យ ព្រាំង) ។
- សង្គ្រោះ (ន.) ៖ ការទំនុកបម្រុង ការជួយឱ្យបានសុខស្រួល ។ **ឧ.** ចិញ្ចឹមរក្សាដោយសង្គ្រោះ ឱ្យប្រាក់ដោយសង្គ្រោះ ។


www.elibraryofcambodia.org

- ស្ទុះ (កិ.) ៖ រត់ឬបោលពេញសន្ទុះ ពេញទំហឹង។
ឧ. ស្ទុះវ៉ៃត។

### ២. បដិសព្ទ

- រស់ ≠ ស្លាប់
- អណ្ដែត ≠ លិច
- ឮ ≠ ថ្លង់
- សរសើរ ≠ បង្អាប់

### ៣. វេវចនសព្ទ

- ព្យាយាម ខំប្រឹង ប្រឹងប្រែង សង្វាត ។

### ៤. សទិសសព្ទ

- កំពុង (គុ.) ៖ ដែលពេញកំពូក កណ្ដាលឡើងមិនរាបស្មើ។ ឧ. ពេញកំពុង, ថ្លាល់កំពុង ។
- កំពុង (និ.) ៖ កាលក្នុង កាលដែលជាប់នៅក្នុងរវាង។ ឧ. កំពុងធ្វើការ កំពុងស៊ី កំពុងនិយាយ ... ។
- កំពង់ (ន.) ៖ ទីកន្លែងនៅមាត់ទឹកដែលជនានុជនចុះឡើងឬចតទូកជាដើម។ ឧ. កំពង់ទូក កំពង់កប៉ាល់ កំពង់ទឹក។ បញ្ចុះកំពង់គឺស៊ី (ព. ប្រ.) ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ណារិន រស់នៅតាមមាត់ទន្លេ ហើយណារិនមានជំនាញខាងហែលទឹក។

២. ជំនាញនេះ ឪពុកណារិនជាអ្នកបង្ហាត់បង្រៀនណារិន។

៣. រៀបរាប់ពីព្រឹត្តិការណ៍ ដែលណារិនបានជួយសង្គ្រោះក្មេងលង់ទឹក ៖

- ក្រោយពីឮសំឡេងក្មេងៗស្រែក ៖ " ជួយផងមានអ្នកលង់ទឹកហើយ ! "។ ណារិន ឆក់បានក្រមាស្នុះទៅមាត់ទន្លេ ឃើញក្មេងម្នាក់កំពុងលិចអណ្តែតៗ។
- ណារិនលោតចុះក្នុងទឹក ហែលទៅជិតកុមារនោះ រួចបោះក្រមាឱ្យតោង។ ណារិនហែលអូសអ្នកលង់ទឹក រហូតដល់ច្រាំង ទើបស្រង់ឡើងគោក។ អ្នកនៅទីនោះ នាំគ្នាធ្វើចលនាជួយសង្គ្រោះកុមារនោះ។ អ្នកភូមិអរគុណ និងសរសើរណារិនគ្រប់ៗគ្នា។

៤. ព្រឹត្តិការណ៍សំខាន់ជាងគេក្នុងរឿងនេះ គឺណារិនបោះក្រមាឱ្យអ្នកលង់ទឹកតោង រួចហែលអូសអ្នកលង់ទឹករហូតដល់ច្រាំង ទើបស្រង់ឡើងគោក។ ព្រឹត្តិការណ៍នេះបង្ហាញពីអំពើល្អ និងភាពឈ្លាសវៃរបស់ណារិន។

៥. ណារិនមានចរិតលក្ខណៈល្អ ចេះជួយសង្គ្រោះអ្នកលង់ទឹកឱ្យរួចផុតពីសេចក្ដីស្លាប់។

៦. ព្រោះបើណារិនទៅចាប់ស្រង់អ្នកលង់ទឹកនោះដោយផ្ទាល់ដៃ នោះណារិននឹងត្រូវអ្នកលង់ទឹកឱបក្រៀកជាប់មិនអាចឱ្យណារិនហែលទឹករួច ហើយអាចគ្រោះថ្នាក់លង់ទឹកទាំងអស់គ្នា។


www.elibraryofcambodia.org

វិញ្ញាសាទី ៣

# រឿង យ៉ារីមើលថែប្អូន



ថ្ងៃមួយ ពេលម្ដាយឪពុកទៅធ្វើការបាត់ យ៉ារីនៅចាំផ្ទះមើលថែប្អូនតូច។ នាងនាំប្អូនលេងបត់ក្រដាសធ្វើជាផ្កា។ នាងបានដាក់ក្រដាស កន្ត្រៃ កាំបិតរាយប៉ាយជុំវិញខ្លួន។ ប្អូនប្រុសនាងរីករាយណាស់។ វាភរចុះឡើងតាមឆក់ដណ្ដើមក្រដាស កាំបិត កន្ត្រៃពីបង។ នៅពេលយ៉ារីមិនបានប្រយ័ត្ន ប្អូននាងឆក់ចាប់ត្រូវមុខកាំបិតមុតដៃហូរឈាមបន្តិច។ ប្អូននាងយំយ៉ាងខ្លាំង។ យ៉ារីភ័យណាស់ ស្ទុះទៅយកអាល់កុល និងសំឡីមកលាងឈាមចេញ រួចយកបង់រុំរបួសឱ្យប្អូន។

ពេលម្ដាយឪពុកនាងត្រឡប់ពីធ្វើការវិញ យ៉ារីនិយាយរឿងនេះប្រាប់ពួកគាត់។ ម្ដាយឪពុកនាងមិនបន្ទោសនាងទេ តែគាត់ណែនាំយ៉ារីដោយពាក្យផ្អែមល្ហែម៖ "កូនដឹងទេ! ការលេងដោយប្រើវត្ថុមានមុខមុតចុងស្រួច


www.elibraryofcambodia.org

ភនាំឱ្យមានគ្រោះថ្នាក់ បើយើងមិនប្រុងប្រយ័ត្ន។ នេះមុតត្រឹមដៃ ចុះបើចុងកាំបិតត្រូវភ្នែកនោះ គ្រោះថ្នាក់កាន់តែធំហើយ។ ថ្ងៃក្រោយ ពេលកូននាំប្អូនលេង កូនគួរជ្រើសរើសល្បែងណាមានសុវត្ថិភាពដូចជាការត្រៀបជាត់ពណ៌ ល្បែងបត់ក្រដាសធ្វើទូក ធ្វើរូបសត្វស្លាបជាដើម ដែលកិច្ចការទាំងនោះមិនចាំបាច់ប្រើកាំបិតកន្ត្រៃ "។ យ៉ារីឆ្លើយ ៖ " ចាសម៉ាក់ ! ខ្ញុំនឹងធ្វើតាមដំបូន្មាននេះ "។

## សិក្សាឈើវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ភយ បន្ទោស ដំបូន្មាន សុវត្ថិភាព ផាត់ "។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " តូច ឪពុក ប្អូន "។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ម្ដាយ "។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ភ បិត "។

### ខ. សំណួរ

១. ពេលម្ដាយមិននៅផ្ទះ តើយ៉ារីត្រូវធ្វើអ្វី ?
២. តើយ៉ារីនាំប្អូនធ្វើអ្វី ?
៣. តើមានរឿងអ្វីកើតឡើង ចំពោះប្អូនប្រុសនាងយ៉ារី ? រឿងនេះបណ្ដាលមកពីអ្វី ?
៤. តើម្ដាយឪពុកនាង ក្រើនរំឭកនាងយ៉ាងដូចម្ដេច ?
៥. តើយ៉ារីមានចរិតលក្ខណៈដូចម្ដេចខ្លះ ?


www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- រាយ (កិ.) ៖ ដាក់អ្វីៗពីសពាសមិនមូលគ្នា ឥតសណ្ដាប់ធ្នាប់។ *ឧ.* រាយអីវ៉ាន់ពេញផ្ទះ ក្មេងរាយសំរាមកញ្ចាំមុខផ្ទះ ។
- រាយ (គុ. ឬ កិ.វិ.) ៖ ដែលរលែកចេញ ដែលមិនមែនជាចង្កោម មិនមែនជាដុំ។ *ឧ.* ប្រាក់រាយ ប្រាក់រាយរងដែលរលែកចេញដោយឡែក (ព. ផ្ទ. ប្រាក់ដុំ) ។
- បន្ទោស (កិ.) ៖ ស្ដីឱ្យដោយគ្រាន់តែប្រាប់ទោសកំហុស ឥតមានជេរវាយ ឬធ្វើទោសអ្វី ។ *ឧ.* ម្ដាយបន្ទោសកូន ។
- ដំបូន្មាន (ន.) ៖ សេចក្ដីទូន្មាន ឱវាទ ពាក្យប្រដៅ ។ *ឧ.* ឱ្យដំបូន្មាន ស្ដាប់ដំបូន្មាន។
- សុវត្ថិភាព (ន.) ៖ ការមានសួស្ដី ការប្រកបដោយសេចក្ដីសុខ។ *ឧ.* បានត្រឡប់មកដល់ស្រុកវិញដោយសុវត្ថិភាព ។ល។
- ផាត់ (កិ.) ៖ លើងត្រីងៀត ឬសាច់ងៀតដែលបុកល្អិតជាមួយនឹងខ្លាញ់ជ្រូក ... ។
- ផាត់ (កិ.) ៖ ទាត់ច្រាន វែកនឹងដៃឱ្យងាក ឱ្យបែរចេញ ឬកៀសកៀរកេចនឹងដៃ។ *ឧ.* ផាត់វ៉ាំងនន ផាត់អង្ករ ។


www.elibraryofcambodia.org

២.បដិសព្ទ

- តូច ≠ ធំ
- ឪពុក ≠ ម្ដាយ
- ប្អូន ≠ បង

៣.វេវចនសព្ទ

- ម្ដាយ ម៉ាក់ ម៉ែ មាតា ញោមស្រី។

៤.សទិសសព្ទ

- វា (បុ. ស.) ៖ គេ ពាក្យសម្រាប់និយាយជាជំនួសឈ្មោះ មនុស្សក្មេងជាង ឬមនុស្សថ្នាក់តូចទាបជាង ឬក៏សត្វតិរច្ឆាន វត្ថុ ធម្មជាតិ ... ផ្សេងៗ ។ *ឧ.* ហាមពួកក្មេងកុំឱ្យវាលេងទឹក កូនខ្ញុំវាឈឺ កូនគោវាយំរកមេវា ការុងវាតូចច្រកអង្ករមិនអស់ គំនិតវារាក់ ។ល។
- វារ (កិ.) ៖ លូនដោយប្រវា។ *ឧ.* កូនតូចទើបចេះវារ ស្រមោចវាររសាវ ។ បោះទងចេញ ឬបោះទងតោងចាប់។ *ឧ.* ល្ពៅវារ ត្រឡាចវារឡើងច្រើង ម្លូវារតាមជន្លង់ ។
- វៀរ (កិ.) ៖ លើកលែង តម ឈប់ខាន អត់មិនធ្វើ។ *ឧ.* វៀរចាកទុច្ចរិត ឈប់មិនកាន់ទុច្ចរិត។ វៀរតែ និ. លើកតែ លើកលែងតែ។ វៀរត្រីសាច់ តមត្រីសាច់ ។ វៀរបង់ លះបង់ លះចោលបង់ ។ វៀរលែង លះលែង លះស្រឡះ។ វៀរលែងតែ និ. លើកលែងតែ។



www.elibraryofcambodia.org

ឧ. ចង់ស៊ីអ៊ីស៊ីចុះ ម៉្យ៉ាងវិញទៀតមិនដឹងថាមានទំពាំង ស្អិតនុំ ទុកប្រគេនលោក ! គេទៅទាំងអស់ គ្នា ល្មៀរលែងតែខ្ញុំ ត្រូវនៅចាំផ្ទះ ។

- បិត (កិ.) ៖ កាន់ទប់ដោយដៃទាំងពីរ កួត ប្រួម សម្រួច ដោយមុខកាំបិតបន្ទោះ ឬកាំបិតឯទៀតក៏ បាន។ ឧ. បិតបន្ទោះ បិតផ្ដៅ បិតឈើស្រួច បិតសម្រួច។ ចំហុយយកញើស ឱ្យស្រក់ចុះ ក្នុងតម្រងឱ្យកើតបានជាសុរា។ ឧ. បិតស្រា។
- បិទ (កិ.) ៖ ខ្ទប់ រាំង ធ្វើឱ្យជិត។ ឧ. បិទទ្វារ បិទផ្លូវ ។ ដាក់ផ្អិតភ្ជាប់ , ទឹប។ ឧ. បិតមាស ។

## ខ. ចម្លើយ

១. ពេលម្ដាយមិននៅផ្ទះ យ៉ារីនៅចាំផ្ទះមើលថែប្អូនតូច។

២. យ៉ារីនាំប្អូនលេង ដោយបត់ក្រដាសធ្វើជាផ្កា។

៣. រឿងដែលកើតឡើងចំពោះប្អូនប្រុសនាងយ៉ារី គឺប្អូននាងឆក់ចាប់ ត្រូវមុខកាំបិតមុតដៃក៏ហូរឈាមបន្តិច។ រឿងនេះបណ្ដាលមកពី នាងយ៉ារីមិនប្រយ័ត្ន ដោយនាងបានដាក់ក្រដាស កន្ត្រៃ កាំបិត រាយប៉ាយជុំវិញខ្លួន។

៤. ម្ដាយឪពុកនាងក្រើនរំឭកនាងថា ថ្ងៃក្រោយ ពេលកូននាំប្អូនលេង កូនគួរជ្រើសរើសល្បែងណាមានសុវត្ថិភាពដូចជា ការគូររូបផាត់ ពណ៌ បត់ក្រដាសធ្វើវត្ថុផ្សេងៗដែលមិនប្រើកាំបិត កន្ត្រៃ ម្ជុល។

៥. យ៉ារីជាបងស្រីដ៏ល្អ ចេះមើលថែប្អូនប្រុស នាំប្អូនលេងនៅពេល ម្ដាយឪពុកទៅធ្វើការ។ប៉ុន្តែនាងមានការធ្វេសប្រហែសមិនយក ល្បែងដែលមានសុវត្ថិភាពមកឱ្យប្អូនលេងទេ។


www.elibraryofcambodia.org

វិញ្ញាសាទី ៤

# រឿង គោនិងហ៊ីង



មានសត្វគោមួយ បានចុះទៅផឹកទឹកត្រពាំង។ កូនហ៊ីងឃើញក៏ស្រែកហាម ៖ " ឈប់សិន ! ឯងមិនត្រូវមកផឹកទឹកនៅទីនេះទេ ព្រោះជាត្រពាំងរបស់ខ្ញុំ "។ គោឆ្លើយតប ៖ " យើ ! អាច្រមក់ ឯងចេះដឹងអី ប្រយ័ត្នយើងជាន់ស្លាប់ណា៎ ! "។ កូនហ៊ីង ឮដូច្នេះក៏រត់ប្រាប់មេវា ៖ " ម៉ែ ! ម៉ែ ! មានអ្វីធំណាស់ ! វាមកផឹកទឹកត្រពាំងយើងហើយ គំរាមជាន់កូនឱ្យស្លាប់ទៀតផង "។ មេហ៊ីងសួរកូន ៖ " តើវាធំប៉ុនណា ? "។ មេហ៊ីងខំប៉ប៉ោងខ្លួនធំ រួចសួរកូន ៖ " តើវាធំប៉ុននេះមែនទេ ? "។ កូនហ៊ីងឆ្លើយ ៖ " ទេ ! ទេ ! វាធំជាងនេះឆ្ងាយណាស់ "។ មេហ៊ីងខំប៉ប៉ោងខ្លួនឱ្យធំជាងមុនទៀត រួចសួរកូន ៖ " តើវាធំប៉ុននេះមែនទេ ? "។ កូនហ៊ីងឆ្លើយ ៖ " ទេ ! វាធំជាងនេះទៅទៀត "។ មេហ៊ីង ខំប៉ប៉ោងខ្លួនឱ្យធំថែមទៀត រហូតដល់បែករយះខ្លួន ហើយក៏ស្លាប់ទៅ។


www.elibraryofcambodia.org

## សិក្សាលើមេរៀនទី ៤

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ជាន់ ត្រពាំង មេ តំរាម ស្រែក ហាម "។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " ឆ្ងាយ ស្លាប់ ចុះ ប្រយ័ត្ន "។
៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " សួរ "។
៤. ដូចម្ដេចដែលហៅថានាមសាធារណ៍ ? ចូរស្រង់នាមសាធារណ៍នៅក្នុងរឿងខាងលើនេះឱ្យបានចំនួន៥ពាក្យ។

### ខ. សំណួរ

១. ពេលសត្វគោចុះផឹកទឹកត្រពាំង តើកូនហ៊ឹងធ្វើដូចម្ដេច ?
២. តើសត្វគោ ថាដូចម្ដេចខ្លះចំពោះកូនហ៊ឹង ?
៣. តើសម្ដីសត្វគោ ទៅលើសត្វហ៊ឹងត្រូវឬទេ ? ហេតុអ្វី ?
៤. តើសត្វហ៊ឹង និងសត្វគោ មានចរិតលក្ខណៈដូចម្ដេចខ្លះ ?
៥. តើរឿងនេះមានព្រឹត្តិការណ៍អ្វីខ្លះ ?
៦. ចូរអ្នកប៉ាន់ស្មានមើលថា តើមេហ៊ឹងអាចបញ្ឈប់ការបំប៉ោងខ្លួនឬទេ? ព្រោះអ្វី?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ជាន់ (កិ.) ៖ ដាក់ជើងសង្កត់សិប់ពីលើ។ គ្រួតគ្រាលើ។ ឧ. ជាន់ស្រុក, ជាន់ខេត្ត។ ឡើងពានលើ ឡើងទំពីលើចឹកជាប់ ធ្វើសន្ទវកិច្ច (ប្រើសម្រាប់សត្វតិរច្ឆាន) ។ ថ្ងៃជាន់ ថ្ងៃចាំងត្រូវកំពុងដេកលក់ ។
- ជាន់ (ន.) ៖ ថ្នាក់ : ផ្ទះពីរជាន់ ។ ដែលត្រួតលើគ្នា ។ ឧ. សំពត់ពីរជាន់ ។ កាល សម័យ គ្រា។ ជាន់នេះមិនដូចជាន់ពីដើមទេ ។
- ត្រពាំង (ន.) ៖ ថ្លុកធំកើតពីមនុស្សជីកសម្រាប់ដក់ទឹក ឬកើតដោយសារកម្លាំងទឹកហូរច្រោះក៏មាន។
- មេ (ន.) ៖ ម្ដាយ (ចំពោះតែសត្វតិរច្ឆាន)។ ឧ. មេក្របី មេគោ មេមាន់ មេសេះ ...។
- គំរាម (កិ.) ៖ កំហែង។ ឧ. គំរាមឱ្យខ្លាច។
- គំរាម (គុ. ឬ កិ. វិ.)៖ ដែលកំហែងឱ្យខ្លាច។ ឧ. សម្ដីគំរាម និយាយគំរាម ស្រែកសន្ធាប់គំរាម ។
- ស្រែក (កិ.) ៖ បញ្ចេញសម្រែក។ ឧ. ស្រែកច្រៀង ស្រែកបទ ស្រែកយំ ស្រែកសួរ ស្រែកហៅ។


www.elibraryofcambodia.org

- ហាម (កិ.) ៖ ប្រាម ឃាត់។ ឧ. ហាមមិនឱ្យចូល ហាមពួកក្មេងមិនឱ្យមាត់។ ហាមឃាត់ ឃាត់យ៉ាងតឹងតែង ។ ហាមប្រាម ប្រាមប្រាប់ ឬប្រាប់ប្រាម ឃាត់ដោយមានបម្រាម ។

ហាម (ន.) ៖ រឹម (ចំពោះតែវត្ថុរឹងដែលមានកម្រាស់តិច)។ ឧ. ហាមថាស ហាមតុ ។

២.បដិសព្ទ

- ឆ្ងាយ ≠ ជិត
- ស្លាប់ ≠ រស់
- ចុះ ≠ ឡើង
- ប្រយ័ត្ន ≠ ប្រហែស

៣.សទិសសព្ទ

- សួរ (កិ.) ៖ ពោលពាក្យឆ្ពោះទៅរកអ្នកដទៃឱ្យគេឆ្លើយតបឱ្យគេប្រាប់។ ឧ. សួរដំណឹង សួរឱ្យដឹងការណ៍ ។ សួរនាំ សួរឱ្យណែនាំ ។ សួរមាត់សួរពាក្យ សួរបញ្ជាក់ឱ្យដឹងថាបាននិយាយមែនឬទេ ?
- សូ (កិ.) ៖ ដើរលើស្នួឬលើអ្វីៗដែលមានគ្រៀងគោងផង។ ឧ. សូស្ពានឫស្សី សូស្នួ សូមែកឈើ។ សូព្រ័ត្រ កាន់សំណុំកន្ទុយក្ងោករាំដើរសូលើព្រ័ត្រចងខ្វែង។ ឧ. ល្បែងសូព្រ័ត្រ ។

៤. ដែលហៅថានាមសាធារណ៍ គឺជានាមសម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង វត្ថុ ទូទៅ មិនចំពោះ។

ស្រង់នាមសាធារណ៍នៅក្នុងរឿង ឱ្យបានចំនួន៥ពាក្យ ៖ ហ៊ឹង គោ កូន មេ ត្រពាំង។

## ខ. ចម្លើយ

១. ពេលសត្វគោចុះផឹកទឹកត្រពាំង កូនហ៊ឹងស្រែកហាម ៖" ឈប់សិន ! ឯងមិនត្រូវមកផឹកទឹកនៅទីនេះទេ ព្រោះជាត្រពាំងរបស់ខ្ញុំ "។

២. សត្វគោ ៖ " យើ ! អាច្រមក់ ឯងចេះដឹងអី ប្រយ័ត្នយើងជាន់ស្លាប់ណា ! "។

៣. សម្ដីសត្វគោ ពោលទៅកាន់សត្វហ៊ឹងពិតជាត្រូវ ដោយហេតុថាសត្វគោមានមានធំជាងសត្វហ៊ឹងរាប់សិបដង រីឯសត្វហ៊ឹងមានទំហំតូចជាងសត្វគោខ្លាំងណាស់។

៤. សត្វហ៊ឹង ជាសត្វមានអំនួត មិនចេះប្រមាណមានខ្លួន។
សត្វគោ ជាសត្វអាងមានខ្លួនធំ គំរាមនិងប្រមាថកូនហ៊ឹង។

៥. រឿងនេះមានព្រឹត្តិការណ៍ ៖

- កូនហ៊ឹងគំរាមសត្វគោ មិនឱ្យចុះផឹកទឹកត្រពាំង។
- សត្វគោគំរាមសត្វហ៊ឹង។
- មេហ៊ឹងខំប៉ប៉ោងខ្លួនឱ្យធំ ដើម្បីឱ្យសត្វគោញញើត។

៦. តាមការប៉ាន់ស្មាន មេហ៊ឹងមិនអាចបញ្ឈប់ការប៉ប៉ោងខ្លួនទេ ព្រោះមេហ៊ឹងកំពុងតែមានអំនួត។


www.elibraryofcambodia.org

វិញ្ញាសាទី ៥

# កីឡានិងល្បែងមានសុវត្ថិភាព



កុមារចូលចិត្តលេងល្បែងកំសាន្តផ្សេងៗ ជារៀងរាល់ថ្ងៃ។ ល្បែងកំសាន្តខ្លះ នាំមកនូវភាពសប្បាយរីករាយ សាមគ្គីភាព ការល្អតលាស់ផ្នែកប្រាជ្ញាជាដើម តែល្បែងកំសាន្តខ្លះទៀត អាចនាំឱ្យអន្តរាយដល់ខ្លួន និងបង្កការលំបាកដល់ឪពុកម្តាយទៀតផង។

ល្បែងកំសាន្តខ្លះដូចជាការលេងទឹក ការឡើងដើមឈើ ការលេងគ្រាប់មិនទាន់ផ្ទុះ និងគ្រឿងផ្ទុះ អាចធ្វើឱ្យអ្នករបួស ពិការ ឬបាត់បង់ជីវិត។ ចំណែកការលេងបាល់ទាត់តាមទីសាធារណៈ ពិសេសតាមចិញ្ចើមផ្លូវ អាចនាំឱ្យខ្លួនអ្នកមានគ្រោះថ្នាក់ និងអាចបង្កគ្រោះមហន្តរាយដល់អ្នកដទៃផងដែរ។ ល្បែងកំសាន្តខ្លះ ផ្តល់អត្ថប្រយោជន៍ច្រើនណាស់។ ការលេងកីឡាបាល់ទាត់ បាល់ទះ បាល់បោះ វាយសី លោតអន្ទាក់ ហាត់


www.elibraryofcambodia.org

ប្រាណអាចធ្វើឱ្យអ្នកលេងមានសុខភាពល្អ។ ប៉ុន្តែការលេងកីឡា គប្បីរកកន្លែងសមរម្យទើបមានសុវត្ថិភាព រីឯការកំសាន្តខ្លះទៀត ដូចជាការលេងអុក លេងវែក និងខ្លាឃ្មុំគោធ្វើឱ្យសប្បាយរីករាយផង លូតលាស់ផ្នែកប្រាជ្ញាផង ព្រោះអ្នកលេងខំគិតត្រិះរិះពិចារណារកវិធីលេង ដើម្បីយកជ័យជម្នះលើដៃគូ។

សិស្សានុសិស្សគ្រប់រូប គប្បីខិតខំសិក្សា និងលេងកីឡាដើម្បីទទួលបានចំណេះវិជ្ជា សុខភាព និងប្រាជ្ញាស្មារតីភ្លឺថ្លា។

## សិក្សាលើទិញ្ញាសាទី ៥

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖
" កំសាន្ត សាមគ្គី សុខភាព សមរម្យ សិស្សានុសិស្ស ប្រាជ្ញា "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ជ័យជម្នះ លំបាក " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " អន្តរាយ សិក្សា " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " មាន អ្នក "។

៥. ចូរស្រង់នាមសាធារណ៍ពីក្នុងអត្ថបទខាងលើនេះចំនួនប្រាំពាក្យ។

### ខ. សំណួរ

១. តើល្បែងកំសាន្តណាខ្លះ ដែលនាំមកនូវភាពរីករាយ សាមគ្គីភាព ?

២. តើល្បែងណាខ្លះដែលនាំឱ្យអន្តរាយ និងបង្កការលំបាកដល់ឪពុកម្ដាយ ?

៣. តើល្បែងកំសាន្ត បានផ្ដល់អត្ថប្រយោជន៍យ៉ាងណាខ្លះ ?

៤. តើល្បែងកំសាន្តណាខ្លះ ដែលនាំឱ្យប្រាជ្ញាលូតលាស់ ? ព្រោះអ្វី ?


www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ៥

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កំសាន្ត (កិ.) ៖ សម្រាកចិត្ត ធ្វើឱ្យក្សាន្តចិត្ត លំហើយចិត្ត ធ្វើចិត្តឱ្យស្រាកស្រាន្ត ឱ្យស្បើយចាកអារម្មណ៍ផ្សេងៗ។
  *ឧ.* ដើរលេងកម្សាន្តចិត្ត។
- សាមគ្គី (ន.) ៖ សេចក្តីព្រមព្រៀង សេចក្តីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា។
  *ឧ.* សាមគ្គីជាគុណសម្បត្តិដ៏សំខាន់មួយរបស់សត្វលោក ។
- សុខភាព (ន.) ៖ ភាពជាសុខ សេចក្តីសុខ ។
- សមរម្យ (គុ. ឬកិ.វិ.) ៖ ដែលត្រូវបែប ត្រូវយ៉ាង មិនទាស់ភ្នែក។
  *ឧ.* ស្លៀកពាក់សមរម្យ ។
- សិស្សានុសិស្ស (ន.) ៖ សិស្សនិងសិស្សបន្ទាប់ គឺសិស្សនៃសិស្ស សិស្សតូចនិងសិស្សធំ ឬ សិស្សផ្ទាល់និងចៅសិស្ស ។
  *ឧ.* ពួកសិស្សានុសិស្ស ។
- ប្រាជ្ញា (ន.) ៖ មានប្រាជ្ញ ឥតប្រាជ្ញា ។ ប្រាជ្ញាញាណ ប្រាជ្ញានិងញាណ ឬញាណដែលអាស្រ័យនឹងប្រាជ្ញា ការយល់ជាក់ច្បាស់។


www.elibraryofcambodia.org

២.បដិសព្ទ

- ជ័យជម្នះ ≠ បរាជ័យ
- លំបាក ≠ ស្រណុក ស្រួល

៣.វេវចនសព្ទ

- អន្តរាយ វិនាស បាត់បង់ សូន្យបង់ ខូចប្រយោជន៍
- សិក្សា ការរៀន ការសូត្ររៀន ការហ្វឹក ការហ្វឹកហាត់ ការស្វាធ្យាយ សិក្ខា ។

៤. សមិសសព្ទ

- មាន (កិ.) ៖ បាន គប ប្រកបដោយ កើត បរិបូរដោយ គង់នៅ ឋិតនៅ។
- មៀន (ន.) ៖ ចង្កឹះវែងស្រោបគល់ដងកាំបិត ឬផ្ទាក់ជាដើមឱ្យជាប់មាំគ្រង់អន្សា។ ឧ. មៀនកាំបិត។
- មៀន (ន.) ៖ ឈ្មោះឈើមួយប្រភេទ ជាដំណាំស្រុកផ្លែមូលៗ ទំហំខ្នាតមេដៃ វេលាទុំមានក្លិនសាច់ក្រអូប មានរសផ្អែម ប្រើជាបង្អែម។
- អ្នក (បុ.ស.) ៖ ឈ្មោះបុគ្គលដែលត្រូវនិយាយទៅរកក្នុងទីចំពោះមុខ សម្រាប់ប្រជាពលរដ្ឋហៅគ្នាដោយសេចក្ដីគួរសម មិនចេញឈ្មោះបុគ្គលនោះ (ប្រើបានទាំងបុរសទាំងស្ត្រី)។ ឧ. អ្នកអញ្ជើញទៅណា ? អញ្ជើញអ្នកចូលអង្គុយលេងសិន ! អ្នកស្រីសុខសប្បាយទេឬ ? ។ សាធារណជនហៅបងថ្លៃក៏ប្រើពាក្យ អ្នក ដែរ ។


www.elibraryofcambodia.org

- នាក់ ៖ (សំខ្យានុគ្រោះ) ពាក្យសម្រាប់ប្រើដាក់ខាងចុងសំខ្យា ដើម្បីឱ្យដឹងចំនួនមនុស្ស។ *ឧ.* ប្រុសមួយនាក់ ស្រីពីរនាក់ ក្នុងផ្ទះនេះមានមនុស្សប៉ុន្មាននាក់ ?

៥. ស្រង់នាមសាធារណ៍ពីក្នុងអត្ថបទខាងលើនេះចំនួនប្រាំពាក្យ ៖
កុមារ ឪពុក ម្ដាយ បាល់ សី។

## ខ.ចម្លើយ

១. ល្បែងកំសាន្ត ដែលនាំមកនូវភាពរីករាយ សាមគ្គីភាពមានល្បែងកីឡាបាល់ទាត់ បាល់ទះ បាល់បោះ វាយសី លោតអន្ទាក់។

២. ល្បែងដែលនាំឱ្យអន្តរាយ និងបង្កការលំបាកដល់ឪពុកម្ដាយមានការលេងទឹក ការឡើងដើមឈើ ការលេងគ្រាប់មិនទាន់ផ្ទុះ និងគ្រឿងផ្ទុះ អាចធ្វើឱ្យរបួស ពិការ ឬបាត់បង់ជីវិត។

៣. ល្បែងកំសាន្ត បានផ្ដល់អត្ថប្រយោជន៍ដូចជា ៖
- សុខភាពល្អ
- សាមគ្គីភាព

៤. ល្បែងកំសាន្ត ដែលនាំឱ្យលូតលាស់ប្រាជ្ញាមានការលេងអុក លេងវែក និងខ្លាស៊ីគោ... ព្រោះធ្វើឱ្យសប្បាយរីករាយផង លូតលាស់ផ្នែកប្រាជ្ញាផង។ អ្នកលេងត្រូវខំគិតត្រិះរិះពិចារណារកវិធីលេង ដើម្បីយកជ័យជម្នះលើដៃគូ។


www.elibraryofcambodia.org

វិញ្ញាសាទី ៦

# រឿង ជ័យជម្នះរបស់តុលា



តុលាជាសិស្សថ្នាក់ទី៤។ តុលា មានរាងធាត់កន្ទ្រល ក្បាលពោះសុទ្ធតែខ្លាញ់ ភ្នែកលិប ដំណើរអឹកអ៊ាកៗ។

ថ្ងៃមួយ សាលាមានកម្មវិធីប្រកួតរត់ប្រណាំង ចម្ងាយ១០០ម៉ែត្រ។ សិស្សជាច្រើនរត់យ៉ាងលឿនដល់ទី តាមពេលវេលាកំណត់។ ចំណែកតុលាវិញរត់អឹកអ៊ាកៗក្រោយគេ មិនទាន់ទាំងបាន៥០ម៉ែត្រផងហត់តយូសទៅមុខលែងរួច ដកដង្ហើមតាមមាត់និយាយលែងរួច ដាក់ត្ងទអង្គុយចុះ។ តុលាខ្មាសគេណាស់។ អ្នកគ្រូឃើញដូច្នេះ ក៏ហៅតុលាមកណែនាំ ៖ " ប្អូនត្រូវហាត់ប្រាណ លេងកីឡា ហាត់រត់ឱ្យបានទៀងទាត់ "។ តុលាធ្វើតាមដំបូន្មានអ្នកគ្រូជាប្រចាំ។ មិនយូរប៉ុន្មាន តុលាស្រកក្បាលពោះ ហើយស្រាលខ្លួនជាងមុន។ វាអាចរត់ លោត លេងកីឡាដោយមិនងឿយហត់។


www.elibraryofcambodia.org

ថ្ងៃរត់ប្រណាំងលើកទី២ មកដល់ជាថ្មី។ ម្តងនេះ តុលារត់យ៉ាងលឿនស្ទុះដល់ទីមុនគេ។ អ្នកឈរមើលធ្វើភ្នែកស្លឹងដោយនឹកស្មានមិនដល់។ បន្តិចមក ទើបគេនាំគ្នាទះដៃប្រាវអបអរសាទរ។ សិស្សទាំងអស់សរសើរតុលាគ្រប់ៗគ្នា។

## សិក្សាលើវិញ្ញាសាទី ៦

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖

" កន្ទ្រួល អឹកអាក់ ប្រកួត គយូស នឿយ ស្លឹ ប្រាវ "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ធាត់ លឿន ស្រាល សរសើរ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ទូន្មាន "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " តូច "។

៥. ចូរស្រង់នាមសាធារណ៍ពីក្នុងអត្ថបទខាងលើនេះចំនួនប្រាំពាក្យ ។

### ខ. សំណួរ

១. តើតុលាមានរាងយ៉ាងដូចម្តេច ?

២. តើតុលារត់ប្រណាំងឈ្នះគេឬទេ ? ហេតុអ្វី ?

៣. តើសិស្សទាំងនោះ រត់ដល់ទីតាមពេលកំណត់ឬទេ ?

៤. តើអ្នកគ្រូ ហៅតុលាមកណែនាំយ៉ាងដូចម្តេច ?

៥. តើតុលាធ្វើតាមដំបូន្មានអ្នកគ្រូដែរឬទេ ? ហើយបានទទួលលទ្ធផលដូចម្តេចខ្លះ ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៦

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កន្ទ្រល (គុ.) ៖ រលេ ននលមិនសមរម្យ។ ឧ. រាងកន្ទ្រល ។
- អឹកអាក (គុ. ឬកិ.វិ.) ៖ ដែលដើរយោលខ្លួនចីកងាកៗ ឃ្លោងៗ ទៅឆ្វេងទៅស្តាំ (ព្រោះធ្ងន់ខ្លួន ឬធ្ងន់ពោះ)។ ឧ. ដំណើរអឹកអាកៗ , ដើរអឹកអាកៗ ។
- ប្រកួត (កិ.) ៖ ប្រឡងគ្នា ដោយតំនំ ដោយកំហឹង ឬដោយចង់បានជម្នះ។ ឧ. ប្រកួតកីឡាបាល់ទាត់។
- គឃុស (ន.) ៖ សូរឮឃុសៗ ច្រើនដង ។
- នឿយ (កិ.) ៖ ព្រួយកាយឬចិត្តដោយធ្វើការធ្ងន់ ឬដោយធ្វើការឥតស្រាក ដោយដើរផ្លូវឆ្ងាយ ។
- ស្លី (គុ.) ៖ ដែលបញ្ឈរស្លឹងងើប ឬងើយទៅលើ។ ឧ. ធ្វើភ្នែកស្លី , ភ្នែកស្លី។
- ប្រាវ (ន.) ៖ សូរឮដោយកាច់ ជាន់ សង្កត់អ្វីៗដែលស្ងួតស្រួយ ឬវត្ថុនោះបាក់ ធ្លាក់ ជាដើម ។

២. បដិសព្ទ

- ធាត់ ≠ ស្គម
- លឿន ≠ យឺត
- ស្រាល ≠ ធ្ងន់
- សរសើរ ≠ បន្ទាប់

៣. វេវចនសព្ទ

- ទុន្មាន ដំបូន្មាន ឱវាទ ប្រៀនប្រដៅ។


www.elibraryofcambodia.org

៤. សទិសសព្ទ

- គូទ (ន.) ៖ អវយវៈត្រង់ចំណែកកាយខាងក្រោយជិតវច្ចទ្វារ។ *ឧ.* ដាក់គូទអង្គុយ។ ប៉ែកអវយវៈនេះ បុរាណពីដើមហៅថា គពោក ឬត្រពោក សូម្បីសព្វថ្ងៃនេះអ្នកបាត់ដំបង អ្នកសៀមរាបជាដើម ក៏នៅប្រើពាក្យនេះដែរ។ *ឧ.* ដាក់គពោកអង្គុយ។
- គូថ (ន.) ៖ អាចម៍ ឧច្ចារៈ លាមក ។ *ឧ.* អង្គុយបន្ទោគូថក្នុងបង្គន់។

៥. ស្រង់នាមសាធារណ៍ពីក្នុងអត្ថបទខាងលើនេះចំនួនប្រាំពាក្យ ៖ សិស្ស សាលា គ្រូ ក្បាល ជង្គើម។

## ខ. ចម្លើយ

១. តុលាមានរាងធាត់កន្ទ្រល ក្បាលពោះសុទ្ធតែខ្លាញ់ ភ្នែកលឹប ដំណើរអឹកអាកៗ។

២. តុលារត់ប្រណាំងមិនឈ្នះគេទេ មកពីវាធាត់មានក្បាលពោះសុទ្ធតែខ្លាញ់ រត់អឹកអាកៗក្រោយគេ មិនទាន់ទាំងបាន៥០ម៉ែត្រផងក៏ហត់ទៅហើយ។

៣. សិស្សទាំងអស់ រត់យ៉ាងលឿនដល់ទីតាមពេលវេលាកំណត់។

៤. អ្នកគ្រូហៅតុលាមកណែនាំថា " ប្អូនត្រូវហាត់ប្រាណ លេងកីឡាហាត់រត់ឱ្យបានទៀងទាត់ "។

៥. តុលាបានធ្វើតាមដំបូន្មានអ្នកគ្រូ ដែលបានណែនាំជាប្រចាំ ហើយបានទទួលលទ្ធផលល្អ គឺតុលាស្រកក្បាលពោះ ហើយស្រាលខ្លួនជាងមុន ហើយរត់លឿនជាងគេទៀតផង។


www.elibraryofcambodia.org

វិញ្ញាសាទី ៧

# រឿង ក្មេងសុចរិត



នៅពេលខ្ញុំកំពុងអង្គុយហូបគុយទាវ ស្រាប់តែមានក្មេងប្រុសម្នាក់អង្វរខ្ញុំឱ្យជួយទិញកាសែត។ ពេលនោះ ខ្ញុំមានក្រដាសប្រាក់ប្រាំម៉ឺនរៀល។ ក្មេងនោះអង្វរខ្ញុំថា ចាំវាយកទៅដូរគេ ហើយវាយកមកឱ្យខ្ញុំវិញ។ ខ្ញុំក៏ឱ្យប្រាក់នោះទៅវា។ ខ្ញុំចាំវាយូរពេកមិនឃើញវាមកវិញ ខ្ញុំគិតថាក្មេងនោះប្រាកដជាបោកប្រាស់ខ្ញុំ។ ខ្ញុំក៏ធ្វើដំណើរទៅធ្វើការ។

មួយអាទិត្យក្រោយមក នៅពេលដែលខ្ញុំដើរចូលហាងគុយទាវដដែល ខ្ញុំបានឃើញក្មេងពីថ្ងៃមុនមកឈរចាំខ្ញុំ។ ពេលឃើញខ្ញុំ វាដើរមកជិត ហើយហុចលុយឱ្យខ្ញុំគ្រប់ចំនួន។ ខ្ញុំសួរវា ៖ " ហេតុអ្វីបានជាថ្ងៃមុនឯងគេចពីខ្ញុំ ? "។ វាឆ្លើយដោយទឹកមុខស្រងូត ៖ " ខ្ញុំបាទត្រូវម៉ូតូបុក ទើបមិនបានយកប្រាក់មកជូនលោកពូវិញ។ ពេលនេះ ខ្ញុំបានធូរស្រាលក៏យកមក


www.elibraryofcambodia.org

ជូនលោកឲ្យវិញ "។ ខ្ញុំពិនិត្យមើលជើងវាឃើញមានរបួសមែន។ ខ្ញុំក៏ឈប់សង្ស័យចំពោះក្មេងនោះទៅ។ វាបានសុំទោសខ្ញុំ ហើយធ្វើដំណើរទៅលក់កាសែតបន្តទៀត។

## សិក្សាឈើទិញ្ញាសាទី ៧

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖

" តុយទាវ អង្វរ កាសែត ដូរ គេច ស្រងូត សង្ស័យ "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ទៅ ជិត ធូរ "។

៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " វា "។

### ខ. សំណួរ

១. តើបុរសនោះបានហូបតុយទាវនៅពេលណា ? ទីកន្លែងណា ? ហើយមានព្រឹត្តិការណ៍អ្វីកើតឡើង ?

២. តើមានហេតុការណ៍អ្វីដែរ ចំពោះក្មេងប្រុសនោះ ?

៣. តើបុរសនោះយល់ឃើញយ៉ាងដូចម្ដេចទៅ ចំពោះក្មេងប្រុសនោះ ?

៤. ចូរប្រាប់ពីភាពអាកាសដែលបុរសនោះ បានជួបក្មេងប្រុសនោះ ជាលើកទីពីរ។ តើបុរសនោះជឿសម្ដីក្មេងប្រុសនោះឬទេ ? ហេតុអ្វី ?

៥. ចូរអ្នកបង្ហាញចរិតលក្ខណៈតួអង្គបុរស និងក្មេងប្រុស។


www.elibraryofcambodia.org

## អំណានទី ៧

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- គុយទាវ (ន.) ៖ ឈ្មោះម្ហូបចិនម្យ៉ាងធ្វើដោយសរសៃម្សៅ ឱ្យវាយដែលហាន់ ស្រុះលាយនឹងសាច់ចិញ្ច្រាំ ផ្សំនឹងគ្រឿងផ្សេងៗ។ សរសៃម្សៅហាន់នោះ ក៏ហៅ គុយទាវដែរ ។
- អង្វរ (កិ.) ៖ ពោលពាក្យលំអុតទទូចបន្ទន់ចិត្ត ឱ្យអាណិត ឱ្យចុះសម្រុង ឱ្យយល់ព្រម តាមបំណងរបស់ខ្លួន។ **ឧ.** អង្វរឱ្យយល់ព្រមតាម អង្វរឱ្យលែងប្រកាន់ទោស ។ អង្វរចិត្ត សូមឱ្យចិត្តតាម ។
- កាសែត (ន.) ៖ សារព័ត៌មាន សេចក្តីផ្សាយដំណឹងផ្សេងៗ។ **ឧ.** អានកាសែត រឿងក្នុងកាសែត។
- ដូរ (កិ.) ៖ ប្តូររបស់ ឱ្យរបស់ទៅវិញទៅមកដោយទុកតម្លៃជាស្មើគ្នា។ **ឧ.** ដូរគោ,ដឹកឌីឡើកទៅដូរស្រូវ។
- គេច (កិ.) ៖ ជៀសវាង។ **ឧ.** គេចចុះគេចឡើង ទាហានទៅខាងឆ្វេង ចោរគេចទៅខាងស្តាំ ។
- ស្រងូត (គុ.) ៖ ដែលស្រពោនស្រពាប់មិនស្រស់បស់ (ចំពោះតែទឹកមុខ)។ **ឧ.** កើតទុក្ខមុខស្រងូត។ ស្រងូតស្រងាត់ ស្រងូតស្ងៀមស្ងាត់ សញ្ជប់សញ្ជឹង គួរឱ្យអាណិត ។


www.elibraryofcambodia.org

- សង្ស័យ (ន.) ៖ សេចក្ដីឆ្ងល់ ដំណើរងឿងឆ្ងល់ ដំណើរមិនអស់មិនហើយក្នុងចិត្ត។ *ឧ.* មានសង្ស័យ អស់សង្ស័យ។ ខ្មែរប្រើជា កិ. ផងក៏បាន " ឆ្ងល់ ងឿងឆ្ងល់ មិនអស់មិនហើយក្នុងចិត្ត "។ *ឧ.* ខ្ញុំសង្ស័យណាស់ កុំសង្ស័យឡើយ ។

## ២.បដិសព្ទ

- ទៅ ≠ មក
- ជិត ≠ ឆ្ងាយ
- ធូរ ≠ តឹង

## ៣.សទិសសព្ទ

- វា (បុ.ស.) ៖ គេ ពាក្យសម្រាប់និយាយជាជំនួសឈ្មោះមនុស្សក្មេងជាង ឬមនុស្សថ្នាក់តូចទាបជាង ឬក៏សត្តិរច្ឆាន វត្ថុ ធម្មជាតិ ...ផ្សេងៗ ។ *ឧ.* ហាមពួកក្មេងកុំឱ្យវាលេងទឹក កូនខ្ញុំឈឺ កូនគោយំរកមេវា។
- វារ (កិ.) ៖ លូនដោយប្រវា។ *ឧ.* កូនតូចទើបចេះវារ ស្រមោចវារសោរ ។ បោះទងចេញ ឬ បោះទងតោងចាប់។ *ឧ.* ល្ពៅវារ ត្រឡាចវារឡើងច្រើងម្លូវារតាមជន្លង់ ។
- វៀរ (កិ.) ៖ លើកលែង តម ឈប់ខាន អត់មិនធ្វើ។ *ឧ.* វៀរចាកទុច្ចរិត ឈប់មិនកាន់ទុច្ចរិត ។


www.elibraryofcambodia.org

ខ. ចម្លើយ

១. បុរសនោះបានហូបគុយទាវនៅពេលព្រឹកមួយ។

- ទីកន្លែង នៅហាងមួយ
- ព្រឹត្តិការណ៍ គឺក្មេងប្រុសអង្វរបុរសនោះឱ្យជួយទិញកាសែត។

២. ហេតុការណ៍ដែលកើតមានចំពោះក្មេងប្រុសនោះ គឺក្រោយពីយកក្រដាសប្រាក់ទៅដូរក៏ត្រូវម៉ូតូបុក ។

៣. បុរសនោះគិតថា ក្មេងប្រុសនោះបានបោកប្រាស់ខ្លួន ព្រោះខ្លួនបានរង់ចាំវា តែមិនឃើញមកវិញសោះ។

៤. កាល ៖ មួយអាទិត្យក្រោយមក ។

- អាកាស ៖ នៅហាងគុយទាវដដែល
- បុរសនោះ ជឿសម្ដីក្មេងប្រុសនោះដោយខ្លួនបានពិនិត្យទៅមើលឃើញថា ជើងវាមានរបួសមែន។

៥. ចរិតលក្ខណៈតួអង្គ ៖

- បុរស ៖ មានក្ដីមេត្តា ចេះអាណិតអាសូរដល់ក្មេងប្រុសក្រីក្រលំបាក។
- ក្មេងប្រុស ៖ មានភាពស្មោះត្រង់ ចេះទទួលខុសត្រូវ ។


www.elibraryofcambodia.org

វិញ្ញាសាទី ៨

# រឿង ព្រះថោងនាងនាគ

កាលពីព្រេងនាយ មានឈ្មួញសំពៅជនជាតិឥណ្ឌាម្នាក់នាម " ព្រះថោង " បានមកធ្វើជំនួញនៅសមុទ្រខាងត្បូង។ យប់មួយ ព្រះថោងបោះពលរេហ៍ចូលចតសម្រាកនៅកោះមួយ។ កោះនេះជាកន្លែងដែលនាងនាគតែងកាឡាខ្លួនជាស្រីក្រមុំដ៏ស្អាត នាំអ្នកកំដរមកលេងទឹកជារៀងរាល់យប់។ ព្រះថោងឃើញនាងនាគក៏កើតក្ដីស្រឡាញ់។ អ្នកទាំងពីរ មានទឹកចិត្តស្នេហាគ្នា ទៅវិញទៅមក។ ស្ដេចនាគទ្រង់ជ្រាបក៏យាងមកកោះនោះ ហើយរៀបអភិសេកបុត្រទាំងពីរតាមប្រពៃណី។



ក្រោយមក ព្រះថោងចង់ទៅស្គាល់ឋានភុជង្គនាគ តែទ្រង់ពុំចេះជ្រែកទឹក ជ្រែកដីសោះ។ នាងនាគក៏ឱ្យព្រះថោងតោងកន្ទុយមុជជ្រែកទឹក ជ្រែកដីបានទៅដល់ឋានភុជង្គនាគ ដូចប្រាថ្នា។


www.elibraryofcambodia.org

## សិក្សាលើមេរៀនសារទី ៨

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖

" ឈ្មួញ សំពៅ ពល កាឡា កំដរ ស្នេហា អភិសេក ភុជង្គ ច្រៀក "។

២. ចូររកវេវចនសព្ទនឹងពាក្យ ៖ " កាល "។

៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " ចត កោះ "។

### ខ. សំណួរ

១. តើព្រះថោងជាជនជាតិអ្វី ? មានមុខបរអ្វី ?

២. តើព្រះថោង មកទីនោះដើម្បីធ្វើអ្វី ? ទីនោះនៅឯណា ?

៣. តើព្រះថោង បានចូលចតសំពៅនៅឯណាដែរ ?

៤. តើកោះនោះជាកន្លែងរបស់អ្នកណា? សម្រាប់ធ្វើអ្វី ?

៥. នៅទីបំផុត តើអ្នកទាំងពីរបានជួបគ្នា ក្នុងន័យជាអ្វីនឹងគ្នា ? ហេតុអ្វី?

៦. ក្រោយពីស្តេចភុជង្គនាគទ្រង់ជ្រាបរឿងនេះហើយ តើព្រះអង្គធ្វើដូចម្តេច?

៧. ក្រោយពីរៀបអភិសេករួចមក តើព្រះថោងមានបំណងទៅណា ? ហើយត្រូវធ្វើដូចម្តេច ដើម្បីសម្រេចបំណងនេះ ?

៨. តើប្រពៃណីខ្មែរមួយណា ដែលមានទាក់ទងទៅនឹងរឿងព្រះថោង នាងនាគនេះ ?



www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ៨

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ឈ្មួញ (ន.) ៖ អ្នកដែលធ្វើជំនួញ អ្នកជួញ ។
- សំពៅ (ន.) ៖ កេត្រា គឺនាវាធំមានរាងខាងក្បាលនិងកន្សៃស្មើនបើកលឿនដោយកម្លាំងស្លាបក្ដោងច្រើន មានតូចមានធំតាមការប្រកបសម្រាប់ដើរផ្លូវសមុទ្រ។
- ពល (ន.) ៖ កម្លាំង។ សេនា ទាហាន កងទ័ព។ ឧ. កុំពល, លើកពល ។
- កាឡា (កិ.) ៖ ប្លែងខ្លួន និម្មិតខ្លួនឱ្យប្លែកពីប្រក្រតី ។ ឧ. យក្សកាឡាខ្លួនជាប្រើសមាស ។
- កំដរ (កិ. ឬ កិ.វិ.) ៖ ធ្វើឱ្យបានជាគ្នា។ ឧ. កំដរគ្នា ដេកកំដរ នៅកំដរ ទៅកំដរគេ ។
- ស្នេហា(ន. ឬ គុ.) ៖ សេចក្ដីស្រឡាញ់ស្និទ្ធ សេចក្ដីស្រឡាញ់ជាប់ចិត្ត។
- អភិសេក (កិ.) ៖ រៀបផ្សំផ្គុំជាគូស្វាមីភរិយា។
- ភុជង្គ (ន.) ៖ ពស់ នាគ។ ភុជង្គនាគខ្មែរប្រើសំដៅសេចក្ដីថា ពិភពនាគ។
- ជ្រែក (កិ.) ៖ ដែកវែកចូល ញែកចូល។ ឧ. ជ្រែកចូល មារជ្រែក។



www.elibraryofcambodia.org

២. វេចនសព្ទ

- កាល ពេល វេលា គ្រា សម័យ។

៣. សទិសសព្ទ

- ចត (កិ.) ៖ បញ្ឈប់យានយន្តនៅចិញ្ចើមផ្លូវ នៅផែជាដើម។ ឧ. ចតទូក ចតកប៉ាល់ ចតឡាន។
- ចត (កិ.) ៖ ដាក់ថ្នាំបំពោករុំដោយសំពត់ត្រង់ដៃ ឬជើងដែលបាក់ឬគ្រេច។ ឧ.ចតឫស(និយាយដោយស្រុក)
- កោះ (កិ.) ៖ ហៅដោយអំណាចអាជ្ញា។ ឧ. ដីកាកោះ។ អំពាវនាវហៅ(ឆ្កែ) ឆ្កែកោះអញ្ជើញ។
- កោះ (កិ.) ៖ លើកផ្លូងឡើង ច្រើននិយាយតែខាងធ្នូសរ។ ឧ. កោះសរតម្រង់ ។
- កោះ (កិ.) ៖ ធ្វើវត្ថុមានគ្រឿងបរិភោគជាដើមឱ្យមានទឹកព័ទ្ធជុំវិញមានសណ្ឋានជាកោះ។ ឧ. យកស្ករទៅកោះទឹកកុំឱ្យស្រមោចស៊ីបាន ។
- កោះ (កិ.) ៖ ផ្ដក់។ ឧ. គ្រឿងកោះជាប់នៅដៃវណែង ។
- កោះ (ន.) ៖ ទីដី ឬភ្នំ ដែលមានទឹកព័ទ្ធជុំវិញ។ ឧ. កោះកុងកោះទន្សាយ។
- កោះ (ន.) ៖ អវយវៈក្នុងពោះបក្សី។ ឧ. កោះមាន់ កោះទា។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ព្រះថោង ជាជនជាតិឥណ្ឌា មានមុខរបរជាឈ្មួញសំពៅ។

២. ព្រះថោង មកទីនេះដើម្បីធ្វើជំនួញ នៅសមុទ្រខាងត្បូង។

៣. ព្រះថោង បានចូលចតសំពៅ និងបោះពលរេហ៍សម្រាកនៅកោះមួយ។

៤. កោះនេះជាទីកន្លែងរបស់នាងនាគ ដែលនាងតែងកាឡាខ្លួនជាស្រីក្រមុំដ៏ស្អាត មកលេងទឹករៀងរាល់យប់ ។

៥. នៅទីបំផុត អ្នកទាំងពីរបានជួបគ្នាក្នុងន័យស្រឡាញ់ ព្រោះអ្នកទាំងពីរមានទឹកចិត្តស្នេហាគ្នាទៅវិញទៅមក។

៦. ក្រោយពីស្ដេចភុជង្គនាគទ្រង់ជ្រាបក្នុងរឿងនេះហើយ ព្រះអង្គក៏យាងមកកោះនោះ ដើម្បីរៀបអភិសេកបុត្រទាំងពីរតាមប្រពៃណី។

៧. ក្រោយពីរៀបអភិសេករួចមក ព្រះថោងមានបំណងចង់ទៅស្គាល់ឋានភុជង្គនាគ តែទ្រង់ពុំចេះជ្រែកទឹក ជ្រែកដីសោះ។ ព្រះអង្គក៏តោងកន្ទុយនាងនាគ មុជជ្រែកទឹក ជ្រែកដីបានទៅដល់ឋានភុជង្គនាគដូចប្រាថ្នា។

៨. ប្រពៃណីខ្មែរ ដែលមានទាក់ទងទៅនឹងរឿងព្រះថោងនាងនាគ គឺពិធីក្នុងមង្គលការ គឺពេលសាមីខ្លួនខាងប្រុសតោងជាយស្បៃកូនក្រមុំចូលទៅក្នុងបន្ទប់។


www.elibraryofcambodia.org

វិញ្ញាសាទី ៩

# រឿង គ្រូពេទ្យភូមិយើង



នៅវេលាយប់មួយ ជីដូនខ្ញុំគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី។ ម្តាយខ្ញុំភ័យស្លន់ស្លោមិនដឹងជាធ្វើដូចម្តេច។ មួយសន្ទុះក្រោយមក គាត់ក៏សម្រេចចិត្តជូនលោកយាយទៅមណ្ឌលសុខភាព។ អ្នកជិតខាងបានឮសំឡេងជជែកគ្នាក៏បើកទ្វារចេញមកមើល។ អ្នកខ្លះជួយច្របាច់រឹត ខ្លះទៅហៅរ៉ឺម៉កមកដឹកលោកយាយ។ ពូប្រធានភូមិបានដឹងរឿងនេះក៏ប្រញាប់មកជួយគ្រាហ៍លោកយាយ ហើយធ្វើដំណើរទៅជាមួយគ្រួសារខ្ញុំដែរ។

ពេលទៅដល់មណ្ឌលសុខភាព លោកគ្រូពេទ្យវ័យក្មេងម្នាក់ដែលប្រចាំការបានចេញមកសាកសួរដោយរាក់ទាក់បំផុត។ យើងនាំគ្នាជួយគ្រាហ៍លោកយាយចូលក្នុងបន្ទប់។ លោកគ្រូពេទ្យចាប់ផ្តើមពិនិត្យជំងឺលោកយាយដោយយកចិត្តទុកដាក់។ បន្ទាប់មក លោកចាក់ថ្នាំជូនលោក


www.elibraryofcambodia.org

យាយ ហើយប្រាប់ម្ដាយខ្ញុំកុំឱ្យបារម្ភ ព្រោះបន្ដិចទៀតលោកយាយនឹងធូរស្រាលហើយ។ លោកយកថ្នាំទុកជូនលោកយាយពិសា ហើយក៏ហួសទៅសម្រាក។ មួយសន្ទុះក្រោយមក គាត់អញ្ជើញមកម្ដងទៀតឃើញលោកយាយដឹងខ្លួន លោកនិយាយលួងលោមដោយសម្ដីផ្អែមល្ហែម គួរឱ្យកក់ក្ដៅ ...។

## សិក្សាឈើចិញ្ចាសាធី ៩

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖

" គ្រុន សន្លប់ ស្មារតី ស្លន់ ស្លោ មណ្ឌល គ្រាហ៍ បារម្ភ ធូរ លួង "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ក្ដៅ ស្រាល " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ពិសា "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ដឹង "។

### ខ. សំណួរ

១. តើជីដូនអ្នកមានអាការដូចម្ដេច ?

២. តើម្ដាយអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ? ហើយគាត់សម្រេចចិត្តយ៉ាងណា ?

៣. តើអ្នកជិតខាងនាំគ្នាធ្វើដូចម្ដេច ចំពោះលោកយាយ ?

៤. តើប្រធានភូមិគាត់ធ្វើដូចម្ដេចខ្លះ ?

៥. តើអ្នកណាប្រចាំការនៅមណ្ឌលសុខភាព ? គាត់មានចរិតលក្ខណៈដូចម្ដេចដែរ ?

៦. តើប្រធានភូមិជាមនុស្សយ៉ាងដូចម្ដេច ?

៧. តើអត្ថបទនេះ បានអប់រំអ្នកយ៉ាងដូចម្ដេចខ្លះ ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៩

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- គ្រុន (ន.) ៖ ឈ្មោះរោគមានអាការស្រៀវក្តៅ មានច្រើនយ៉ាង។ *ឧ.* គ្រុនផ្តាសាយ គ្រុនក្តៅក្រហាយ គ្រុនសន្និ គ្រុនញាក់ គ្រុនផ្ទៃមាត់ ...។
- គ្រុន (កិ.) ៖ ចាប់ជំងឺដែលហៅថា គ្រុន។ *ឧ.* រកកលគ្រុន ខ្ញុំគ្រុនធ្វើការមិនកើតទេ។
- សន្លប់ (កិ.) ៖ បាត់ស្មារតីមិនដឹងខ្លួន ដោយភ័យចំប្រប់តក់ស្លុតខ្លាំង ឬដោយត្រូវឫសដំណាំខ្លាំងជាដើម។ *ឧ.* ត្រូវបច្ចាមិត្តវាយសន្លប់ ធ្លាក់ពីលើចុងឈើសន្លប់ ។
- ស្មារតី (ន.) ៖ សេចក្តីនឹកឃើញ ការរឭកបាន ការរឭកឃើញមិនភ្លេច ការចាំបាន ការប្រុងប្រយ័ត្នមិនឱ្យភ្លេច ដំណើរស្វាងរុងរឿងគំនិត(សតិ)។ *ឧ.* មានស្មារតី ភ្លាត់ស្មារតី។
- ស្លន់ (កិ.) ៖ ភ័ន្តស្មារតីមួយរំពេចៗដោយភិតភ័យខ្លាំង ឬដោយប្រញាប់ប្រញាល់ពេក។ *ឧ.* ភ័យណាស់ស្លន់យកអ្វីមិនទាន់ ។ ស្លន់ស្លោ ស្លន់ធ្វើភ្នែកស្លោ ឬស្លន់ឆោឡោ ។
- ស្លោ (គុ. ឬ កិ.វិ.) ៖ ដែលបើកខ្លាំងបញ្ឈរស្ញឹងដោយភ្ញាក់ផ្អើល ឬភ័យ តក់ស្លុត (ចំពោះតែភ្នែក)។ *ឧ.* ភ្នែកស្លោ ធ្វើភ្នែកស្លោ ភ័យស្លោភ្នែក ។ ស្លន់ស្លោ ស្លន់ធ្វើភ្នែកស្លោ ឬធ្វើភ្នែកស្លោព្រោះស្លន់ ។



www.elibraryofcambodia.org

- មណ្ឌល (ន.) ៖ រង្វង់មូល ទីដែលមានសណ្ឋានមូល។ *ឧ.* មណ្ឌលកីឡា មណ្ឌលប្រណាំងសេះ វង់ ឬផ្ទៃព្រះអាទិត្យ ឬព្រះចន្ទ្រ។ មណ្ឌលព្រះចន្ទ្រ មណ្ឌលព្រះអាទិត្យ។ ទី ទីប្រជុំ តំបន់។ *ឧ.* មណ្ឌលបោះឆ្នោត ខេត្រ ដែន ...។
- គ្រាហ៍ (ន.) ៖ ដំណើរអង អបអង កៀកអង។ ប្រើក្លាយមកជា (កិ.) ៖ គ្រាហ៍មនុស្សឈឺ គ្រាហ៍មនុស្សមានរបួស ។
- បារម្ភ (ន.) ៖ ដំណើរនឹកថប់ឬនឹកព្រួយជាមុន។ *ឧ.* ខ្ញុំមានបារម្ភក្រែងតែការនុះនឹងមិនបានសម្រេច ។ ផ្ទួនកាលប្រើជា (កិ.) ៖ អ្នកកុំបារម្ភឱ្យសោះ ការនុះមុខជានឹងសម្រេចជាប្រាកដ។
- ធូរ (គុ.) ៖ ទីទៃពីតឹង គឺងាយ ទូលាយ។
  (កិ.) ៖ ស្រាក ស្បើយ(ជំងឺ)។ *ឧ.* ជំងឺជីតាខ្ញុំ ថ្ងៃនេះបានធូរបន្តិច។
- លួង (កិ.) ៖ ពោលពាក្យទន់ផ្អែមល្ហែមសម្រួលចិត្តអ្នកដទៃឱ្យធូរឱ្យស្រួល។ *ឧ.* ម្ដាយលួងកូន ។ លួងលោម លោមដោយលួងចិត្ត ល្បួងលួងឱ្យស្រួលចិត្ត ។

## ២.បដិសព្ទ

- ក្ដៅ ≠ត្រជាក់
- ស្រាល ≠ធ្ងន់


www.elibraryofcambodia.org

៣. វេចនសព្ទ

- ពិសា ស៊ី សោយ ហូប ឆាន់។

៤. សទិសសព្ទ

- ដឹង (ន.) ៖ ប្រដាប់គ្រឿងប្រើប្រាស់ធ្វើដោយដែកមានដង មានផ្លែសម្រាប់ក្រវៃបែល ចពុះចាំងឈើ។
  *ឧ.* យកដឹងមកចាំងឈើ។
- ដឹង (កិ.) ៖ បានដំណឹង ទទួលដំណឹង យល់ការណ៍។
  *ឧ.* ដឹងខុសដឹងត្រូវ។

## ខ. ចម្លើយ

១. ជីដូនខ្ញុំមានអាការគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ។

២. ម្តាយខ្ញុំមានអារម្មណ៍ភ័យស្លន់ស្លោមិនដឹងជាធ្វើដូចម្តេច ។ គាត់សម្រេចចិត្តជូនលោកយាយទៅមណ្ឌលសុខភាព ។

៣. អ្នកជិតខាងបានឮសំឡេងជជែកគ្នា ក៏បើកទ្វារចេញមកមើល ខ្លះជួយរិតច្របាច់ ខ្លះទៅហៅរ៉ឺម៉ក មកដឹកលោកយាយ។

៤. ប្រធានភូមិ បានដឹងរឿងនេះក៏ប្រញាប់មកជួយគ្រាហ៍លោកយាយ ហើយធ្វើដំណើរទៅជាមួយគ្រួសារខ្ញុំដែរ។

៥. លោកគ្រូពេទ្យវ័យក្មេងម្នាក់ ជាអ្នកប្រចាំការនៅមណ្ឌលសុខភាព បានចេញមកសាកសួរយ៉ាងរាក់ទាក់។
គាត់មានចរិតលក្ខណៈស្លូតបូតសុភាពរាបសា ចេះគួរសមប្រកបដោយសីលធម៌ជាគ្រូពេទ្យល្អ។

៦. ប្រធានភូមិ ជាមនុស្សដែលមានសន្តានចិត្តល្អ ចេះជួយទុក្ខធុរៈសមាជិកភូមិរបស់ខ្លួនក្នុងគ្រាមានអាសន្ន។

៧. អត្ថបទនេះ បានអប់រំយើងឱ្យចេះជួយគ្នាទៅវិញទៅមក ពេលមានទុក្ខធុរៈ ។


www.elibraryofcambodia.org

វិញ្ញាសាទី
១០

# ការគោរពឪពុកម្ដាយ



ឪពុកម្ដាយ ជាអ្នកមានគុណដ៏លើសលប់ចំពោះកូន។ កូនគ្រប់រូបត្រូវមានឥរិយាបថល្អប្រពៃចំពោះពួកគាត់។ ពេលឪពុកម្ដាយហៅ កូនត្រូវឆ្លើយបាទ ឬចាស ហើយមកជិតចាំស្ដាប់គាត់មានប្រសាសន៍ ដោយយកចិត្តទុកដាក់ និងដោយទឹកមុខញញឹម។ ពេលឪពុកម្ដាយប្រើបន្តិចបន្តួចត្រូវប្រញាប់ធ្វើដោយប្រញាប់ មិនត្រូវរត់គេច ឬធ្វើឫកពាមិនពេញចិត្តនោះឡើយ។ លើសពីនេះទៀត កូនមិនត្រូវមានចរិតរឹងរូស មិនស្ដាប់ដំបូន្មានឪពុកម្ដាយនោះទេ។

កូនត្រូវជម្រាបលាឪពុកម្ដាយ ពេលចេញទៅសាលារៀន និងជម្រាបសួរគាត់ ពេលត្រឡប់មកពីសាលារៀនវិញដោយពោលពាក្យ ពុក ម៉ែ ឬ ប៉ា ម៉ាក់ ! កូនទៅរៀនហើយ ឬកូនមកពីរៀនវិញហើយ។ បើចង់ទៅណា


www.elibraryofcambodia.org

មកណា ត្រូវជម្រាបគាត់ឱ្យបានសមរម្យដោយប្រាប់ពីទីកន្លែងដែលយើងទៅ ទៅជាមួយអ្នកណា ទៅធ្វើអ្វី ហើយពេលណាត្រឡប់មកវិញ។ម្យ៉ាងទៀត កូនត្រូវជៀសវាងការនិយាយកុហកឪពុកម្ដាយ។

ប្រសិនបើកូនគ្រប់រូប ប្រកាន់ខ្ជាប់នូវអាកប្បកិរិយាទាំងនេះ សេចក្ដីថ្លៃថ្នូរនឹងកើតមានដល់ខ្លួនអ្នក និងគ្រួសារអ្នក។ លើសពីនេះ អ្នកនឹងមានអនាគតល្អ ហើយគ្រួសារនឹងជួបតែសុភមង្គលមិនខានឡើយ។

## សិក្សាលើមេរៀនទី ១០

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖

" លើស ឥរិយាបថ ប្រសាសន៍ រូតរះ ឬក ចរិត រឹងរូស ជំនួនន "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ល្អ លើស រឹង សុភមង្គល "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ឪពុក ម្ដាយ "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " គុណ "។

### ខ. សំណួរ

១. ពេលឪពុកម្ដាយហៅ តើកូនត្រូវឆ្លើយ ហើយធ្វើដូចម្ដេចខ្លះ ?

២. ពេលឪពុកម្ដាយនិយាយ តើកូនត្រូវធ្វើដូចម្ដេច ?

៣. តើកូនត្រូវជៀសវាងអ្វីខ្លះ ?

៤. មុនពេលទៅនិងត្រឡប់ពីសាលារៀនវិញ តើកូនត្រូវធ្វើនិងនិយាយដូចម្ដេច ?

៥. បើចង់ទៅណាមកណា តើកូនត្រូវធ្វើដូចម្ដេច ?


www.elibraryofcambodia.org

៦. ចូរអ្នកចុះលេខល្បះខាងក្រោមតាមលំដាប់គំនិត រួចសរសេរល្បះទាំងនេះ តគ្នាជាកថាខណ្ឌឱ្យត្រឹមត្រូវ ៖

- កូនត្រូវគោរពស្រឡាញ់គាត់ ។
- បើគាត់ហៅ កូនត្រូវឆ្លើយបាទ ឬចាសហើយរត់មកជិតគាត់ដោយទឹកមុខញញឹម។
- ត្រូវប្រុងចាំស្ដាប់ប្រសាសន៍គាត់ ដោយយកចិត្តទុកដាក់។
- មិនតែប៉ុណ្ណោះកូនល្អ ត្រូវប្រើសម្ដីទន់ភ្លន់ជានិច្ចទៅកាន់មាតាបិតា។
- កុមារគ្រប់រូបត្រូវប្រតិបត្តិដូចខាងលើ ដើម្បីឱ្យឪពុកម្ដាយអ្នកសប្បាយចិត្ត។
- ឪពុកម្ដាយជាអ្នកមានគុណ។

## កំណែវិញ្ញាសាទី ១០

### ក. រៀនពាក្យ

#### ១. ពន្យល់ពាក្យ

- លើស (កិ.) ៖ ហួស កន្លង។ **ឧ.** ចេះឥតមានអ្នកណាលើស។ **គុ.** ដែលហួសប្រមាណ ហួសពីចំនួន កន្លង ក្រៃលែង។ **ឧ.** ច្រើនលើស ល្អលើសគេ មានទ្រព្យលើសគេ។ លើសខ្វះ លើសឬខ្វះ លើសខ្លះខ្វះខ្លះ។ លើសប្រមាណ ហួសប្រមាណ ។
- ឥរិយាបថ (ន.) ៖ ផ្លូវ ឬគន្លងនៃឥរិយា គឺការដើរ ឈរ អង្គុយ ដេក។ សម្រេច ឥរិយាបថ ប្រើឥរិយាបថ។


www.elibraryofcambodia.org

- ប្រសាសន៍ (ន.) ៖ ពាក្យបង្គាប់ ពាក្យផ្ដាំ ផ្ញើបណ្ដាំ។ ខ្មែរយើងប្រើចំពោះតែ ពាក្យសម្ដី របស់ឥស្សរជនក្រៅពីក្សត្រិយ៍។ *ឧ.* ទទួលប្រសាសន៍លោក គឺទទួលពាក្យលោក លោកមានប្រសាសន៍ គឺលោកនិយាយ (សម្រាប់ឥស្សរជនជាគ្រហស្ថ)។
- រូតរះ (កិ. ឬកិ.វិ.) ៖ ស្រូតរូត រៀសរវៃ ម៉ឺម្នា។ *ឧ.* ដើររូតរះ ធ្វើការរូតរះ ។
- ឫក (ន.) ៖ មារយាទ កិរិយា អាការកិរិយា បែបបទសណ្ដាប់ធ្នាប់(របស់រូបកាយ)។ *ឧ.* ឫកល្អ ឫកអាក្រក់។
- ចរិត (ន.) ៖ ការប្រព្រឹត្តិ កិរិយាមារយាទ ឫកពា បែបបទ។ល។ *ឧ.* ចរិតល្អ ចរិតមិនល្អ។
- រឹងរូស (គុ.) ៖ រឹងតត្រឹសតត្រូស រឹងមិនព្រមចុះរុះ មិនព្រមទន់តាម។ *ឧ.* មនុស្សរឹងរូស សម្ដីរឹងរូស ចិត្តរឹងរូស ។
- ដំបូន្មាន (ន.) ៖ សេចក្ដីទូន្មាន និវាទ ពាក្យប្រដៅ ។ *ឧ.* ឱ្យដំបូន្មាន ស្ដាប់ដំបូន្មាន។

២.បដិសព្ទ

- ល្អ ≠ អាក្រក់
- លើស ≠ ខ្វះ
- រឹង ≠ ទន់
- សុភមង្គល ≠ អពមង្គល


www.elibraryofcambodia.org

៣. វេចនសព្ទ

- ឪពុក បិតា ពុក ប៉ា
- ម្ដាយ មាតា ម៉ែ ម៉ាក់។

៤. សទិសសព្ទ

- គុណ (ន.) ៖ សេចក្ដីចម្រើន សភាវធម៌ដែលចម្រើនឡើង ដោយលក្ខណៈរបស់ខ្លួនគួរគោរពគបស្នងនឹង ខានពុំបាន ដូចជាគុណមាតាបិតា គុណគ្រូ គុណព្រះពុទ្ធ គុណលេខ។
- គុន (ន.) ៖ ឈ្មោះសិល្បៈខាងគ្រឿងអាវុធ សម្រាប់ចូលប្រឡូក លោត ហក់ តយុទ្ធផ្ទាល់ខ្លួន ជាចំណេះវិសេសម្យ៉ាងរបស់អ្នកចម្បាំង ពីក្នុងសម័យបុព្វបុរសរាល់ប្រទេស។ ឧ. គុនដំបង គុនដាវវែង គុនដាវខ្លី គុនខែល គុនកាំបិត គ្រលុក ... ។

## ខ. ចម្លើយ

១. ពេលឪពុកម្ដាយហៅ កូនត្រូវឆ្លើយបាទ ឬចាស ហើយមកជិតចាំស្ដាប់គាត់មានប្រសាសន៍ ដោយយកចិត្តទុកដាក់ និងដោយទឹកមុខញញឹម។

២. ពេលឪពុកម្ដាយប្រើបន្តិចបន្តួចត្រូវតែរះធ្វើដោយប្រញាប់ មិនត្រូវរត់គេច ឬធ្វើឫកពាមិនពេញចិត្តនោះឡើយ។ លើសពីនេះទៀត កូនមិនត្រូវមានចរិតរឹងរូសមិនស្ដាប់ដំបូន្មានឪពុកម្ដាយនោះទេ។


www.elibraryofcambodia.org

៣. កូនត្រូវជៀសវាង ៖
- ការនិយាយកុហកឪពុកម្ដាយ
- ការរត់គេច ឬធ្វើឫកពាមិនពេញចិត្តចំពោះកិច្ចការណាដែលលោកប្រើ
- ការមានចរិតរឹងរូសមិនស្ដាប់ដំបូន្មានឪពុកម្ដាយ។

៤. មុនពេលទៅ និងត្រឡប់ពីសាលារៀនវិញ កូនត្រូវជម្រាបលាឪពុកម្ដាយពេលចេញទៅសាលារៀន និងជម្រាបសួរគាត់ពេលត្រឡប់មកពីសាលារៀនវិញ ដោយពោលពាក្យ ពុក ម៉ែ ឬប៉ា ម៉ាក់ ! កូនទៅរៀនហើយ ឬកូនមកពីរៀនវិញហើយ។

៥. បើចង់ទៅណាមកណា កូនត្រូវជម្រាបគាត់ឱ្យបានសមរម្យថា យើងទៅណា ទៅជាមួយអ្នកណា ទៅធ្វើអ្វី ហើយពេលណាត្រឡប់មកវិញ។

៦. ចុះលេខល្បះខាងក្រោមតាមលំដាប់គំនិត រួចសរសេរល្បះទាំងនេះតគ្នាជាកថាខណ្ឌ ៖
- ឪពុកម្ដាយជាអ្នកមានគុណ។
- កូនត្រូវគោរពស្រឡាញ់គាត់ ។
- បើគាត់ហៅ កូនត្រូវឆ្លើយបាទ ឬចាសហើយរត់មកជិតគាត់ដោយទឹកមុខញញឹម។ ត្រូវប្រុងចាំស្ដាប់ប្រសាសន៍គាត់ ដោយយកចិត្តទុកដាក់។
- មិនតែប៉ុណ្ណោះកូនល្អ ត្រូវប្រើសម្ដីទន់ភ្លន់ជានិច្ចទៅកាន់មាតាបិតា។
- កុមារគ្រប់រូបត្រូវប្រតិបត្តិដូចខាងលើ ដើម្បីឱ្យឪពុកម្ដាយសប្បាយចិត្ត។


www.elibraryofcambodia.org

វិញ្ញាសាទី ១១

# រឿង ខ្លានិងកណ្ដុរ



ថ្ងៃមួយ ខ្លាដើរស្វែងរកអាហារ ប្រទះនឹងកណ្ដុរកំពុងដេកលក់។ ខ្លាបានចាប់កណ្ដុរប្រុងនឹងត្របាក់ស៊ី តែកណ្ដុរអង្វរ៖ " សូមលោកកុំពិសាខ្ញុំអី ខ្ញុំតូចណាស់ ! បើលោកពិសាខ្ញុំ ខ្លួនខ្ញុំមិនបានមួយម៉ាត់ផង! ហើយបើលោកទុកជីវិតខ្ញុំវិញ ខ្ញុំនឹងដឹងគុណលោកអស់មួយជីវិត "។ គាប់ជួនពេលនោះខ្លាពុំសូវឃ្លានអាហារក៏ធ្វើតាមការអង្វររបស់កណ្ដុរ។ ថ្ងៃក្រោយមក ខ្លាដើរស្វែងរកចំណីដូចធម្មតាក៏ទៅជាប់អន្ទាក់ព្រាន។ ខ្លាស្រែកឮសន្ធឹកពេញព្រៃ។ កណ្ដុរឮសំឡេងខ្លា ក៏រត់មករកមើល។ វាស្គាល់ច្បាស់ជាខ្លាដែលទុកជីវិតវាពីថ្ងៃមុន។ ជាការតបស្នងគុណវិញ កណ្ដុរខំប្រឹងកកេរកាត់ខ្សែអន្ទាក់ទាល់តែដាច់របូត ខ្លាក៏រួចជីវិតទៅ។


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ១១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ក្របាក់ គុណ អន្ទាក់ ព្រាន សន្ទិក កកេរ "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ក្រោយ មក រួចជីវិត "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ស្នងគុណ របូត "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " លក់ "។

### ខ. សំណួរ

១. តើខ្លាបម្រុងចាប់សត្វអ្វីស៊ីជាអាហារ ?

២. តើខ្លាស៊ីសត្វនោះបានសម្រេចឬទេ ? ព្រោះអ្វី ?

៣. ពេលខ្លាដើរស្វែងរកចំណី តើមានរឿងអ្វីកើតឡើង ?

៤. តើមានសត្វណាមួយជាអ្នកជួយខ្លា ? ព្រោះអ្វី ?

៥. ដូចម្តេចដែលហៅថាដំណើររឿង ? តើដំណើររឿងនេះ មានព្រឹត្តិការណ៍សំខាន់អ្វីខ្លះ ?



www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ១១

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ត្របាក់ (កិ.) ៖ ខាំ លេបស៊ីដោយរហ័ស (ពាក្យសម្រាប់ប្រើចំពោះតែសត្វតិរច្ឆាន)។ *ឧ.* ឆ្កែត្របាក់ ត្រីឆ្តោរត្របាក់ ជ្រូកត្របាក់បាយក្នុងស្នូក ។
- គុណ(ន. ឬ គុ.)៖ ដំណើរធ្វើឱ្យចម្រើនកើនឡើង។ *ឧ.* គុណ ១០ ជា ២០ លេខគុណ ។
- គុណ (ន.) ៖ សេចក្តីចម្រើន ថ្នាក់ ជាន់ លក្ខណៈ ចំណែកសេចក្តីល្អ សភាព បែបបទ...។ សភាវធម៌ដែលចម្រើនឡើងដោយលក្ខណៈរបស់ខ្លួនគួរគោរពតបស្នងនឹងខានពុំបាន។ *ឧ.* គុណមាតា គុណបិតា គុណគ្រូ គុណលោកអ្នកមានឧបការៈលើខ្លួន ។
- អន្ទាក់ (ន.) ៖ ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្តៅជាដើមមានក្រវិលរូតបាន សម្រាប់ទាក់ សម្រាប់ដាក់ឱ្យជាប់សត្វទ្វេបាទចតុប្បាទជាដើម។ *ឧ.* សត្វជាប់អន្ទាក់។
- ព្រាន (ន.) ៖ ប្រមាញ់ នេសាទ។ *ឧ.* ព្រានម្រឹគ ព្រានបក្សី ឬព្រានសត្វស្លាប។


www.elibraryofcambodia.org

- សន្ទឹក (ន.) ៖ ស្ទរលាន់ឮខ្លាំង ស្ទរសព្ទដែលលាន់ឮរំពងគួរ
ឱ្យស្ញើប។ ឧ. សន្ទឹកខ្យល់ព្យុះ សន្ទឹករលក
សមុទ្រ។ គុ. ឬ កិ.វិ. ៖ ដែលច្រើនហួស
ប្រមាណ ច្រើនក្រៃ។ ឧ. បានអឺកក់សន្ទឹក
មនុស្សមកសន្ទឹកណាស់ ត្រូវគេស្ដីឱ្យសន្ទឹក។
- កកេរ (កិ.) ៖ ខាំរៀយៗ ដើម្បីឱ្យដាច់។ ឧ. កកេរពោត
កណ្ដុរកកេរខ្ទុ ។

## ២.បដិសព្ទ

- ក្រោយ ≠ មុខ
- មក ≠ ទៅ
- រួចជីវិត ≠ បាត់បង់ជីវិត

## ៣.វេវចនសព្ទ

- ស្ពងគុណ ដឹងគុណ
- របូត រលូត ឃ្លាត។

## ៤.សទិសសព្ទ

- លក់ (កិ.) ៖ ចំណាយទំនិញ ឱ្យរបស់ទៅអ្នកទិញដោយយក
ថ្លៃ។ ឧ. លក់ទំនិញ។ ពិន័យតាមច្បាប់បញ្ញត្តិ។
ឧ. ត្រូវគេយលក់ ៣០រៀល។ លក់ខ្លួន ចំណាយ
ខ្លួនឱ្យជាអ្នកនៅបម្រើគេ ។
- លក់ (កិ.) ៖ ដេកសិប់ស្ងាត់អារម្មណ៍មិនដឹងខ្លួន។ ឧ. លក់
មួយល្បក់។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ខ្លាបម្រុងចាប់សត្វកណ្ដុរស៊ីជាអាហារ។

២. ខ្លាស៊ីសត្វកណ្ដុរនោះមិនបានសម្រេចទេ ព្រោះកណ្ដុរអង្វរ ៖ " សូមលោកកុំពិសាខ្ញុំអី ខ្ញុំតូចណាស់ ! បើលោកពិសាខ្ញុំ ខ្លួនខ្ញុំមិនបានមួយម៉ាត់ផង ! ហើយបើលោកទុកជីវិតខ្ញុំវិញ ខ្ញុំនឹងដឹងគុណលោកអស់មួយជីវិត " ។

៣. ពេលខ្លាដើរស្វែងរកចំណី ក៏ត្រូវជាប់អន្ទាក់ព្រាន។

៤. សត្វកណ្ដុរជាអ្នកជួយខ្លា ដោយខំប្រឹងកកេរកាត់ខ្សែអន្ទាក់ទាល់តែដាច់រលូត ខ្លាក៏រួចជីវិត នេះជាការតបស្នងគុណរបស់កណ្ដុរចំពោះខ្លា។

៥. ដែលហៅថា ដំណើររឿង គឺជាលំដាប់លំដោយព្រឹត្តិការណ៍ក្នុងរឿងតាំងពីដើមដល់ចប់។ ព្រឹត្តិការណ៍រឿងសំខាន់ៗ គឺជាបណ្ដុំព្រឹត្តិការណ៍បន្ទាប់បន្សំនៅក្នុងរឿងមួយ។

ដំណើររឿងនេះ មានព្រឹត្តិការណ៍សំខាន់គឺ ៖

- ខ្លាបម្រុងស៊ីកណ្ដុរ តែដោយកណ្ដុរអង្វរក៏លែងកណ្ដុរវិញទៅ
- ខ្លាជាប់អន្ទាក់ព្រាន
- កណ្ដុរជួយខ្លាឱ្យរួចជីវិត។


www.elibraryofcambodia.org

វិញ្ញាសាទី ១២

# រឿង បងប្អូនបីនាក់



មានបុរសម្នាក់មានកូនបីនាក់។ កាលបើដឹងថាខ្លួនជិតស្លាប់ហើយក៏ហៅកូនទាំងបីមកជិត រួចនិយាយ ៖ " នែកូនទាំងបី ! ឪពុកបានបង្ហាត់បង្រៀនចំណេះវិជ្ជាសព្វគ្រប់ល្មមរក្សាខ្លួនបានហើយ។ ប៉ុន្តែឪពុកផ្តាំកូនជាចុងក្រោយ ត្រូវចេះស្រឡាញ់រួបរួមគ្នា កុំឈ្លោះប្រកែកបែកសាមគ្គីគ្នា "។

គាត់បានប្រើឱ្យកូនច្បង ទៅយកអំពៅមួយដើមមកកាច់។ កូនច្បងកាច់អំពៅនោះបាក់ជាពីរកំណាត់។ ឃើញអំពៅបាក់ គាត់បានបង្គាប់កូនបន្ទាប់យកអំពៅបីដើមមកចងជាបាច់កាច់ឱ្យបាក់។ កូនបន្ទាប់កាច់អំពៅមិនបាក់សោះ។ ឃើញដូច្នេះ ឪពុកពោលទៅកាន់កូន ៖ " ខ្លួនកូនបីនាក់


www.elibraryofcambodia.org

ប្រៀបដូចអំពៅបីដើមនេះ។ បើពួកឯងចងសាមគ្គីគ្នា នោះពិតជាបានសុខ និងមានជ័យជម្នះលើការងារគ្រប់មុខ "។ កូនទាំងបី ធ្វើតាមដំបូន្មានឪពុក បានសេចក្ដីសុខដរាបរៀងទៅ។

## សិក្សាលើវិញ្ញាសាទី ១២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖
" បង្គាត់ បង្រៀន វៃ្លមាន រក្សា សាមគ្គី ជ័យ ដរាប "។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " សាមគ្គី ជ័យជម្នះ "។
៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ដំបូន្មាន "។
៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " បី រៀង "។
៥. តើសញ្ញាក្បៀស បើក បិទ ប្រើសម្រាប់ធ្វើអ្វីខ្លះ ? ចូររកឧទាហរណ៍ បញ្ជាក់។

### ខ. សំណួរ

១. កាលបើដឹងខ្លួនថា ខ្លួនជិតស្លាប់ហើយ តើបុរសនោះនិយាយដូចម្ដេច ?
២. តើគាត់បានឱ្យកូនធ្វើដូចម្ដេចទៀត ?
៣. ក្រោយពីកាច់អំពៅបាក់ហើយ តើគាត់បង្គាប់កូនឱ្យធ្វើអ្វីទៀត ?
៤. ជាចុងក្រោយ តើឪពុកបានពោលយ៉ាងណាខ្លះ ទៅកាន់កូន ?
៥. តើកូនទាំងបីធ្វើតាមដំបូន្មានឪពុកដែរឬទេ ? បានលទ្ធផលយ៉ាងណាដែរ ?


www.elibraryofcambodia.org

## អំណានទី ១២

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- បង្ហាត់ (កិ.) ៖ ប្រើឱ្យហាត់ ប្រិតប្រៀនបង្វឹកឱ្យបានបទ ។
  ឧ. បង្ហាត់កីឡា បង្ហាត់ធម៌ ។
- បង្រៀន (កិ.) ៖ ញ៉ាំងអ្នកដទៃឱ្យរៀន ប្រៀនឱ្យចេះ ចំណេះ ដោយការបង្ហាត់ បង្ហាញឱ្យចេះ។
  ឧ. បង្រៀនអក្សរ បង្រៀនលេខ បង្រៀនច្បាប់។
- វិជ្ជមាន (គុ.) ៖ ដែលកំពុងមាននៅឡើយ ធរមាន។
  ឧ. ច្បាប់វិជ្ជមាន ឬវិជ្ជមានបញ្ញត្តិ។
- រក្សា (កិ.) ៖ ថែ ថែទាំ បីបាច់ ចិញ្ចឹម កាន់ កាន់កាប់ ការពារ ប្រយ័ត្ន។ ឧ. រក្សាទ្រព្យ រក្សាខ្លួន រក្សាមារយាទ រក្សាសីល។
- សាមគ្គី (ន.) ៖ សេចក្ដីព្រមព្រៀង សេចក្ដីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា។ ឧ. សាមគ្គីជាគុណសម្បត្តិដ៏សំខាន់មួយរបស់សត្វលោក ។
- ជ័យ (ន.) ៖ ការឈ្នះ។ ឧ. មានជ័យ ហោយកជ័យ ។ ឈ្មោះពរមួយយ៉ាងសម្រាប់សូត្រចម្រើនសិរីសួស្ដី ក្នុងមង្គលការសម័យបុរាណ។ ក្នុងមង្គលការនេះ សូមឱ្យសូត្រជ័យផង និមន្តលោកសូត្រជ័យ។



www.elibraryofcambodia.org

- ដរាប (និ.) ៖ រៀងរាប ត្រឹម កំណត់ត្រឹម។ ឧ. ដរាបណាដរាបដល់ថ្ងៃនេះ ដរាបណាខ្ញុំនឹងវិលមកដល់វិញ ដរាបនោះសឹមយើងនឹងទៅជាមួយគ្នា អ្នកនៅចាំក្នុងទីនេះចុះ ដរាបណាតែ (គ្រាតែ) ខ្ញុំមកដល់វិញ ។

២.បដិសព្ទ

- សាមគ្គី ≠ បែកបាក់
- ជ័យជម្នះ ≠ បរាជ័យ

៣.ផ្ទួនសព្ទ

- ជំហ្មាន ប្រៀនប្រដៅ ទូន្មាន។

៤.សទិសសព្ទ

- បី (ប.សំ.) ៖ ចំនួនលេខដែលនៅត្រង់ចន្លោះពីរនិងបួន គឺមួយផ្សំនឹងពីរ ឬពីរផ្សំនឹងមួយ (៣) ។
- បី (កិ.) ៖ កាន់ត្រកងឱប ឬទ្រដោយដៃទាំងពីរ។ ឧ. បីកូន បីគោក។ បីត្រកង (ព.ប្រ.)លើកតម្កើង កាន់ជើង កាន់ទ្រធំ។ បីទ្រ ជួយឧបត្ថម្ភគាំទ្រ ។
- រៀង (កិ.ឬកិ.វិ.) ៖ ដាក់តាមលំដាប់ ធ្វើឱ្យត្រូវលំដាប់ ឱ្យត្រូវរបៀប ឱ្យត្រូវជួរ ឱ្យជាជួរ។ ឧ. រៀងលេខដាក់រៀងគ្នា, ឈររៀងគ្នា ដើមឈើដុះរៀងគ្នា។


www.elibraryofcambodia.org

- រាង (កិ. ឬគុ.) ៖ ចាល រអា លែងចង់ លែងត្រូវការទៀត។ ឧ. ផ្លូវនេះពិបាកណាស់ ខ្ញុំរាងហើយមិនទៅទៀតទេ !។
- រាង (ន.) ៖ សណ្ឋាន ទ្រង់ ទ្រង់ទ្រាយ។ ឧ. រាងក្រអាញ រាងស្លើង។
- រាង (ន.) ៖ ផ្ទាំងនោបឬស្សីពាសស្រទបចេក ដាក់លើគែមទូកម្ខាងបន្ទេរឱ្យផ្អៀងមកខាងក្នុងទូក ប៉ែកខាងក្រោមឱ្យរះនឹងទឹក ដើម្បីចែវឬអុំទូកទៅឱ្យត្រីក័ន្តស្លន់លោតចូលក្នុងទូក គេធ្វើតែក្នុងវេលាយប់មានខែភ្លឺ ហៅថា ដេញរាង ។

៥. សញ្ញាក្បៀស បើក បិទ សម្រាប់ដាក់អមពាក្យ ឃ្លា ឬល្បះ ដើម្បីពន្លេចឡើងនូវឈ្មោះ មនុស្ស សត្វ ឬវត្ថុអ្វីមួយដែលសំខាន់ ឬសម្ដីផ្ទាល់របស់អ្នកនិយាយ។ ឧ. ផ្លាស់សំពត់ , ផ្លាស់ទឹកន្លែង , ផ្លាស់ពីទីរាជការ ... ។ ឧ. ឪពុកនិយាយ ៖ " នែ៎កូនទាំងបី ! ឪពុកបានបង្ហាត់បង្រៀនចំណេះវិជ្ជាសព្វគ្រប់ល្មមរក្សាខ្លួនបានហើយ។ ប៉ុន្តែឪពុកផ្ដាំកូនជាចុងក្រោយត្រូវចេះស្រឡាញ់ឬរមគ្នា កុំឈ្លោះប្រកែកបែកសាមគ្គីគ្នា "។


www.elibraryofcambodia.org

## ខ.ចម្លើយ

១. កាលបើដឹងខ្លួនថា ខ្លួនជិតស្លាប់ហើយ បុរសនោះហៅកូនទាំងបីមកជិតរួចនិយាយ៖ "នែ៎កូនទាំងបី!ឪពុកបានបង្ហាត់បង្រៀនចំណេះវិជ្ជាសព្វគ្រប់ ល្មមរក្សាខ្លួនបានហើយ។ ប៉ុន្តែឪពុកផ្តាំកូនជាចុងក្រោយត្រូវចេះស្រឡាញ់របរមគ្នាកុំឈ្លោះប្រកែកបែកសាមគ្គីគ្នា"។

២. គាត់បានប្រើឱ្យកូនច្បង ទៅយកអំពៅមួយដើមមកកាច់ ក៏កាច់អំពៅនោះបាក់ជាពីរកំណាត់។

៣. ក្រោយពីកាច់អំពៅបាក់ហើយ គាត់បានបង្គាប់កូនបន្ទាប់យកអំពៅបីដើមមកចងជាបាច់កាច់ឱ្យបាក់ តែកូនបន្ទាប់កាច់អំពៅមិនបាក់សោះ។

៤. ជាចុងក្រោយ ឪពុកបានពោលទៅកាន់កូន៖ " ខ្លួនកូនបីនាក់ប្រៀបដូចអំពៅបីដើមនេះ។ បើពួកឯងចងសាមគ្គីគ្នា នោះពិតជាបានសុខនិងជ័យជម្នះលើការងារគ្រប់មុខ "។

៥. កូនទាំងបីធ្វើតាមដំបូន្មានឪពុក បានទទួលសេចក្តីសុខដរាបរៀងទៅ។


www.elibraryofcambodia.org

វិញ្ញាសាទី ១៣

# រឿង កុមារចេះគួរសម



វេលារសៀលនៃថ្ងៃអាទិត្យមួយ កុមារីគន្ធាបានឮអាពាលព្រុសវ៉ែស ! វ៉ែស ! នាងដឹងច្បាស់ថាមានភ្ញៀវ មករកនៅខាងក្រៅ។ គន្ធាប្រញាប់ចាប់ ឆ្កែចង រួចដើរទៅបើកទ្វារ។ ពេលនោះ បុរសចំណាស់ម្នាក់សួរគន្ធាមុន ៖ " ពុកម៉ែរបស់ក្មួយនៅឬទេ ? "។ គន្ធាលើកដៃសំពះគាត់ ព្រមទាំងឆ្លើយ ដោយទន់ភ្លន់ ៖ " ចាសលោក អ៊ំ ! ម៉ែខ្ញុំនៅក្នុងផ្ទះបាយចំណែកពុកកំពុង ធ្វើរបងព័ទ្ធចម្ការខាងក្រោយ។ សូមលោកអ៊ំអញ្ជើញចូលទៅក្នុងផ្ទះសិន ខ្ញុំនឹងជម្រាបគាត់ "។ គន្ធានាំភ្ញៀវអង្គុយកន្លែងដ៏គួរសម រួចនាងចូល ទៅក្នុងផ្ទះចាក់ទឹកមួយកែវយកមកជូនភ្ញៀវ និងនិយាយដោយទឹកមុខ ញញឹម ៖ " លោកអ៊ំ ! អញ្ជើញពិសាទឹក "។ ភ្ញៀវនោះតបវិញ " អរគុណ ក្មួយ "។ បន្ទាប់មក គន្ធាថយទៅជម្រាបឪពុកម្ដាយ ។


www.elibraryofcambodia.org

ពេលឪពុកម្ដាយកំពុងសន្ទនាជាមួយភ្ញៀវ ប្អូនប្រុសនាងម្នាក់រត់រឹង បម្រុងទៅរកឪពុកម្ដាយ ស្រាប់តែឃើញឪពុកម្ដាយមានភ្ញៀវ ក៏ឱនក្បាល គោរពបន្តិចរួចត្រឡប់ថយក្រោយវិញ។ គន្ធាទៅជិតនិយាយខ្សឹប ប្រាប់ប្អូន ៖ " អូនឯងកុំរត់កាត់មុខភ្ញៀវ ឬទៅរំខានពុកម៉ែ មិនគួរសមទេ "។

ពេលភ្ញៀវត្រឡប់ទៅផ្ទះវិញ ឪពុកម្ដាយគន្ធាសរសើរកូនស្រីដោយពេញចិត្ត ៖ " កូនចេះគួរសមចំពោះ ភ្ញៀវណាស់ ! ចូរកូនរក្សាការគួរសមចំពោះអ្នកដទៃឱ្យបានជាប់ជានិច្ច "។

## សិក្សាលើអត្ថបទទី ១៣

### ក.រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " រសៀល ទន់ភ្លន់ សន្ទនា រឹង ឱន "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " កុមារី បើក ថយក្រោយ "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ពិសា រក្សា "។

៤. ចូរស្រង់ឧទាហរណ៍ដែលប្រើសញ្ញាក្បៀស បើក បិទ ពីក្នុងអត្ថបទខាងលើ ចំនួន២ល្បះ។

### ខ. សំណួរ

១. ពេលភ្ញៀវទៅលេងផ្ទះ តើគន្ធាបានទទួលភ្ញៀវដូចម្ដេចខ្លះ ?

២. ពេលភ្ញៀវចូលដល់ក្នុងផ្ទះ តើគន្ធាបានធ្វើអ្វីទៀត ?

៣.ពេលឪពុកម្ដាយនាងកំពុងសន្ទនាជាមួយភ្ញៀវ តើមានអ្វីកើតឡើង?


www.elibraryofcambodia.org

៤. ហេតុអ្វីបានជាឪពុកម្ដាយពោលសរសើរគេទ្វា ?

៥. តើអ្នកចង់យកតម្រាប់តាមកុមារីតន្ទាដែរឬទេ ? ហេតុអ្វី ?

៦. តើរឿងនេះ កើតនៅកន្លែងណា ? ពេលណា ?

៧. តើរឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗប៉ុន្មាន ? ចូររៀបរាប់។

## អំណានទិញ្ញាសាទី ១៣

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- រសៀល (ន.) ៖ វេលាក្នុងរវាងថ្ងៃត្រង់ និងល្ងាច គឺតាំងពីក្រោយថ្ងៃត្រង់ដល់ពេលល្ងាច។ ឧ. រសៀលម៉ោង ១។
- ទន់ភ្លន់ (គុ.) ៖ ល្ហាសល្ហន់ សុភាព។ ឧ. ឫកពាទន់ភ្លន់ សម្ដីទន់ភ្លន់។
- សន្ទនា (ន.) ៖ ការនិយាយគ្នា ការពោលពាក្យប្រសាយរកគ្នា ការប្រឹក្សាគ្នា។ ឧ. ធ្វើសន្ទនារកគ្នា។
- វៃ (និ.) ៖ វៃឆ្លាត វៃទៀត ឆ្លាម។ ឧ. វៃឆ្មី វៃកក់ វៃស្លូង។
- វៃ (ន.) ៖ ស្នូរឮដោយចោល ឬគ្រវែងពេញកម្លាំងដៃ។ ឧ. ចោលវៃ ចោលដុំដីឮស្នូរវៃ ។
- ឱន (កិ.) ៖ ទន់ចុះ បន្ទន់ទៅមុខ បន្ទន់ទៅរក ។ ឧ. ឱនកាយថ្វាយបង្គំ ឱនក្បាល មានចិត្តឱនទៅរកសុចរិត ស្រូវឱន ដើរឱន ។


www.elibraryofcambodia.org

២. បដិសព្ទ

- កុមារី ≠ កុមារា
- បើក ≠ បិទ
- ថយក្រោយ ≠ ទៅមុខ

៣. វេវចនសព្ទ

- ពិសា ស៊ី ញ៉ាំ ឆាន់ ហូប សោយ
- ក្បែរ ថែ ថែទាំ បីបាច់ ចិញ្ចឹម កាន់កាប់ ការពារ។

៤. ស្រង់ឧទាហរណ៍ដែលប្រើសញ្ញាក្បៀស បើក បិទពីក្នុងអត្ថបទខាងលើចំនួន២ល្បះ ៖

- " ពុកម៉ែរបស់ក្មួយនៅឬទេ ? "
- " អូនឯងកុំតែកាត់មុខភ្ញៀវ ឬទៅរំខានពុកម៉ែមិនគួរសមទេ " ។

## ខ. ចម្លើយ

១. ពេលភ្ញៀវទៅលេងផ្ទះគន្ធាបានទទួលភ្ញៀវ ដោយលើកដៃសំពះគាត់ព្រមទាំងឆ្លើយក្នុងភាពទន់ភ្លន់ ៖ " ចាសលោកអ៊ំ ! ម៉ែខ្ញុំនៅក្នុងផ្ទះបាយ ចំណែកពុកកំពុងធ្វើរបងព័ទ្ធចម្ការខាងក្រោយ។ សូមលោកអ៊ំអញ្ជើញចូលទៅក្នុងផ្ទះសិនខ្ញុំនឹងជម្រាបគាត់ "។

២. ពេលភ្ញៀវចូលដល់ក្នុងផ្ទះ គន្ធាបាននាំភ្ញៀវអង្គុយកន្លែងដ៏គួរសម រួចនាងចូលទៅចាក់ទឹកមួយកែវយកមកជូនភ្ញៀវ និងនិយាយដោយទឹកមុខញញឹម ៖ " លោកអ៊ំ ! អញ្ជើញពិសាទឹក "។



www.elibraryofcambodia.org

៣. ពេលឪពុកម្ដាយនាងកំពុងសន្ទនាជាមួយភ្ញៀវ ប្អូនប្រុសនាងម្នាក់រត់រឹងបម្រុងទៅរកឪពុកម្ដាយ ស្រាប់តែឃើញឪពុកម្ដាយមានភ្ញៀវក៏ឱនក្បាលគោរពបន្ដិចរួចត្រឡប់ថយក្រោយវិញ ។

៤. បានជាឪពុកម្ដាយនាងពោលពាក្យសរសើរគន្ធា ព្រោះនាងចេះពន្យល់ប្អូននាង កុំឱ្យរត់កាត់មុខភ្ញៀវ ឬទៅរឹទានពុកម៉ែ ដែលកំពុងសន្ទនាជាមួយភ្ញៀវ។

៥. ខ្ញុំចង់យកតម្រាប់តាមកុមារីគន្ធា ព្រោះនាងជាកូនល្អដែលចេះគួរសមចំពោះភ្ញៀវ និងធ្វើឱ្យឪពុកម្ដាយសប្បាយចិត្តដោយសារសីលធម៌ល្អរបស់នាង។

៦. រឿងនេះកើតឡើងនៅផ្ទះនាងគន្ធា វេលារសៀលនៃថ្ងៃអាទិត្យមួយ។

៧. រឿងនេះមានព្រឹត្តិការណ៍សំខាន់១បី ៖

- ភ្ញៀវមកលេងនៅផ្ទះឪពុកម្ដាយគន្ធា។
- ប្អូនប្រុសនាងរត់ទៅរកឪពុកម្ដាយស្រាប់តែឃើញឪពុកម្ដាយមានភ្ញៀវក៏ឱនក្បាលគោរព។
- គន្ធាណែនាំប្អូនឱ្យចេះគួរសម កុំរត់កាត់មុខភ្ញៀវ ឬទៅរឹទានពុកម៉ែពេលមានភ្ញៀវ ។


www.elibraryofcambodia.org

វិញ្ញាសាទី ១៤

# រឿង ម្ជុលឃ្មារាំង



កាលពីដើម មានយុវជនម្នាក់ឈ្មោះកំសាន្ត កំព្រាឪពុកតាំងពីតូច។ កំសាន្តខិតខំតស៊ូពុះពារការលំបាកគ្រប់បែបយ៉ាង រហូតបានបញ្ចប់ការសិក្សាផ្នែកធនាគារ។

ថ្ងៃមួយ កំសាន្តបានទៅដាក់ពាក្យសុំចូលធ្វើការនៅធនាគារមួយ។ ពេលទៅដល់កំសាន្តលើកដៃសំពះដោយសុភាព រួចហុចពាក្យសុំចូលធ្វើការទៅលោកនាយកធនាគារ។ លោកនាយកពិនិត្យមើលរួចហុចពាក្យនោះ ឱ្យមកកំសាន្តវិញព្រមទាំងប្រាប់ថា លោកស្ដាយណាស់ដោយនៅពេលនេះ មានបុគ្គលិកគ្រប់គ្រាន់ហើយ បើលោកត្រូវការបុគ្គលិកបន្ថែមទៀតលោកនឹងឱ្យដំណឹង។ កំសាន្តក៏សំពះលាត្រឡប់មកវិញ។


www.elibraryofcambodia.org

ពេលកំពុងដើរត្រឡប់មកវិញ កំសាន្តឃើញម្ជុលបារាំងមួយកំពើស ចុក។ ឃើញកាយវិការដូច្នេះ លោកនាយកគិតក្នុងចិត្ត ៖ " យុវជននេះ មានសណ្ដាប់ធ្នាប់ល្អ និងមានគំនិតចេះសន្សំសំចៃ "។ លោកនាយកបាន ឱ្យកំសាន្តមកធ្វើការជាមួយគាត់។ មួយឆ្នាំបន្ទាប់ កំសាន្តត្រូវបានតែងតាំង ជានាយករងធនាគារនោះទៅ។

## សិក្សាលើមិញ្ញាសាទី ១៤

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " កំព្រា បញ្ចប់ ធនាគារ សុភាព នាយក ហុច ស្ពាយ កាយវិការ តែងតាំង "។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " បន្ថែម សន្សំសំចៃ "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " សុភាព "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " និង "។

### ខ. សំណួរ

១. តើកំសាន្តដាក់ពាក្យសុំទៅធ្វើការនៅកន្លែងណា ?

២. តើបានសម្រេចឬទេពីដំបូង ?

៣. ក្រោយមក ហេតុអ្វីបានជានាយកធនាគារ សម្រេចចិត្តឱ្យកំសាន្ត ធ្វើការវិញ ?

៤. តើអ្នកណាជាតួអង្គឯកនៅក្នុងរឿងនេះ ?

៥. តើរឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗប៉ុន្មាន ? គឺអ្វីខ្លះ ?

៦. តើរឿងនេះ កើតនៅពេលណា ? នៅឯណា ?



www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ១៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កំព្រា (គុ. ឬន.)៖ មនុស្សសត្វដែលឥតម្ដាយ ឥតឪពុក។ ឧ. មនុស្សកំព្រា កំព្រាឪពុក កំព្រាម្ដាយ។
- បញ្ចប់ (កិ.) ៖ ធ្វើឱ្យចប់។ ឧ. បញ្ចប់រឿង បញ្ចប់សេចក្ដីតែប៉ុណ្ណេះ ។
- ធនាគារ (ន.) ៖ ឃ្លាំងដាក់ទ្រព្យ ឃ្លាំងប្រាក់។ ឧ. ផ្ញើប្រាក់ក្នុងធនាគារ ។
- សុភាព (ន.) ៖ ភាពជាសុខ សេចក្ដីសុខ។
- នាយក (ន.) ៖ អ្នកនាំ អ្នកដឹកនាំ អ្នកត្រួតត្រា។ ឧ. អ្នកនាយក ឥតមានអ្នកនាយកលើ។
- ហុច (កិ.) ៖ ចាប់កាន់អ្វីៗដោយដៃតែម្ខាងប្រយោល។ ឧ. ហុចដៃឱ្យចាប់។
- ស្ដាយ (កិ.) ៖ នឹកអាល័យ នឹកឃើញហើយមិនអស់ចិត្ត មិនអស់អាល័យ ជំពាក់ដោយអាល័យ។ ឧ. ស្ដាយទ្រព្យ ខ្ញុំស្ដាយណាស់ដោយមិនបានទៅ ... ។
- កាយវិការ (ន.) ៖ ការកម្រើកនៃកាយ ចលនានៃកាយ ។



www.elibraryofcambodia.org

- តែងតាំង (កិ.) ៖ តាំងឱ្យមានមុខងារ ឬមុខតំណែងជាអ្វីៗ រៀបចំលើកតម្កើងឱ្យមានឋានន្តរស័ក្តិខ្ពង់ខ្ពស់...។ *ឧ.* តែងតាំងលោក ... ជារដ្ឋមន្ត្រីក្រសួងកសិកម្ម ។

២.បដិសព្ទ

- បន្ថែម ≠ បន្ថយ
- សន្សំសំចៃ ≠ ខ្ជះខ្ជាយ

៣.វេវចនសព្ទ

- សុភាព ទន់ភ្លន់ រាបទាប រៀបរយ ចុះចែបបទ ស្លូតបូត។

៤.សមិសសព្ទ

- និង (ធិ.) ៖ សព្ទជាសន្ធាន សម្រាប់និយាយតពាក្យ ឬតឃ្លាល្បះពីមួយទៅមួយដែលមានដំណើរសេចក្តីថា ទាំង ព្រមទាំង ផង នេះផងនុះផង។ *ឧ.* អ្នកនិងខ្ញុំ គោនិងក្របី។
- នឹង (កិ.នុ.) ៖ ពាក្យជាកិរិយានុគ្រោះសម្រាប់និយាយនាំមុខកិរិយាសព្ទប្រាប់អនាគតកាលទៅខាងមុខថាមុខជា ប្រាកដជា គង់, គង់តែ។ *ឧ.* ស្អែកនឹងទៅផ្ទះអ្នក យើងគង់តែនឹងបានជួបគ្នាទៀតក្នុងថ្ងៃណាមួយពុំខាន ។


www.elibraryofcambodia.org

- នឹង(គុ. ឬកិ.វិ.) ៖ ស្ងៀម ល្មើយ មិនកម្រើក។ *ឧ.* អង្គុយនឹងថ្កល់ គឺអង្គុយនឹងដូចគេថ្កល់ ។ មិនប្រែប្រួល មិនឡើងមិនចុះ នៅដូចដដែល។ *ឧ.* ជំងឺនុំះនៅនឹង។ ទឹកនឹង គឺទឹកដែលមិនឡើងមិនស្រក ឬមិនហូរ។
- នឹង (អា.និ.) ៖ ពាក្យប្រាប់ដំណើរសម្រេចនូវអំពើ សម្រាប់ប្រើនិយាយនាំមុខនាមស័ព្ទ មានន័យថា ដោយ ជាមួយ ដោយសារ ឲ្យដំ នៅត្រង់។ *ឧ.* ដួសសម្លនឹងវែក ដាំបាយនឹងឆ្នាំង។

## ខ. ចម្លើយ

១. កំសាន្តដាក់ពាក្យសុំទៅធ្វើការនៅធនាគារមួយ។

២. ពីដំបូងមិនបានសម្រេចទេ។

៣. ក្រោយមក បានជានាយកធនាគារសម្រេចចិត្តឱ្យកំសាន្តធ្វើការវិញ ដោយលោកមើលឃើញពីកាយវិការល្អរបស់កំសាន្ត ក្នុងការរើសម្ជុលបារាំងមួយ ចាត់ទុកជាមនុស្សមានសណ្ដាប់ធ្នាប់ល្អ និងមានគំនិត ចេះសន្សំសំចៃ។

៤. កំសាន្ត ជាតួអង្គឯកនៅក្នុងរឿងនេះ។

៥. រឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗបី គឺ ៖

- កំសាន្តដាក់ពាក្យសុំធ្វើការនៅធនាគារមួយ។
- កំសាន្តឃើញម្ជុលបារាំងមួយ ក៏រើសទុក។
- លោកនាយកធនាគារបានឱ្យកំសាន្តមកធ្វើការជាមួយគាត់។

៦. រឿងនេះ កើតឡើងនៅថ្ងៃមួយ នៅធនាគារមួយ ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ១៥ ការផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់




សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម។ អាស្រ័យហេតុនេះហើយ បានជារាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រីកដំណាំឧស្សាហកម្មស្ទើរគ្រប់ទីកន្លែង។ ក្រសួងកសិកម្ម ក៏បានយកចិត្តទុកដាក់ផ្សព្វផ្សាយ និងពន្យល់ដល់កសិករឱ្យខំដាំដំណាំផ្សេងៗដែលបម្រើឱ្យឧស្សាហកម្ម។ ជាក់ស្តែងកាលពីចុងខែមិថុនា ឆ្នាំ២០០៧ កន្លងទៅនេះបុគ្គលិកមន្ទីរកសិកម្មខេត្តកំពង់ចាម បានចុះទៅសួរសុខទុក្ខប្រជាជនក្នុងស្រុកក្រូចឆ្មារ ដែលនិយមដាំដំណាំថ្នាំជក់តាំងពីយូរណាស់មកហើយ។ ជាមួយនេះដែរ អស់លោកបានពន្យល់ពីផលអាក្រក់នៃការដាំថ្នាំជក់។ ពួកគាត់បានពន្យល់ថា ការដាំថ្នាំជក់ទាមទារពលកម្មខ្លាំង និងចំណាយប្រាក់ច្រើនសម្រាប់ទិញជី និងថ្នាំសម្លាប់សត្វល្អិត ចំណែកផល


www.elibraryofcambodia.org

ទទួលបាន មិនចំណេញប៉ុន្មានឡើយ។ម្យ៉ាងទៀត អ្នកដាំថ្នាំជក់រងគ្រោះថ្នាក់ក្នុងការងារជាច្រើនដោយការប៉ះពាល់ថ្នាំសម្លាប់សត្វល្អិត និងការពុលដោយសារធាតុគីមី ពុលនីកូទីន។ កុមារ និងមនុស្សពេញវ័យ ច្រើនទទួលរងគ្រោះដោយការជ្រាបចូលនៃនីកូទីនតាមស្បែក នៅពេលពួកគេប៉ះពាល់ស្លឹកថ្នាំជក់ ធ្វើឱ្យគេចង់ក្អួតឈឺក្បាល ពិបាកដកដង្ហើម អស់កម្លាំង វិលមុខ។ល។ បន្ថែមលើនេះទៀត កសិករត្រូវកាប់បំផ្លាញព្រៃឈើយ៉ាងច្រើន ដើម្បីយកមកសម្ងួត និងចំហុយស្លឹកថ្នាំ ដែលជាហេតុធ្វើឱ្យជាតិខាតបង់យ៉ាងច្រើន ។

នៅទីបញ្ចប់ គេបានណែនាំប្រជាកសិករឱ្យងាកមកដាំដំណាំកសិឧស្សាហកម្ម មានដំឡូង អំពៅ ល្ហុងខ្វង់ ស្វាយចន្ទីវិញ ព្រោះវាផ្ដល់ប្រាក់ចំណូលច្រើនជាងការដាំថ្នាំជក់ ហើយមិនបង្កគ្រោះថ្នាក់ទៀតផង។

## សិក្សាលើវិញ្ញាសាទី ១៥

### ក.រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ "កសិកម្ម ទាមទារ ល្ហុងខ្វង់ ស្វាយចន្ទី ចំហុយ "។
២. ចូររកបដិសព្ទនឹងពាក្យ ៖ " លើ ទុក្ខ យូរ ចំណាយ "។
៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " ពុល សុខ "។
៤. ដូចម្ដេចដែលហៅថានាមអសាធារណ៍ ? ចូររកឧទាហរណ៍ពីក្នុងអត្ថបទនេះឱ្យបាន៨ពាក្យ ។

### ខ. សំណួរ

១. តើអ្នកណាចុះពន្យល់ប្រជាកសិករនៅស្រុកក្រូចឆ្មារ ?
២. តើបុគ្គលិកកសិកម្មបានពន្យល់ពីផលអាក្រក់ ចំពោះអ្នកដាំថ្នាំជក់ដូចម្ដេចខ្លះ ?


www.elibraryofcambodia.org

៣. តើកុមារ និងមនុស្សពេញវ័យច្រើនទទួលរងគ្រោះពីថ្នាំជក់យ៉ាងណាខ្លះ ?
៤. តើគេបានណែនាំប្រជាកសិករឱ្យប្ដូរពីដំណាំថ្នាំជក់ ទៅជាដំណាំអ្វីខ្លះ ? ព្រោះអ្វី ?
៥. តើចំណុចណានៃអត្ថបទ ដែលបញ្ជាក់ថាជាអត្ថបទពិតកថា ឬរឿងពិត ?

## កំណែវិញ្ញាសាទី ១៥

### ក. រៀនពាក្យ

#### ១. ពន្យល់ពាក្យ

- កសិកម្ម (ន.) ៖ ការភ្ជួររាស់ ការងារដែលគេប្រកបក្នុងការភ្ជួររាស់ គឺការធ្វើស្រែចម្ការ ។
- ទាមទារ (កិ.) ៖ ទាមផងទារផង ទារដោយទាមចំណែក ឬទារតភ័យករបស់ មតិកខ្លួនជាកេរ្តិ៍ដំណែលឱ្យបានមកខ្លួនវិញ។
- ល្ហុងខ្វង (ន.) ៖ រុក្ខជាតិមួយប្រភេទមានដើមស្រលូតបែកមែកច្រើនស្លឹកតូចៗឥតឆែកប្រៅធាងខ្លីៗឥតប្រហោង ផ្លែមូលៗរលីងកាត់ដើមដាំដុះ សម្រាប់ដាំធ្វើរបង គ្រាប់ស្លប្រេងបាន។ ន. របងល្ហុងខ្វង។
- ស្វាយចន្ទី (ន.) ៖ ឈើមួយប្រភេទស្លឹកខ្ចីប្រើជាបោយ ឬជាអន្លក់បាន ,ផ្លែលៀនចុងគ្រាប់លេចចេញមកខាងក្រៅ វេលាទុំមានក្លិនក្រអូបឆ្ងួលឆ្ងិតបន្តិច មានជ័របន្តិចៗប្រើការបរិភោគបាន។


www.elibraryofcambodia.org

- ចំហុយ (កិ.) ៖ កម្ដៅ ឬចម្អិនដោយចំហាយទឹកក្ដៅដែលហុយឡើង។ ឧ. ចំហុយបាយដំណើប, ចំហុយត្រី ។
- ចំហុយ (គុ.) ៖ ដែលឆ្អិនដោយចំហុយ។ ឧ. បាយចំហុយ, ពោតចំហុយ, ត្រីចំហុយ ។

២.បដិសព្ទ

- លើ ≠ ក្រោម
- ទុក្ខ ≠ សុខ
- យូរ ≠ឆាប់
- ចំណាយ ≠ ចំណូល

៣.សទិសសព្ទ

- ពុល (គុ.) ៖ ដែលមានពិសអាចបណ្ដាលឱ្យរាប់រយើ ឱ្យក្អួតចង្អោរ ឬធ្វើទុក្ខខ្លាំងដល់ឈឺស្លាប់ក៏មាន។ ឧ. ផ្សិតពុល, ថ្នាំពុល, គ្រឿងពុល ។
- ពល (ន.) ៖ កម្លាំង។ សេនា ទាហាន កងទ័ព។ ឧ. កុំពលលើកពល។
- សុខ (ន.) ៖ សេចក្ដីសុខសាន្ត សុខទុក្ខគ្រប់ប្រការ។
- សុខ (គុ.) ៖ ដែលសប្បាយ ងាយស្រួល ស្រណុក សម្រាន្ត។
- សុក (ន.) ៖ ស្រោមស្រោបកូនដែលនៅក្នុងផ្ទៃម្ដាយ មានទងជាប់នឹងផ្ចិតទារក។
- សុក្រ (ន.) ៖ ឈ្មោះថ្ងៃទី៦ នៃសប្ដាហ៍។

៤. នាមអសាធារណ៍ គឺជាពាក្យសម្គាល់មនុស្ស សត្វ វត្ថុ និងទីកន្លែងដោយចំពោះ មិនទូទៅ។ ឧ. កម្ពុជា កំពង់ចាម ក្រូចឆ្មារ នីកូទីន។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. អ្នកដែលចុះពន្យល់ប្រជាកសិករនៅស្រុកក្រូចឆ្មារ គឺបុគ្គលិកមន្ទីរកសិកម្មខេត្តកំពង់ចាម។

២. បុគ្គលិកកសិកម្ម បានពន្យល់ពីផលអាក្រក់ចំពោះអ្នកដាំថ្នាំជក់ថា អ្នកដាំថ្នាំជក់រងគ្រោះថ្នាក់ក្នុងការងារជាច្រើន ដោយការប៉ះពាល់ថ្នាំសម្លាប់សត្វល្អិត និងការពុលដោយសារធាតុគីមី ពុលនីកូទីន។

៣. កុមារ និងមនុស្សពេញវ័យច្រើនទទួលរងគ្រោះដោយការជ្រាបចូលនៃនីកូទីនតាមស្បែកនៅពេលពួកគេប៉ះពាល់ស្លឹកថ្នាំជក់ ធ្វើឱ្យគេចង់ក្អួតឈឺក្បាលពិបាកដកដង្ហើមអស់កម្លាំងវិលមុខ។

៤. គេបានណែនាំប្រជាកសិករ ឱ្យប្តូរពីដំណាំថ្នាំជក់ទៅជាដំណាំកសិនស្បាហកម្មវិញ គឺដំឡូង អំពៅ ល្ហុងខ្វង ស្វាយចន្ទី ព្រោះវាផ្តល់ប្រាក់ចំណូលច្រើនជាងការដាំថ្នាំជក់ និងមិនបង្កគ្រោះថ្នាក់ទៀតផង។

៥. ចំណុចនៃអត្ថបទ ដែលបញ្ជាក់ថាជាអត្ថបទពិតកថា ឬរឿងពិតគឺអត្ថបទនេះបានប្រាប់ពី៖

- ទីកន្លែងពិត ខេត្តកំពង់ចាម ស្រុកក្រូចឆ្មារ
- ព្រឹត្តិការណ៍ពិត ចុងខែមិថុនាឆ្នាំ២០០៧ បុគ្គលិកមន្ទីរកសិកម្មខេត្តកំពង់ចាមបានចុះទៅសួរសុខទុក្ខប្រជាជនក្នុងស្រុកក្រូចឆ្មារ ដែលនិយមដាំដំណាំថ្នាំជក់តាំងពីយូរណាស់មកហើយ។


www.elibraryofcambodia.org

វិញ្ញាសាទី ១៦

# ដំណាំស្រូវ



ដំណាំសំខាន់បំផុតនៅប្រទេសកម្ពុជាគឺស្រូវ។ គេដាំស្រូវស្ទើរគ្រប់ទីកន្លែងទាំងអស់។ គេធ្វើស្រែពីរដងក្នុងមួយឆ្នាំ គឺស្រែវស្សា និងស្រែប្រាំង។ ស្រែប្រាំងគេចាប់ផ្ដើមធ្វើនៅពេលទឹកស្រក។ គេធ្វើស្រូវប្រាំងនៅតាមមាត់បឹង ទំនាបទន្លេ មាត់ព្រែក ឬស្ទឹងដែលមានទឹកពុំដាច់។ ប្រជាជនមួយចំនួន ពិសេសប្រជាជននៅខេត្តបាត់ដំបង បន្ទាយមានជ័យចូលចិត្តដាំស្រូវផ្កាម្លិះ ផ្កាខ្ញី នាងអំ ផ្ការំដួល ... ព្រោះស្រូវទាំងនោះមានឱជារសឆ្ងាញ់ពិសា។

បច្ចុប្បន្ន វិស័យកសិកម្មកាន់តែអភិវឌ្ឍ ប្រជាកសិករច្រើនធ្វើស្រូវប្រពលវប្បកម្មនិងស្ទូងស្រូវមួយដើមតាមការណែនាំរបស់ក្រសួងកសិកម្មដើម្បីសន្សំសំចៃពូជ និងទទួលបានផលច្រើន។ លើសពីនេះទៅទៀត


www.elibraryofcambodia.org

កសិករបានទទួលការណែនាំឱ្យប្រើជីធម្មជាតិ និងជីកំប៉ុស។ បច្ចុប្បន្ន កសិករមួយចំនួនបោះជំហានទៅប្រើគោយន្ត ដើម្បីភ្ជួរដី និងប្រើម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវជំនួសកម្លាំងគោក្របី។ ពួកគាត់ទទួលបានផលច្រើន ធ្វើឱ្យជីវភាពពួកគាត់ធូរធារជាលំដាប់។

## សិក្សាលើវិញ្ញាសាទី ១៦

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ស្រែវស្សា ស្រែប្រាំង ព្រែក ប្រពលវប្បកម្ម ជីធម្មជាតិ ជីកំប៉ុស " ។

២. ចូររកបដិសព្ទនឹងពាក្យ ៖ " ប្រពលវប្បកម្ម "។

៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " រស "។

៤. ចូរស្រង់នាមអសាធារណ៍នៅក្នុងអត្ថបទ ចំនួន៧ពាក្យ។

៥. ចូរអានអត្ថបទទាំងពីរកថាខណ្ឌ រួចជ្រើសរើសប្រធានបទរបស់កថាខណ្ឌនីមួយៗ។

- កថាខណ្ឌទី១ ៖
  - ក. ការលំបាកក្នុងការធ្វើស្រូវប្រាំង
  - ខ. ពេលវេលា ទីកន្លែងសម្រាប់ធ្វើស្រូវប្រាំង
  - គ. របៀបថែស្រូវប្រាំង។
- កថាខណ្ឌទី២ ៖
  - ក. ការអភិវឌ្ឍនៃវិស័យកសិកម្មទំនើប
  - ខ. ការធ្វើស្រូវប្រពលវប្បធម៌
  - គ. ការជីកប្រឡាយទឹក។



www.elibraryofcambodia.org

## ខ. សំណួរ

១. តើសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើអ្វី ?

២. តើនៅប្រទេសកម្ពុជា គេធ្វើស្រូវប៉ុន្មានដងក្នុងមួយឆ្នាំ ? អ្វីខ្លះ ?

៣. ហេតុអ្វីបានជាកសិករធ្វើស្រូវប្រពលវប្បកម្ម និងដំណាំស្រូវមួយដើម ?

៤. តើការប្រើជីធម្មជាតិ និងជីកំប៉ុសមានអត្ថប្រយោជន៍ដូចម្តេច ?

៥. តើកសិកម្មនៅកម្ពុជាមានការអភិវឌ្ឍដែរឬទេ ? ហេតុអ្វី ?

# កំណែវិញ្ញាសាទី ១៦

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- ស្រែវស្សា (ន.) ៖ ស្រែសម្រាប់ធ្វើស្រូវក្នុងរដូវវស្សា។
- ស្រែប្រាំង (ន.) ៖ ស្រែសម្រាប់ស្ទូងស្រូវក្នុងរដូវប្រាំង។
- ព្រែក (ន.) ៖ ជ្រលង ឬប្រឡាយធំជាផ្លូវទឹកតពីទន្លេទៅបឹង ឬពីទីឯទៀតចូលមកទន្លេ សមុទ្រ បើកើតដោយជីកហៅថា ព្រែកជីក ។
- ប្រពលវប្បកម្ម (ន.) ៖ ការធ្វើស្រែដែលមិនចាំបាច់រង់ចាំទឹកភ្លៀងធ្លាក់មក ទើបអាចធ្វើស្រែបាននោះទេ គឺមានប្រព័ន្ធប្រឡាយទឹកគ្រប់គ្រាន់ដែលមានទឹកជានិច្ចសម្រាប់ធ្វើស្រែគ្រប់រដូវ។


www.elibraryofcambodia.org

- ជីធម្មជាតិ (ន.) ៖ ជីលាមកសត្វ ជីកំប៉ុស ជីបន្លែរុក្ខជាតិ និងកាកសំណល់ពីផ្ទះបាយ រោងចក្រ ដែលអាចផុយរលួយធ្វើជាជីបាន។
- ជីកំប៉ុស (ន.) ៖ អំពុក ជីធម្មជាតិធ្វើពីរុក្ខជាតិរលួយ ឬអាចម៍សត្វ ... ឬអំពុកជីផ្សំដោយវត្ថុផ្សេងៗនឹងកំបោរធ្វើជាជី។

២. បដិសព្ទ

- ប្រពលវប្បកម្ម ≠ ឯកវប្បកម្ម

៣. សទិសសព្ទ

- រស (ន.) ៖ សម្មស្សផ្សេងៗ ដែលប៉ះពាល់ជិវ្ហាបសាទ ដឹងថាប្រៃ ជូរ ចត់ ល្វីង ផ្អែមជាដើម។ *ឧ.* រសប្រៃ រសជូរ រសផ្អែម អាហារមានរសឆ្ងាញ់ និជារស។
- រស់ (កិ.) ៖ មានជីវិតនៅ មិនទាន់ស្លាប់។ *ឧ.* បុគ្គលរស់នៅមួយរយ។

៤. ស្រង់នាមអសាធារណ៍នៅក្នុងអត្ថបទចំនួន៧ពាក្យ ៖ ប្រទេសកម្ពុជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ស្រូវផ្កាម្លិះ ស្រូវផ្កាខ្ញី ស្រូវនាងអំ ស្រូវផ្ការំដួល។

៥. អានអត្ថបទទាំងពីរកថាខណ្ឌ រួចជ្រើសរើសប្រធានបទរបស់កថាខណ្ឌនីមួយៗ ៖

- កថាខណ្ឌទី១ ៖

  ខ. ពេលវេលា ទីកន្លែងសម្រាប់ធ្វើស្រូវប្រាំង

- កថាខណ្ឌទី២ ៖

  ក. ការអភិវឌ្ឍនៃវិស័យកសិកម្មទំនើប



www.elibraryofcambodia.org

## ខ. ចម្លើយ

១. សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម ។

២. នៅប្រទេសកម្ពុជា គេធ្វើស្រូវពីរដងក្នុងមួយឆ្នាំ គឺស្រូវប្រាំង និងស្រូវវស្សា។

៣. បានជាកសិករធ្វើស្រូវប្រពលវប្បកម្ម និងដំណាំស្រូវមួយដើម ដើម្បីការសន្សំសំចៃពូជ និងទទួលបានផលច្រើន។

៤. ការប្រើជីធម្មជាតិ និងជីកំប៉ុសមានអត្ថប្រយោជន៍ដូចតទៅ ៖

- ជួយកែលម្អជីជាតិ និងផលិតភាពដី ដោយធ្វើឱ្យប្រសើរ
- បន្ថយការប្រើប្រាស់ជីគីមី និងប្រាក់ចំណាយក្នុងការទិញជី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ
- បន្ថយជាតិពុលនៃដី។

៥. កសិកម្មនៅកម្ពុជាមានការអភិវឌ្ឍ ដោយហេតុថាកសិករយើងបានឈានទៅប្រើគោយន្តដើម្បីភ្ជួរដីនិងប្រើម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវជំនួសកម្លាំងគោក្របី។


www.elibraryofcambodia.org

# រឿង ក្ងាន់ ក្អែក និងចចក



ក្ងាន់និងក្អែកជាមិត្តនឹងគ្នារស់នៅយ៉ាងសុខសាន្ត។ ថ្ងៃមួយ ចចកឃើញក្ងាន់ក៏ចូលទៅនិយាយបញ្ចុះបញ្ចូលទាល់តែក្ងាន់សុខចិត្ត។ សត្វទាំងពីរសុំគ្នាធ្វើជាមិត្ត។ ក្អែកដឹងពីល្បិចចចក ក៏ប្រាប់ក្ងាន់ឱ្យឈប់ទាក់ទងតែត្រូវក្ងាន់បដិសេធ។ ល្ងាចមួយ ចចកឃើញអន្ទាក់ព្រានក៏បបួលក្ងាន់ទៅរកស៊ីទីនោះ ដើម្បីឱ្យក្ងាន់ជាប់អន្ទាក់។ ក្ងាន់ជឿតាមចចកក៏ភ្លាត់ទៅជាប់អន្ទាក់ព្រាន។ ក្ងាន់ស្រែកហៅឱ្យចចកជួយ តែចចកធ្វើមិនឮក៏រត់ពួនក្នុងគុម្ពោតព្រៃចាំមើលក្ងាន់រើបម្រះអស់កម្លាំងវានឹងស៊ី។ ក្អែកពុំឃើញក្ងាន់ ខំហើររកក៏ប្រទះឃើញក្ងាន់ជាប់អន្ទាក់។ ក្អែកប្រាប់ក្ងាន់ឱ្យធ្វើពុតជាងាប់ នៅពេលព្រានមកដល់។ ពេលព្រានដោះអន្ទាក់រួច វានឹងធ្វើសញ្ញាឱ្យក្ងាន់ស្ទុះបោលឱ្យលឿន។ ព្រានមកដល់ឃើញក្ងាន់ជាប់អន្ទាក់ដេកស្ងូកក៏ដោះក្ងាន់ដាក់ទៅម្ខាង។ ក្អែកឃើញដូច្នោះ ក៏ស្រែកខ្វាកៗ។


www.elibraryofcambodia.org

ក្ងាន់ស្ទុះបោលចូលទៅក្នុងព្រៃ។ ព្រានក៏ស្ទុះទៅយកលំពែងពួយសំដៅក្ងាន់ តែផ្ទួនជាចំកន្លែងចចកសម្ងំនៅ។ លំពែងនោះធ្លាក់ត្រូវចចកមរណានាពេលនោះទៅ។

*(ដកស្រង់និងកែសម្រួលចេញពីគតិលោកភាគ៥)*

## សិក្សាលើនិទានទី ១៧

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យ ៖ " ក្ងាន់ ក្អែក ចចក បដិសេធ អន្ទាក់ ភ្ញាត់ តុម្ពោត បោល ស្លូត ខ្វក លំពែង " ។

២. ចូររកវេវចនសព្ទនឹងពាក្យ ៖ " មរណា ស្ទុះ "។

៣. ចូររកបរិភាសព្ទនឹងពាក្យ ៖ " សុខសាន្ត ស្ទុះស្ទា "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ពុត ពួយ "។

### ខ. សំណួរ

១. តើចចកនិយាយបញ្ចុះបញ្ចូលក្ងាន់ពីអ្វី ? បានសម្រេចឬទេ ?

២. ហេតុដូចម្ដេចបានជាក្អែក ឱ្យក្ងាន់ឈប់ទាក់ទងនឹងចចក ? តើក្ងាន់យល់ព្រមដែរឬទេ ?

៣. តើចចកមានបំណងយ៉ាងណា ទើបបបួលក្ងាន់ឱ្យទៅរកស៊ីក្បែរអន្ទាក់ ?

៤. តើក្ងាន់រួចផុតពីក្ដីស្លាប់ឬទេ ? ព្រោះអ្វី ?

៥. ចូរអ្នកបង្ហាញពីសកម្មភាពរបស់សត្វក្អែក និងសកម្មភាពរបស់សត្វចចក។

៦. តើយើងគួរយកតម្រាប់តាមសត្វណា ? មិនយកតម្រាប់តាមសត្វណា ? ព្រោះអ្វី ?


www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ១៧

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ក្ដាន់ (ន.) ៖ ឈ្មោះម្រឹគមួយប្រភេទ មានស្នែងម្ខាងៗ បែកខ្នែងជា ៣ ដូចជាប្រើស តែរូបតូចជាងប្រើស សម្បុរកំឧសខ្មាពីប្រើស ។
- ក្អែក (ន.) ៖ ឈ្មោះបក្សីមួយប្រភេទ សម្បុរខ្មៅសុទ្ធ ដំណើរលោតៗ ច្រើនបរិភោគអសុភជាអាហារ។ ឈ្មោះត្រីមួយប្រភេទ មានស្រកាសម្បុរខ្មៅប្រផេះ រង្វង់មាត់តូច។ ឧ. ត្រីក្អែក។ ឈ្មោះតាសក់ពុលមួយប្រភេទ ផ្លែរាងមូលទុំឡើងពណ៌ក្រហម។ គ្រសក់ក្អែក។
- ចចក (ន.) ៖ ឈ្មោះសត្វជើង ៤ សន្ដានឆ្កែព្រៃ។
- បដិសេធ(កិ.) ៖ ឃាត់ ហាម លើកចោល ឬទាត់ចោលលែងយកជាការ លែងរាប់អាន។ ឧ. បដិសេធពាក្យ បដិសេធសេចក្ដី បដិសេធរឿងហេតុ។
- បដិសេធន៍(ន.)៖ ការឃាត់ ការហាម ដំណើរលើកចោល ឬទាត់ចោលលែងយកជាការ លែងរាប់អាន។ ឈ្មោះវណ្ណយុត្តមួយប្រភេទ (ម.ព. ទណ្ឌឃាដ ឬទណ្ឌឃាត)។
- អន្ទាក់ (ន.) ៖ ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្ដៅជាដើម មានក្រវិលរូតបាន សម្រាប់ទាក់ សម្រាប់ដាក់ឱ្យជាប់សត្វទ្វេបាទចតុប្បាទជាដើម។ ឧ.សត្វជាប់អន្ទាក់។


www.elibraryofcambodia.org

- ភ្លាត់ (កិ.) ៖ ច្រុល ច្រលូស លង់ស៊ិន ទាស ទាស់ ខុសទំនង ឃ្លាត ស៊ិនហួស។
ឧ. ភ្លាត់គំនិត ភ្លាត់ជើង ភ្លាត់ដៃ ភ្លាត់មាត់ ។ ភ្លាត់ចំណាប់ ភ្លាត់ដោយចាប់មិនស៊ប់ មិនមាំ ។
- គុម្ពោត (បា.) (ន.) ៖ គុម្ពឈើតូចៗ ដែលដុះជុំគ្នាទង់ៗ។
ឧ. គុម្ពោតឈើ ។
- ពោល (កិ.) ៖ រត់ពោលជើងទាំង ៤ ពេញទំហឹង។
ឧ. គោពោល ក្របីពោល ។
- ស្លូក (កិ.វិ. ឬ គុ.) ៖ ស្ងឹង ភ្លឹង រាបនៅទីផ្ទៃឥតកម្រើក។
ឧ. ដេកស្លូក ផ្អែកស្លូក រឹងស្លូក វែងស្លូក។ ស្លូកស្ងឹង ស្លូកសម្លឹងភ្លឹង ឥតកម្រើក ។
- ខ្វក (ន.) ៖ សួរសម្រែកក្អែក។ ឧ. ក្អែកយំឮខ្វកៗ។
- លំពែង (ន.) ៖ គ្រឿងសាស្ត្រាសម្រាប់ចាក់ សម្រាប់ពួយមានមុខទាំងពីរខាង មានចុងស្រួចរូបសណ្ឋានដូចព្រះខ័ន តែដងវែង។
ឧ. ថ្លៃលំពែង។

## ២. វេវចនសព្ទ

- មរណា ស្លាប់ ងាប់ ខូច អនិច្ចកម្ម ក្សិណក្ស័យ លាចាកលោក ចែកឋាន សុគត សោយទិវង្គត
- ស្ទុះ រត់ ពោល សម្រុកទៅមុខ។


www.elibraryofcambodia.org

៣. បរិវារសព្ទ

- សុខសាន្ត ៖ " សាន្ត " អាចគន្លាស់បានជាពាក្យ " សាន្ត " ស្ងប់ក្សេមក្សាក គឺ - សុខ - ស្ងប់ក្សេមក្សាន្ត។
- ស្ទុះស្ទា ៖ " ស្ទា " អាចគន្លាស់បានជាពាក្យ " ស្ទា " ឆ្វាចុះឆ្វាឡើងដោយម្ចាម្ទុះ គឺ " ស្ទុះ " ឆ្វាចុះឆ្វាឡើងដោយម្ទឹម្ចា។

៤. សទិសសព្ទ

- ពុត (ន.) ៖ ដំណើរបាំងទោសខ្លួន ដំណើររបិញរបុញ កិច្ចកលមាយា ការក្លែងបង្វែងដំណើរឱ្យឃ្លាតចាកសេចក្ដីពិតដូចយ៉ាងមិនឈឺក្លែងធ្វើឈឺជាដើម។ *ឧ.* មានពុត ដេញពុត។ ប្រើជា កិ. ក៏បានខ្លះ។ *ឧ.* ភពុតធ្វើជាឈឺ។
- ពុធ (ន.) ៖ អ្នកមានប្រាជ្ញា អ្នកប្រាជ្ញ ។ ឈ្មោះថ្ងៃទី ៤ (ក្នុងសប្ដាហ៍)។ *ឧ.* ថ្ងៃពុធ (ហៅតាមឈ្មោះផ្កាយពុធ) ... ។
- ពត់ (កិ.) ៖ បត់បំបែរ ធ្វើឱ្យងាកបែរ តម្រង់ បង្កោង បង្អុងតាមបំណង គឺវៀចឱ្យត្រង់ ឬធ្វើវត្ថុត្រង់ឱ្យវៀចឱ្យកោងជាដើម។ *ឧ.* ពត់ព្រួញ, ពត់ឈើកុង។
- ពួយ (កិ.) ៖ ចោលឡោង ឬបោះគ្រឿងសស្ត្រា ឬអាវុធសំដៅអ្វីៗ។ *ឧ.* ពួយលំពែង ពួយដំបង ។
- ពួយ (ន.) ៖ ចម្រឹងឈើ ឬឫស្សីស្រួចដែលគេបោះភ្ជាប់នឹងសម្បកដើមឈើធំ ធ្វើដូចជាបង្ហោង ដើម្បីគោងជាន់ឡើងយកឃ្មុំជាដើម។ *ឧ.* ឡើងតាមពួយ ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ចចកនិយាយបញ្ចុះបញ្ចូលក្ដាន់ពីការសុំគ្នាធ្វើជាមិត្ត បានសម្រេច។

២. បានជាក្អែកឱ្យក្ដាន់ឈប់ទាក់ទងចចក មកពីក្អែកដឹងពីល្បិចចចក ក្ដាន់មិនយល់ព្រមទេ។

៣. ចចកមានបំណងឱ្យក្ដាន់ជាប់អន្ទាក់ ទើបបបួលក្ដាន់ឱ្យទៅរកស៊ីក្បែរអន្ទាក់។

៤. ក្ដាន់រួចផុតពីក្ដីស្លាប់ ព្រោះបានក្អែកជួយរកវិធី ឱ្យរួចផុតពីដៃព្រាន។

៥. បង្ហាញពីសកម្មភាពរបស់ ៖

ក. សត្វក្អែក យល់ដឹងពីល្បិចចចក មានគំនិតឈ្លាសវៃចេះជួយក្ដាន់ឱ្យរួចពីដៃព្រាន។

ខ. ចចក ល្បិច ពុតត្បុត មិនស្មោះត្រង់ រង់ចាំយកចំណេញពីមិត្តភក្តិ។

៦. យើងគួរយកតម្រាប់តាមសត្វក្អែក មិនយកតម្រាប់តាមសត្វចចកទេ ព្រោះសត្វក្អែកមានចិត្តស្មោះត្រង់ ចេះជួយមិត្តភក្តិក្នុងគ្រាមានអាសន្ន។ ចំណែកសត្វចចកវិញ មិនស្មោះត្រង់ចង់បានប្រយោជន៍ពីមិត្តភក្តិ មិនជួយទុក្ខធុរៈមិត្តភក្តិពេលមានអាសន្ន។


www.elibraryofcambodia.org

វិញ្ញាសាទី ១

# តែងសេចក្តីបែបពិពណ៌នា អំពីមនុស្ស

## ក.ការណែនាំទូទៅ

ការពណ៌នាអំពីមនុស្ស ចាំបាច់ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីភិនភាគរបស់មនុស្ស ធ្វើយ៉ាងណាឱ្យអ្នកអានស្គាល់រូបរាងមនុស្សដែលលើកយកមកនិយាយនោះពិតប្រាកដ។

ការពណ៌នាអំពីមនុស្ស គេត្រូវប្រើការនឹកឃើញពីរូបរាង សកម្មភាព ឥរិយាបថ ព្រមទាំងចរិយារបស់មនុស្សណាម្នាក់ ដែលយើងធ្លាប់ស្គាល់ ឬធ្លាប់បានឃើញកន្លងមក ដើម្បីរៀបរាប់ឡើងវិញក្នុងការបង្ហាញឱ្យអ្នកអានបានស្គាល់ ឬហាក់ដូចជាបានឃើញផ្ទាល់នឹងភ្នែកតាមរយៈពាក្យសម្ដី ឬសំណេររបស់យើងនោះតែម្ដង ។

ចំពោះការពណ៌នានេះ ត្រូវឈរលើលក្ខណៈសំខាន់ពីរយ៉ាង ៖

### ១. ពណ៌នារូបសម្បត្តិ

- ត្រូវសង្កេតពិនិត្យលើភិនភាគ ឬរូបរាងខាងក្រៅដែលជាលក្ខណៈទូទៅឱ្យបានច្បាស់លាស់មាន អាយុ មាន កម្ពស់ សម្បុរ ...ដូចជា ក្មេង ឬចាស់ ធំ ឬតូច ខ្ពស់ ឬទាប ខ្មៅ ឬស ... ។
- ត្រូវនិយាយអំពីផ្នែកផ្សេងៗ នៃរាងកាយរបស់មនុស្ស ដែលយើងលើកយកមកពណ៌នា ដូចជា ទម្រង់មុខ ច្រមុះ ភ្នែក ត្រចៀក ចង្កា និងដៃ ជើងជាដើម ។


www.elibraryofcambodia.org

- ត្រូវអធិប្បាយបន្ថែមទៀត អំពីសម្លៀកបំពាក់ គ្រឿងតុបតែងខ្លួនឬប្រដាប់ប្រើប្រាស់ផ្សេងៗ ដែលមាននៅនឹងខ្លួនមនុស្សទៅតាមប្រភេទបុគ្គល ដូចជាកងរាជអាវុធហត្ថ ស្លៀកពាក់ខុសពីនគរបាលជាតិ រីឯគ្រូពេទ្យស្លៀកពាក់ខុសពីយោធាជាដើម។
- ត្រូវបង្ហាញអំពីឥរិយាបថ ដើរ ដេក អង្គុយ ឈរ ... ។

## ២.កំណត់សម្គាល់

- ដើម្បីធ្វើពណ៌នាអំពីរូបសម្បត្តិនេះ ឱ្យកាន់តែច្បាស់លាស់ត្រូវធ្វើការប្រៀបធៀបទៅនឹងអ្វី ដែលមានរូបរាងប្រហាក់ប្រហែលដូចគ្នា ឬផ្ទុយគ្នា ។ **ឧ.** កុមារីនេះស្រស់គ្រហាញដូចផ្ការីក ។
- ដើម្បីធ្វើពណ៌នាពីរូបសម្បត្តិឱ្យកាន់តែបានល្អ ត្រូវភ្ជាប់រូបសម្បត្តិទៅនឹងចរិយាសម្បត្តិ ។ **ឧ.** កុមារនេះមានថ្ងាសទូលាយ ភ្នែកខ្មៅថ្លា ជាក្មេងមានបញ្ញាវៃឆ្លាត និងទឹកចិត្តទូលាយ ។

## ៣.ពណ៌នាអំពីចរិយាសម្បត្តិ

ការធ្វើពណ៌នាអំពីចរិយាសម្បត្តិ ត្រូវលើកចំណុចពីរមកបង្ហាញ ៖

- គុណសម្បត្តិ ៖ ប្រាជ្ញា សមត្ថភាព ទម្លាប់ល្អ ភាពម៉ត់ចត់ ការឧស្សាហ៍ព្យាយាម ។
- គុណវិបត្តិ ៖ ខ្ជិលច្រអូស ព្រហើន កោងកាច រៀចរេវ ... ។

***កំណត់សម្គាល់***

- ការពណ៌នាអំពីរូបសម្បត្តិ ត្រូវភ្ជាប់ទៅនឹងចរិយាសម្បត្តិ ព្រោះទាំងពីរផ្នែកនេះឆ្លុះបញ្ចាំង និងបំពេញឱ្យគ្នាទៅវិញទៅមក ។
- ត្រូវមានបំណិនប្រសប់ក្នុងការជ្រើសរើសរកចំណុច ឬលក្ខណៈសំខាន់ៗដទៃទៀតមករៀបរាប់តាមលំដាប់លំដោយ ដោយប្រើពាក្យពេចន៍ឃ្លា ល្បះឱ្យបានត្រឹមត្រូវ និងរស់រវើក។


www.elibraryofcambodia.org

## ខ.គម្រោងតែង

### ១.សេចក្តីផ្តើម

បង្ហាញពីមនុស្សនោះដោយប្រាប់ ៖

- ឈ្មោះ ...
- ភេទ ...
- អាយុ ...
- ទីលំនៅ ( ផ្ទះលេខ ផ្លូវ ក្រុម ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ រាជធានី/ខេត្ត )
- មុខរបរ ... ។

### ២.តួសេចក្តី

- រូបសម្បត្តិ

  រូបរាង ៖

  - មាឌ ( តូច ធំ ស្គម ធាត់ ... )
  - កម្ពស់ ( ទាប ខ្ពស់ ... )
  - សម្បុរ ( ស ខ្មៅ ស្រអែម ... )
  - មុខមាត់ ( ភ្នែក ច្រមុះ មាត់ ត្រចៀក សក់ ទឹកមុខ ... )
  - ជើង ដៃ ( មាំមួន សមនឹងដងខ្លួន វែងខ្លី ... )
  - អាកប្បកិរិយា ៖ សកម្មភាពផ្សេងៗ ការស្លៀកពាក់ ការនិយាយស្តី ការធ្វើការងារ ។ល។


www.elibraryofcambodia.org

- ចរិយាសម្បត្តិ

  គុណសម្បត្តិ ៖

  - ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់លើការសិក្សា ឬធ្វើការងារ
  - មានសណ្ដាប់ធ្នាប់ គោរពវិន័យ គោរពច្បាប់ ផ្ចិតផ្ចង់ ...
  - ឆ្លាតវាងវៃឆាប់យល់ ចេះចាំ ...
  - ក្លាហាន ហ៊ានទទួលខុសត្រូវ ...
  - ចិត្តទូលាយ ជួយទុក្ខធុរៈអ្នកដទៃ មិត្តភក្តិ ...
  - ស្លូតត្រង់ ស្រឡាញ់យុត្តិធម៌ សុចរិត ... ។

  គុណវិបត្តិ ៖ តើមានចំណុចអសកម្មត្រង់ណាខ្លះ ? **ឧ.** លេងសើចច្រើន មករៀនយឺត...។

## ៣.សេចក្ដីបញ្ចប់

- វាយតម្លៃ ៖ គេជាមនុស្សល្អ ចេះជួយគ្នាក្នុងគ្រាក្រ ... ។
- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះមិត្ត គោរពគួរយកតម្រាប់តាម ...។

## ៧.ការអនុវត្ត

| |
|---|
| *ប្រធាន ៖* សព្វថ្ងៃប្អូនរៀនជាមួយអ្នកគ្រូម្នាក់។ ចូរប្អូនពិពណ៌នាពីអ្នកគ្រូរបស់ប្អូនឱ្យបានក្បោះក្បាយ។ |


www.elibraryofcambodia.org

## សេចក្ដីអធិប្បាយ

ខ្ញុំជាសិស្សថ្នាក់ទី ៤ " ក១ "។ ខ្ញុំមានអ្នកគ្រូជំល្អម្នាក់ឈ្មោះអ្នកគ្រូធីតា។ គាត់ជាគ្រូប្រចាំថ្នាក់របស់ខ្ញុំ។ អ្នកគ្រូរបស់ខ្ញុំមានអាយុប្រហែល ៣៦ឆ្នាំហើយ ។

អ្នកគ្រូធីតា មានមានមិនតូចមិនធំ ល្មម តែគាត់ខ្ពស់ស្រឡះសម្បុរសណ្ដែកបាយ ហើយមានទឹកមុខស្រស់ស្រាយ។ គាត់មានសក់ស្លូត ភ្នែកធំល្មម ច្រមុះស្រួច មុខរាងពងក្រពើ បបូរមាត់ស្តើង មានដៃជើងស្រលូនសមនឹងដងខ្លួន។ ពេលគាត់មកបង្រៀន គាត់តែងពាក់អាវសសំពត់ខៀវ។ អ្នកគ្រូខ្ញុំ ស្លូតបូតសុភាពរាបសា សម្ដីទន់ភ្លន់ ចិត្តធ្ងន់មិនឆាប់ខឹងទេ។ អ្នកគ្រូរបស់ខ្ញុំព្យាយាមណាស់ នៅពេលបង្រៀនសិស្ស បើសិស្សមិនទាន់យល់ខ្លឹមសារមេរៀន គាត់តែងពន្យល់សារឡើងវិញរហូតដល់សិស្សយល់មេរៀន។ គាត់ប្រកាន់សេចក្ដីយុត្តិធម៌ ពេលកែកិច្ចការរបស់សិស្ស គាត់តែងដាក់ពិន្ទុឱ្យសុចរិតមិនលម្អៀង ឬប្រកាន់បក្សពួកឡើយ។ អ្នកគ្រូមានចិត្តសន្ដោសប្រណីយោគយល់អធ្យាស្រ័យ ចំពោះសិស្ស ដែលមានកំហុស ហើយចេះកែកំហុសឆ្គងទាំងនោះ។ អ្នកគ្រូជាមនុស្សប្រកបដោយព្រហ្មវិហារធម៌ គាត់ជាឪពុកម្ដាយទីពីររបស់ខ្ញុំ។

ខ្ញុំគោរពស្រឡាញ់គាត់ណាស់ ព្រោះគាត់ជាអ្នកផ្ដល់ចំណេះដឹងដល់សិស្សានុសិស្សគ្រប់ៗគ្នា។ ដូច្នេះ ខ្ញុំត្រូវខិតខំសិក្សារៀនសូត្រស្ដាប់ដំបូន្មានរបស់គាត់ គោរពវិន័យសាលា មិនឱ្យអ្នកគ្រូ និងឪពុកម្ដាយខកចិត្តឡើយ។


www.elibraryofcambodia.org

វិញ្ញាសាទី ២

# តែងសេចក្ដីបែបពិពណ៌នា អំពីសត្វ

## ក. គម្រោងតែង

### ១. សេចក្ដីផ្ដើម

បង្ហាញពីសត្វនោះដោយប្រាប់ ៖

- ឈ្មោះសត្វ ... ភេទ ...
- អាយុ ...
- ទីលំនៅ ...។

### ២. តួសេចក្ដី

- រូបរាង
  - មាឌ ៖ តូច ធំ ស្គម ធាត់ ...
  - កម្ពស់ ៖ ទាប ខ្ពស់ ...
  - សម្បុរ ៖ ស ខ្មៅ ក្រហម ត្នោត ...
  - ខ្លួន ៖ ជើង ក ភ្នែក ច្រមុះ មាត់ ត្រចៀក ស្នែង រោម ...។
- គុណសម្បត្តិ
  - ចរិតលក្ខណៈ ៖ ស្លូត ឧស្សាហ៍ .....
  - ការប្រើប្រាស់ ៖ ភ្ជួរ រាស់ អូសរទេះ ចាំផ្ទះ .........
  - ការថែទាំ ៖ លាងទឹក ឱ្យស៊ីស្មៅ ផឹកទឹក ចាក់ថ្នាំបង្ការ ... ផលប្រយោជន៍។
- គុណវិបត្តិ
  - ភាព សកម្មភាពបង្កការលំបាក ដេកច្រមក់ ...
  - បំផ្លិចបំផ្លាញ ...។


www.elibraryofcambodia.org

៣.សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះសត្វនោះ ... ។

## ខ.ការអនុវត្ត

> *ប្រធាន ៖* ប្អូនបានទៅស្នាក់នៅផ្ទះជីតារបស់ប្អូន ហើយបានឃើញគោមួយនឹម ។ ចូរប្អូនពិពណ៌នា ពីសត្វគោដែលអ្នកបានឃើញនោះ ។

### សេចក្ដីអធិប្បាយ

ជីតាខ្ញុំរស់នៅជនបទធ្វើស្រែចម្ការ។ គាត់ចិញ្ចឹមគោមួយនឹម មួយឈ្មោះអាចម្ប៉ា មួយទៀតឈ្មោះអាឃ្មៀច។ គោទាំងពីរនេះមានមាឌធំមាំ។ វាមានរាងខ្ពស់មានរោមទន់រលោង។ អាចម្ប៉ាសម្បុរស។ អាឃ្មៀចសម្បុរសស្រគាំ។ ស្នែងវាខ្មៅ ហើយកោងទៅមុខ។ ជើងវាធំ។ កវាក្រាស់ឡើងមូល។ ត្រចៀកវាបើក។ កន្ទុយវែងធ្លាក់ផុតកែង។

អាចម្ប៉ាស្លូតជាងអាឃ្មៀច។ ពួកវាជួយធ្វើការជីតាខ្ញុំ ឥតធុញទ្រាន់ឡើយ។ ពួកវាមានកម្លាំងដូចដំរី។ វាអាចអូសរទេះដឹកស្រូវ។ វាភ្ជួររាស់បានជាច្រើនស្រែ។ អាចម្ប៉ា និងអាឃ្មៀច ដឹកពោត និងអុសបានយ៉ាងច្រើន។ ជីតាខ្ញុំ ស្រឡាញ់គោគាត់ណាស់។ គាត់តែងតែរកស្មៅ ដើមស្រូវ ដើមពោត និងទឹកស្អាត ឱ្យគោរបស់គាត់ស៊ី។ ពេលយប់ វាដេកក្នុងក្រោលក្បែរភ្នក់ភ្លើង ដែលជីតាខ្ញុំដុតដេញមូស។

ខ្ញុំពិតជាស្រឡាញ់អាឃ្មៀច និងអាចម្ប៉ានេះណាស់ ព្រោះវាជាសត្វឧស្សាហ៍ និងស្លូតបូត។ ជីតាខ្ញុំ បានចូរកម្លាំងដោយសារវាទាំងពីរនេះក្នុងការងារស្រែចម្ការគ្រប់រដូវ។


www.elibraryofcambodia.org

វិញ្ញាសាទី ៣

# តែងសេចក្ដីបែបពិពណ៌នា អំពីទីកន្លែង

## គ.ការណែនាំទូទៅ

ដើម្បីធ្វើពណ៌នាអំពីទីកន្លែង ត្រូវធ្វើឱ្យអ្នកអានឃើញទីកន្លែងនោះច្បាស់លាស់ គឺនិយាយយ៉ាងដូចម្ដេចឱ្យទីកន្លែងនោះហាក់បិតនៅចំពោះមុខអ្នកអានតែម្ដង។ ដូចនេះត្រូវរកទីតាំងមួយដើម្បីកំណត់ឱ្យគេស្គាល់។

យើងត្រូវបញ្ជាក់ទៀត អំពីសភាព ឬលក្ខណៈរបស់ទីកន្លែងនោះ (ជាភូមិចាស់បុរាណ ឬភូមិដែលទើបតែកកើតថ្មី ) ។

- កាលណាមើលពីចម្ងាយ ទិដ្ឋភាពសរុបរួមបានបង្ហាញឡើង ( ទំហំ រាង ពណ៌ )
- ពេលចូលទៅជិត ត្រូវបង្ហាញទិដ្ឋភាពនៃផ្នែកនីមួយៗដែលលេចឡើងច្បាស់ ។ ឧ. ដំបូលផ្ទះមានពណ៌ក្រហម ។
- ពេលចូលទៅដល់ ត្រូវបញ្ជាក់ឱ្យច្បាស់អំពីទីតាំងនៃផ្នែកនីមួយៗរបស់ទីកន្លែង ដូចជាចំនួនផ្ទះ សំណង់ផ្សេងៗមានសាលារៀន មន្ទីរពេទ្យ វត្ត ស្ពាន អណ្ដូង។ល។ ក្រៅពីនេះ ដើម្បីញ៉ាំងឱ្យកិច្ចការកាន់តែមានភាពរស់រវើក យើងអាចលើកយកមកនិយាយបន្ថែមបានអំពីជីវភាព និងមុខរបរប្រជាជន ជំនឿ ទំនៀមទម្លាប់ ប្រពៃណី និងចិត្តគំនិតរបស់ប្រជាជន ។

ទីបំផុត យើងត្រូវបង្ហាញមនោសញ្ចេតនា ឬចំណាប់អារម្មណ៍ចំពោះទីកន្លែង ដែលបានលើកយកមកធ្វើពណ៌នា ដូចជាការជាប់ចិត្តស្រឡាញ់ ឬការគោរពជាដើម ។


www.elibraryofcambodia.org

## ខ. ឧទាហរណ៍ ការបំផុសគំនិត

> *ប្រធាន ៖* ចូរធ្វើពណ៌នាអំពីភូមិកំណើតរបស់អ្នក។

### ការរៀបចំគំនិត

- ភូមិកំណើតរបស់អ្នក ឋិតនៅកន្លែងណា ? មានអ្វីដែលអាចធ្វើជាកំណត់សម្គាល់បាន ?
- តើភូមិអ្នកមានទីតាំងពីបុរាណកាលមក ឬទើបតែកសាងថ្មី ?
- បើមើលពីចម្ងាយ ភូមិអ្នកមានទិដ្ឋភាពយ៉ាងដូចម្ដេច ? ពេលចូលទៅដល់អ្នកឃើញអ្វីខ្លះ ?
- ភូមិអ្នកមានប្រជាជនតិច ឬច្រើនប្រកបមុខរបរអ្វីខ្លះ ? មានជីវភាពដូចម្ដេច ? មានជំនឿទំនៀមទម្លាប់ប្រពៃណីយ៉ាងដូចម្ដេច ?
- តើអ្នកស្រឡាញ់ភូមិកំណើតរបស់អ្នកដែរឬទេ ? ពីព្រោះអ្វី ?

## គ. គម្រោងតែងទូទៅ

### ១. សេចក្ដីផ្ដើម

- ពេលវេលា ( ទៅទីនោះ ... )
- ទីកន្លែង ( ឈ្មោះទីកន្លែង ... ទីកន្លែងនោះស្ថិតនៅ ភូមិ ... ឃុំ ... ស្រុក ... ខេត្ត ... )

### ២. តួសេចក្ដី

- ទិដ្ឋភាពខាងក្រៅ ឬមើលពីចម្ងាយ ៖
  - ទិដ្ឋភាពមើលពីចម្ងាយ ( ទីតាំងនោះមានទ្រង់ទ្រាយដូចម្ដេច ? ប្រៀបដូចអ្វី ? ទំហំ រាង ពណ៌ ... )


www.elibraryofcambodia.org

- ទិដ្ឋភាពពេលចូលទៅដល់ (ទីតាំងនោះមានទ្រង់ទ្រាយដូចម្ដេច ? ឃើញអ្វីខ្លះនៅទីនោះ ...)

• ទិដ្ឋភាពពេលចូលទៅជិត ឬខាងក្នុង ៖

- រូបរាង ឬទ្រង់ទ្រាយ ហេដ្ឋារចនាសម្ព័ន្ធខាងក្នុង ( មានរូបរាងទ្រង់ទ្រាយដូចម្ដេច ? ... )
- មានអ្វីខ្លះ ដូចជាចំនួនផ្ទះ បែបផែនសំណង់ជុំវិញផ្ទះមានអ្វី ? ក្រោមផ្ទះមានអ្វី ? ទីតាំងអណ្ដូងទឹក ឬស្រះទឹក សាលារៀន មន្ទីរពេទ្យ វត្ត សាលាឃុំ ... ។
- វត្ថុ ឬសម្ភារៈ ( មានវត្ថុ ឬ សម្ភារៈអ្វីខ្លះនៅទីនោះ ? ... )
- សកម្មភាពអ្នកធ្វើការ ឬ អ្នករស់នៅទីនោះ ...
- ទឹកចិត្តអ្នកធ្វើការ សកម្មភាពអ្នករស់នៅទីនោះ ...
  + អ្នករស់នៅទីនោះ ...
  + ជីវភាព និងមុខរបរ
  + ជំនឿសាសនា
  + ទំនៀមទម្លាប់ប្រពៃណី
  + ចិត្តគំនិត ។

• សារៈសំខាន់ និង ផលប្រយោជន៍ ៖ ទីនោះមានសារៈសំខាន់ និងផលប្រយោជន៍ដូចម្ដេច ? ... ។

## ៣.សេចក្ដីបញ្ចប់

• វាយតម្លៃទីកន្លែងនោះ ...
• បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះទីកន្លែងនោះ។


www.elibraryofcambodia.org

## ឃ.ការអនុវត្ត

> *ប្រធាន ៖* ចូរធ្វើពិពណ៌នាអំពីភូមិកំណើតរបស់ប្អូនឱ្យបានគ្រោះក្បាយ។

### សេចក្ដីអធិប្បាយ

ខ្ញុំបានរស់នៅភូមិកំណើតខ្ញុំអស់រយៈពេលដប់ឆ្នាំកន្លងមកហើយ ។ ភូមិខ្ញុំ ឋិតនៅតាមបណ្ដោយផ្លូវមាត់ទន្លេ មានឈ្មោះថា ភូមិកោះតាម៉ៅ ដែលស្ថិតក្នុងឃុំស្វាយតេង ស្រុកកងមាស ខេត្តកំពង់ចាម។ ភូមិនេះ មានកំណើតតាំងពីបុរាណកាលមកម្ល៉េះ ដែលមានចម្ងាយប្រមាណហុកសិបប្រាំបីគីឡូម៉ែត្រ ខាងកើតរាជធានីភ្នំពេញ។

បើមើលពីចម្ងាយ គេនឹងឃើញមានដើមឈើធំៗ ព័ទ្ធជុំវិញភូមិ ដូចជាកូនភ្នំតូចមួយពណ៌ខៀវស្រងាត់។ ពេលចូលទៅដល់ គេនឹងបានឃើញដើមឈើទាំងនោះ ជាប្រភេទដំណាំឈើហូបផ្លែ មានស្វាយ ខ្នុរ ល្មុត ម្កាក់ ឬក្រូចជាដើម។ ដំណាំនេះ ដូនតាខ្ញុំបានបន្សល់ទុកខ្លះ និងឪពុកម្ដាយខ្ញុំបានដាំបន្ថែមខ្លះ។ ពេលចូលទៅក្នុងភូមិ គេឃើញផ្ទះបុរាណជាផ្ទះប៉ិត ឬផ្ទះកន្លាំង សង់ខ្ពស់ផុតពីដីអមជាជួរ ទល់មុខផ្លូវលំមួយខ្សែ។ នៅក្រោមផ្ទះ គេឃើញមានគំនរដំឡូង ដែលទើបគាស់ថ្មីៗពីចម្ការ និងគំនរពោតទុំដែលបានហាលទុក។ នៅខាងត្បូងភូមិ មានវត្តចាស់ដ៏ធំមួយសម្រាប់អ្នកភូមិទៅប្រារព្ធពិធីបុណ្យនានាតាមប្រពៃណី។ ក្នុងបរិវេណវត្តមានសាលាបឋមសិក្សា ដែលមានដប់បន្ទប់សង់នៅលើទីទួលជាសាលាដែលសង់តាំងពីសម័យដើមមកម្ល៉េះ។ នៅខាងលិចភូមិ មានផ្សារមួយ គេតែងហៅថាផ្សារក្រមួនមានទំហំធំល្មម ដែលតាំងលក់បន្លែផ្លែឈើ ត្រី សាច់ជាផលិតផលក្នុងស្រុក និងក្រៅស្រុក។ នៅខាងលិចផ្សារក្រមួនមានមណ្ឌលសុខភាពមួយកន្លែង ដែលមានគ្រូពេទ្យចំនួនបួននាក់ រង់ចាំបម្រើសេវាសុខភាពជូនដល់អ្នកភូមិខ្ញុំ។

ខ្ញុំពិតជាស្រឡាញ់ភូមិកំណើតខ្ញុំណាស់ ព្រោះបានផ្ដល់ជីវិតដល់រូបខ្ញុំ និងបានបន្សល់ទុកអនុស្សាវរីយ៍តាំងពីកុមារភាពមករហូតបច្ចុប្បន្ន។


www.elibraryofcambodia.org

វិញ្ញាសាទី ៤

# តែងសេចក្តីបែបពិពណ៌នា អំពីទេសភាព

## ក.ការណែនាំទូទៅ

ធ្វើពណ៌នាអំពីទេសភាព គឺត្រូវនិយាយរៀបរាប់អំពីធម្មជាតិមានព្រៃព្រឹក្សា រុក្ខជាតិនានា ភ្នំ ស្ទឹង ទន្លេ បឹងបួ ... ខ្យល់អាកាស ផ្ទៃមេឃ ព្រះអាទិត្យ ព្រះចន្ទ ផ្កាយ ខ្យល់ និងសកម្មភាពមនុស្ស នៅទីកន្លែងណាមួយ ដែលយើងបានឃើញ បានគយគន់ ។

ក្នុងការគយគន់ទេសភាពនេះ យើងត្រូវប្រើភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្ដាប់ ច្រមុះសម្រាប់ស្រង់ក្លិន ដោយភ្ជាប់ទៅនឹងមនោសញ្ចេតនារំភើបរបស់យើង។ ដើម្បីញ៉ាំងទេសភាពដែលយើងលើកយកមកធ្វើពណ៌នានេះ ឱ្យមានសម្រស់រស់រវើក យើងត្រូវចេះជ្រើសរើសធម្មជាតិនានាប្លែកៗមករំលេចបន្ថែមឱ្យសមស្របទៅតាមការពិតជាក់ស្ដែង។ បានសេចក្ដីថា ធ្វើយ៉ាងណាឱ្យអ្នកអានមានជំនក់អារម្មណ៍ហាក់ឃើញរូបភាព ឬផ្ទាំងគំនូរទេសភាពធម្មជាតិទាំងនោះនៅក្នុងខួរក្បាលរបស់គេ។ ពុំនោះសោត គឺបណ្ដុះមនោសញ្ចេតនារបស់អ្នកអានឱ្យកាន់តែខ្លាំងក្លាឡើង។

## ខ.ឧទាហរណ៍ ការបំផុសគំនិត

| | |
|---|---|
| *ប្រធាន ៖* | អ្នកបានទៅកំសាន្តនៅស្រុកស្រែ ពេលវស្សានរដូវ ។ ចូរពណ៌នាអំពីទេសភាព ពេលព្រឹកនៃរដូវនោះ ។ |


www.elibraryofcambodia.org

## គ. គម្រោងតែងសេចក្ដី

### ១. សេចក្ដីផ្ដើម

- ពេលវេលា ( ទៅទីកន្លែងនោះ ... )
- ឈ្មោះទីកន្លែង ( ទីនោះជាកន្លែងអ្វី ... )។

### ២. តួសេចក្ដី

- ទិដ្ឋភាពទូទៅមើលពីចម្ងាយ
- សណ្ឋានដីទីកន្លែង (មានលក្ខណៈ ទ្រង់ទ្រាយដូចម្ដេច ? ...)
- ធម្មជាតិ (ខ្យល់ ពន្លឺ មេឃ ពពក ពណ៌ ...ដោយធ្វើការប្រៀបធៀប)
- សកម្មភាពនិងសូរសំឡេង (មនុស្ស សត្វ វត្ថុ រុក្ខជាតិ ... ដោយធ្វើការប្រៀបធៀប)។

### ៣. សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះទេសភាពទីកន្លែងនោះ ។

## ឃ. ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | ចូរអ្នកសរសេរពណ៌នាពីទេសភាពភ្នំគូលែន ឱ្យបានក្បោះក្បាយ។ |

## សេចក្ដីអធិប្បាយ

នៅសប្ដាហ៍មុន ខ្ញុំនិងគ្រួសារខ្ញុំបានធ្វើដំណើរកំសាន្តនៅរមណីយដ្ឋានភ្នំគូលែន។ រមណីយដ្ឋាននេះស្ថិតនៅប៉ែកខាងជើងឆៀងខាងកើតទីរួមខេត្តសៀមរាប មានចម្ងាយហាសិបបីគីឡូម៉ែត្រពីទីរួមខេត្ត។ រមណីយដ្ឋាននេះស្ថិតនៅឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។


www.elibraryofcambodia.org

បើគេមើលពីចម្ងាយ ភ្នំនេះមានកម្ពស់ខ្ពស់ស្កឹមស្កៃលេចធ្លោលើសអស់ព្រៃព្រឹក្សាទាំងឡាយ។ ភ្នំនេះមានរយៈកម្ពស់ដល់ទៅបួនរយកៅសិបពីរម៉ែត្រ។ គេអាចឡើងលើភ្នំ តាមរថយន្តដែលអាចបើកបរឡើងទៅលើភ្នំយ៉ាងងាយ ឬក៏ដោយជើង។ នៅពេលទៅដល់ជើងភ្នំ គេសង្កេតឃើញផ្ទាំងថ្មធំៗ ហាក់ដូចជា ជញ្ជាំងនាគ នៅកណ្តាលទីស្មសានលេចដោយសម្រស់ និងបង្កប់អាថ៌កំបាំងអតីតកាលនៃសម័យអង្គរ។ រមណីយដ្ឋានភ្នំគូលែនទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនជារៀងរាល់ថ្ងៃ និងមានប្រជាពលរដ្ឋមកពីទីជិតទីឆ្ងាយៗតាំងលំនៅឋាន ប្រកបអាជីវកម្មកសិកម្មយ៉ាងច្រើនកុះករ។ តំបន់ភ្នំគូលែនមិនត្រឹមតែជាតំបន់ទេសចរណ៍ប៉ុណ្ណោះទេ តែក៏ជាតំបន់កសិកម្ម ដីមានជីជាតិអាចដាំដំណាំបានគ្រប់ប្រភេទដូចជាចេក ខ្នុរ ដំឡូង គ្រាវជាដើម។ នៅខែចេត្រផ្លែគូលែនចាប់ផ្តើមទុំ មានពណ៌ក្រហមក្រមៅ។

ផ្លែគូលែនមានរសជាតិផ្អែមឆ្ងាញ់ពិសាណាស់ ហើយមានតម្លៃទៀតផង។ ទិន្នផលកសិកម្មទាំងនេះ អាចជួយសម្រាលជីវភាពគ្រួសារប្រជារាស្ត្រយើងបានមួយភាគធំដែរ។

ខ្ញុំពិតជាស្រឡាញ់រមណីយដ្ឋានភ្នំគូលែនណាស់ ព្រោះទីនេះបានបង្កប់អនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបានសម្រាប់គ្រួសារខ្ញុំ និងអ្នកទេសចរដទៃទៀតដែលបានមកកម្សាន្តនៅទីនេះ។


www.elibraryofcambodia.org

វិញ្ញាសាទី ៥

# តែងសេចក្ដីបែបពិពណ៌នា អំពីសកម្មភាព

## ក.គម្រោងតែង

១.សេចក្ដីផ្ដើម

- ពណ៌នាទូទៅទាក់ទងនឹងសកម្មភាព
- ពេលវេលា
- ទីកន្លែង
- អ្នកចូលរួម ... ។

២.តួសេចក្ដី

- មុនពេលធ្វើសកម្មភាព ៖
  - ការរៀបចំសម្ភារៈសម្រាប់ធ្វើសម្មភាព
  - ស្ថានភាពទីកន្លែង
  - បរិយាកាសទូទៅ ... ។
- ពេលធ្វើសកម្មភាព ៖
  - ការចាប់ផ្ដើមសកម្មភាព
  - ការប្រើកម្លាំង និងបច្ចេកទេស
  - ភាពមមាញឹកក្នុងការងារតាមផ្នែកនីមួយៗ
  - សកម្មភាពផ្សេងៗទៀត
  - ភាពរីករាយក្នុងពេលធ្វើសកម្មភាព ... ។
- ក្រោយពេលធ្វើសកម្មភាព ៖
  - បង្ហាញពីលទ្ធផលការងារ
  - បរិយាកាសទូទៅនៅទីកន្លែងការងារ ... ។


www.elibraryofcambodia.org

### ៣.សេចក្ដីបញ្ចប់

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នកចំពោះសកម្មភាព
- បង្ហាញពីសារប្រយោជន៍នៃការធ្វើសកម្មភាព ។

## ខ.ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | នៅថ្ងៃព្រហស្បតិ៍មួយ ថ្នាក់រៀនរបស់ប្អូនបានធ្វើពលកម្មរួមមួយ។ ចូរអ្នកពិពណ៌នាពីសកម្មភាពធ្វើពលកម្មនោះ តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។ |

## សេចក្ដីអធិប្បាយ

កាលពីថ្ងៃព្រហស្បតិ៍សប្ដាហ៍មុន នៅថ្នាក់រៀនរបស់ខ្ញុំបានធ្វើពលកម្មសម្អាតបន្ទប់រៀនទាំងអស់គ្នា ដោយមានការចូលរួមពីអ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ដោយមានសម្ភារៈគ្រប់គ្នា។

ក្រោយពីគោរពទង់ជាតិរួច នៅម៉ោងប្រាំពីរនិងដប់នាទី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សបានបំបែកផ្លូវទៅតាមថ្នាក់នីមួយៗ រួចអ្នកគ្រូ លោកគ្រូ បានដឹកនាំសិស្សយកសម្ភារៈដូចជា ធុងទឹក បង្គី អម្បោស កំណាត់ ទៅតាមមុខសញ្ញាដែលអ្នកគ្រូបានចែករួចហើយ ។

នៅពេលនោះ សិស្សានុសិស្សបានចាប់ផ្ដើមបំពេញការងាររៀងៗខ្លួន។ សិស្សខ្លះយកកំណាត់ទៅជូតតុ កៅអី។ សិស្សខ្លះបោសសម្អាតកម្រាលឥដ្ឋ។ សិស្សបីនាក់ទៀត បោសសម្អាតពិតាន ហើយសិស្សខ្លះ


www.elibraryofcambodia.org

ទៀត យកបន្ទីកើបសំរាមយកទៅចាក់ចូលធុងសំរាម។ សិស្សខ្លះយកកំណាត់ទៅជូតបង្អួចទ្វារ។ សិស្សខ្លះទៀតយកកំណាត់ ធុងទឹកទៅជូតកម្រាលឥដ្ឋក្នុងបន្ទប់រៀន។

ចំណែកអ្នកគ្រូដឹកនាំសិស្សឱ្យធ្វើការងារតាមតួនាទីរៀងៗខ្លួន។ សកម្មភាពធ្វើពលកម្មសម្អាតថ្នាក់រៀននេះប្រព្រឹត្តទៅយ៉ាងសកម្មរស់រវើក ហើយស្អិតក្នុងបរិយាកាសរីករាយក្រៃលែង ។

ខ្ញុំពេញចិត្តនឹងការធ្វើពលកម្មសម្អាតថ្នាក់នេះណាស់ ពីព្រោះការធ្វើពលកម្មនាំឱ្យយើងមានសុខភាពល្អ ធ្វើឱ្យថ្នាក់រៀនមានបរិស្ថានល្អ និងបង្ការជំងឺផ្សេងៗ។


www.elibraryofcambodia.org

## វិញ្ញាសាទី ៦ តែងសេចក្ដីបែបពិពណ៌នា អំពីពិធីបុណ្យផ្សេងៗ

### ក.គម្រោងតែងសេចក្ដី

១.សេចក្ដីផ្ដើម

- ពេលវេលា
- ទីកន្លែង
- ឈ្មោះពិធីបុណ្យ
- គោលបំណងនៃពិធីបុណ្យ ។

២.តួសេចក្ដី

- មុនពេលចាប់ផ្ដើមប្រារព្ធពិធីបុណ្យ
  - ការអញ្ជើញភ្ញៀវ
  - រៀបចំបោសសម្អាតផ្ទះ
  - រៀបចំតុបតែងផ្ទះ
  - ការសង់រោង
  - ការទទួលភ្ញៀវ
  - ការសូត្រមន្តសម្ដែងធម៌ទេសនា
- ការវេរចង្ហាន់ប្រគេនព្រះសង្ឃ និងបង្សុកូល
  - ការថ្លែងអំណរគុណចំពោះភ្ញៀវ
  - ការរៀបចំផ្សេងៗ។

៣.សេចក្ដីបញ្ចប់

- បង្ហាញពីចំណាប់អារម្មណ៍ និងមនោសញ្ចេតនារបស់អ្នកចំពោះពិធីបុណ្យនេះ។


www.elibraryofcambodia.org

## ខ.ការអនុវត្ត

*ប្រធាន* ៖ អ្នកបានទៅចូលរួមពិធីបុណ្យ៧ថ្ងៃរបស់អ្នកជិតខាង។ ចូរអ្នកសរសេរពិពណ៌នាពីពិធីបុណ្យនេះឱ្យបានក្បោះក្បាយ។

### សេចក្តីអធិប្បាយ

តាមទំនៀមទម្លាប់ខ្មែរ ក្រោយពីមានបុគ្គលណាមួយទទួលមរណភាពបានគម្រប់៧ថ្ងៃ គ្រួសារសពតែងធ្វើពិធីបុណ្យមួយហៅថា " បុណ្យ៧ថ្ងៃ " ដើម្បីឧទ្ទិសកុសលជូនដល់បុគ្គលដែលទើបនឹងស្លាប់នោះ។

មុនថ្ងៃចាប់ផ្តើមបុណ្យ អ្នកផ្តើមបុណ្យបានអញ្ជើញភ្ញៀវជិតឆ្ងាយឱ្យមកចូលរួមក្នុងពិធីបុណ្យ។ អ្នកខ្លះទិញសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យ។ លុះដល់ព្រឹក ក្នុងថ្ងៃចាប់ផ្តើមពិធីបុណ្យនោះ គេឃើញបងប្អូនញាតិមិត្តមកជួយរៀបចំសង់រោង បោសសម្អាត និងតុបតែងកន្លែងរៀបចំពិធី។

លុះវេលារសៀល ជាពេលប្រារព្ធពិធីបុណ្យ អ្នកផ្តើមបុណ្យបានមកឈរនៅមុខរោង ដើម្បីរង់ចាំទទួលភ្ញៀវ។ ពេលនោះ មានភ្ញៀវយ៉ាងច្រើនកុះករ ប្រកបដោយសម្លៀកបំពាក់សមរម្យ មកចូលរួមពិធី។

ពេលភ្ញៀវអញ្ជើញដល់ អ្នកផ្តើមបុណ្យលើកដៃសំពះទទួលភ្ញៀវ ឯភ្ញៀវក៏សំពះតបវិញ។ ភ្ញៀវបាននាំបច្ច័យ និងសម្ភារៈផ្សេងៗសម្រាប់ចូលបុណ្យ និងពិសាភោជនាហារ។

ពេលវេលាល្ងាច ព្រះសង្ឃនិមន្តមកសូត្រមន្ត រួចសម្តែងធម៌ទេសនា។ លុះព្រឹកឡើង ជាថ្ងៃបង្ហើយបុណ្យគេរៀបចំប្រគេនចង្ហាន់ព្រះសង្ឃធ្វើពិធីបង្សុកូល និងឧទ្ទិសកុសលជូនអ្នកដែលបានស្លាប់ទៅ។ ទីបញ្ចប់អ្នកផ្តើមបុណ្យថ្លែងអំណរគុណចំពោះភ្ញៀវទាំងអស់ ដែលបានចូលរួមក្នុងពិធីបុណ្យ។ រីឯភ្ញៀវក៏វិលទៅលំនៅឋានរៀងៗខ្លួន។

ពិធីបុណ្យនេះពិតជាសំខាន់ណាស់ចំពោះប្រជាពលរដ្ឋខ្មែរ ហើយខ្ញុំតែងនឹកឃើញពីទិដ្ឋភាពបុណ្យនេះជានិច្ច។


www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្មៅ យ៉ាត់ណៃ, ខ្មៅ សុផល, ខ្មៅ វិសាល, ខ្មៅ វិមុន, ខ្មៅ ភាពជា, ខ្មៅ ចំរើន និង ខ្មៅ ការី
បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលផលវិញ្ញាណក្ខន្ធ ឧបាសក ខ្មៅ ពាញ និង ឧបាសិកា ឈា ឃឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "កម្មសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ ឃុនសំរឹង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

**យើងបម្រើសេវាកម្ម :**

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

**WE SERVE :**

- book and teaching-aid developm
- printing
- distribution to schools


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច

# PDH BOOKSHOP


**មានលក់ :**

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារៈការិយាល័យគ្រប់មុខ !

**SELLING :**

textbooks , teacher's manuals , workbooks , supplementary reade teaching-aids and stationary !

www.elibraryofcambodia.org